# អាហារផ្នែកវិញ្ញាណតាមរដូវ
# កាលដ៏ ស័ក្តសម

គ្រាន់តែជឿតាម គ្រាន់តែជឿតាម
គ្រប់ការនឹងសម្រេច គ្រាន់តែ...

ធ្វើដូចម្តេចបាន ឥឡូវច្រៀងបែបនេះវិញះ

ឥឡូវខ្ញុំជឿ ឥឡូវខ្ញុំជឿ
គ្រប់ការនឹងសម្រេច ឥឡូវខ្ញុំជឿ
ឥឡូវខ្ញុំជឿ ឥឡូវខ្ញុំជឿ
គ្រប់ការនឹងសម្រេច ឥឡូវខ្ញុំជឿ។

ឥឡូវនេះចូរយើងបន្តឈរដដែល ព្រមទាំងអោនក្បាលចុះ។

ព្រះអម្ចាស់អើយ សូមឲ្យនេះមិនមែនគ្រាន់តែជាចម្រៀងឡើយ ប៉ុន្តែសូមឲ្យវាជាជម្រៅដ៏ជ្រៅដែលច្រៀងចេញពីដួងចិត្តរបស់ពួកយើង"ឥឡូវខ្ញុំជឿ!" ពួកសាវកបាននិយាយក្នុងពេលមួយ បន្ទាប់ពីព្រះយេស៊ូវបានធ្វើការអស្ចារ្យជាច្រើន ពួកគេបាននិយាយថា "ព្រះអង្គអើយ ឥឡូវពួកយើងជឿហើយ។"

ព្រះយេស៊ូវមានបន្ទូលថា "ឥឡូវអ្នកជឿហើយឬ?"

2 ពួកគេនិយាយថា "យើងជឿថាទ្រង់ជ្រាបគ្រប់ការទាំងអស់ ហើយទ្រង់មិនត្រូវការឲ្យនរណាបង្រៀនទ្រង់ឡើយ។" ដូច្នេះហើយ យប់នេះព្រះបិតាអើយ យើងដឹងប្រាកដថា ទ្រង់មិនត្រូវការ ការបង្រៀនរបស់យើងទេ តែយើងត្រូវការការបង្រៀនរបស់ទ្រង់។ ដូច្នេះយើងអធិស្ឋានថា ទ្រង់នឹងបង្រៀនយើងពីរបៀបនៃការអធិស្ឋាន របៀបនៃការរស់នៅ ព្រមទាំងរបៀបនៃការជឿ។ សូមប្រទានដល់ទូលបង្គំ ព្រះអង្គអើយតាមរយៈកម្មវិធីយប់នេះ។ ប្រសិនបើយើងខ្វះអ្វីមួយ សូមប្រទានវាមកពួកយើងខ្ញុំ ផងព្រះអង្គអើយ យើងទូលសូមក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាមែន។

3 ខ្ញុំដឹងថាយប់នេះ មានមនុស្សជាច្រើនក្នុងចំណោមអ្នករាល់គ្នា បានឈរសារជាថ្មីម្តងទៀត។ ហើយនៅខាងក្រៅបានជួបក្រុមមនុស្សដែលនិយាយថា ពួកគេ

មិនអាចចូលមកខាងក្នុងបានពួកគេក៏ស្តាប់តាមវិទ្យុក្នុងឡានផ្សេងៗរបស់ពួកគេ។ ហើយឥឡូវនេះ យើងនឹងព្យាយាមធ្វើឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ក្នុងយប់នេះ ក្នុងយប់ថ្ងៃអាទិត្យ យើងនឹងថ្វាយការអធិស្ឋានសម្រាប់អ្នកជម្ងឺ ហើយសេចក្តីអធិស្ឋាននោះដូចដែលអ្នកបានឃើញនៅទីនេះ។ ប៉ុន្តែយើងនឹងថ្វាយការថ្វាយបង្គំយប់នេះ ដោយផ្តោតទៅលើការអធិស្ឋានសម្រាប់អ្នកជម្ងឺ។

4 ហើយខ្ញុំចង់ឲ្យអ្នករាល់គ្នារឹងមាំ ឡើងឥឡូវនេះនៅក្នុង...ព្រះបន្ទូលដ៏បរិសុទ្ធរបស់ព្រះ ដោយក្តីជំនឿ ក្តីជំនឿក្នុងវេលានេះ។ ជាក្តីជំនឿដែលជឿលើសជាងជំនាន់ណាទាំងអស់ ពីព្រោះវាត្រូវតែជាសេចក្តីជំនឿដែលបានលើកឡើង ដែលបានលើកឡើងពិត។ ដូច្នេះហើយ យើងចង់ឲ្យអ្នករាល់គ្នាយប់នេះជឿ នូវគ្រប់ទាំងអ្វីដែលអ្នករាល់គ្នាបានឃើញនិងឮ ជាព្រះបន្ទូលដែលអ្នកបាន ឮចេញពីការអធិប្បាយ ជា—ជាទីសម្គាល់និងការអស្ចារ្យដែលអ្នកធ្លាប់បានឃើញរួចហើយ។ យើងចង់ឲ្យអ្នករាល់គ្នាប្រមូលផ្តុំការនោះនៅក្នុងចិត្ត ហើយពិចារណាថា តើវាមកពីព្រះឬក៏មិនមែន។

5 គឺដូចជាអេលីសេក្នុងសម័យសញ្ញាចាស់បាននិយាយថា "បើដឹងថាទ្រង់ជាព្រះហើយនោះចូរបម្រើទ្រង់" ហើយបើព្រះយេស៊ូវគឺជាចំណុចកណ្តាលនៃគ្រីស្ទានទាំងអស់ នោះខ្ញុំគិតថា យើងត្រូវតែបោះបង់ចោលអ្វីផ្សេងទៀត ដែលអាចញែកយើងចេញពីទ្រង់។ ចងចាំថា ទ្រង់គឺជាចំណុចកណ្តាល ទ្រង់គឺជាតារានៃទិសខាងជើង ទ្រង់គឺគ្មានទីបញ្ចប់ ទ្រង់គឺពេញខ្នាត។ ហើយបើសិនជាទ្រង់គឺជាតារានៃទិសខាងជើង...នោះគឺមានតែរបស់មួយប៉ុណ្ណោះ ដែលចង្អុលទៅទិសខាងជើង គឺជាត្រីវិស័យដែលអ្នកធ្វើនាវាជាមួយ។ ហើយត្រីវិស័យដែលខ្ញុំព្យាយាមឲ្យអ្នកធ្វើដំណើរជាមួយនោះ គឺព្រះបន្ទូល ហើយព្រះបន្ទូលនោះតែងតែចង្អុលទៅទ្រង់។

6 ហើយយើងមានអារម្មណ៍ដូចជា យើងកំពុងតែជួបទុកព្រួយ យ៉ាងធំនិងការកាត់ទោសតឹងទ្រូងនៃពេលវេលា ព្រមទាំងទុក្ខវេទនារវាងជាតិសាសន៍ ហើយនិងកិច្ចការគ្រប់យ៉ាងបានកើតឡើង ពេលខ្លះខ្ញុំត្រូវហ៊ុំព័ទ្ធដូចជា...គ្រប់ទីដែលខ្ញុំសម្លឹងមើល វាហាក់បីដូចជានៅលើ...នៅក្នុងកប៉ាល់លើសមុទ្រដ៏សែនឆ្ងាយ។ ហើយខ្ញុំបានក្លាយជាអ្នកគ្រប់គ្រងទូកនោះ។ ហើយតើធ្វើវាដោយរបៀបណា នោះស្រាប់តែមាននាវាមួយដ៏ធំ ធំជាងកប៉ាល់របស់ខ្ញុំមួយរយដង។ ប៉ុន្តែយើងនឹងលើកទង់ជ័យ

ឡើងជំនះពួកវា "នៅក្នុងទ្រង់យើងនឹងមានជ័យជំនះ លើអ្វីទាំងអស់។" កាបពីទែន នាយកនាវា បានកាន់ខ្សែនៃចុងបំផុតនៃនាវាជាប់ ទ្រង់នឹងទាញវា។ យើងនឹងមានជ័យជំនះលើពួកវា។

7 ឥឡូវយប់នេះយើងនឹងប្រញាប់ដើម្បីឲ្យអ្នកបានចេញមុនបន្តិច...យើងអគុណចំពោះការធ្វើដំណើរមកពីផ្លូវឆ្ងាយ ហើយត្រឡប់ទៅវិញ ព្រមទាំងការប្រុងប្រយ័ត្នក្នុងការបើកបរនិងការលះបង់ដែលអ្នកបានធ្វើ។ ហើយមើល នោះទើបធ្វើឲ្យខ្ញុំឈរកន្លែងនេះ ដើម្បីបន្តការចែកចាយ ព្រមទាំងធ្វើអ្វីទាំងអស់ដែលខ្ញុំអាចដើម្បីជួយដល់អ្នក។ ប៉ុន្តែនៅពេលខ្ញុំមកទីនេះ ខ្ញុំព្យាយាមប្រឹងប្រែងគ្រប់យ៉ាងតាមដែលអាចធ្វើទៅបាន ដើម្បីជួយក្នុងពេលដែលពួកយើងមកទីនេះ។ ហើយអ្នកអាចយកវា...បើសិនជាអ្នកចែកចាយដល់មនុស្សច្រើនពេក ក្នុងពេលតែមួយពួកគេច្បាស់ជាមិនអាចចងចាំបានទេ។ អ្នក—អ្នកគ្រាន់តែយកអ្វីមួយ កាន់វាឲ្យជាប់ទៅបុគ្គលនោះរហូតទាល់តែគេឃើញវា។ ហើយបន្ទាប់ពីគេបានកាន់រឹងមាំនៅក្នុងចិត្តរបស់ពួកគេហើយគេនឹង...បន្ទាប់មកបង្រៀនគេនូវអ្វីផ្សេងទៀត។ ពីមួយជំហានទៅមួយជំហាន ដូចជាយើងបានធ្វើ។

8 ឥឡូវ អ្នកត្រូវអធិស្ឋានដោយក្តីក្លាហាន ហើយជឿឥឡូវយប់នេះសម្រាប់ការប្រោសឲ្យជា។ ខ្ញុំមិនគិតថានឹងមានចម្ងល់អ្វីនៅក្នុងគំនិតរបស់អ្នក អំពីពេលវេលាដែលយើងរស់នៅ។ ខ្ញុំមិនជឿថានឹងមានចម្ងល់អ្វីនៅក្នុងគំនិតរបស់អ្នក អំពីថាតើព្រះគង់នៅកណ្តាលចំណោមរាស្ត្ររបស់ទ្រង់ឬអត់។ ខ្ញុំជឿថាអ្នកទាំងអស់គ្នាបានជឿ។ ហើយខ្ញុំ...គ្មានចម្ងល់ក្នុងចិត្តអំពីការនោះទេ។ ហើយខ្ញុំ—ខ្ញុំ—ខ្ញុំស្គាល់មនុស្សរបស់ខ្ញុំ មិត្តភ័ក្រ្តខ្ញុំ មិត្តក្នុងព្រះគ្រីស្ទកូនក្មេង—របស់ព្រះគ្រីស្ទ ខ្ញុំជឿដូច្នេះ។

9 ហើយវាផ្តល់ឲ្យខ្ញុំមានក្តីអំណរ នៅពេលឃើញថា អ្នកបានដឹងថាអ្នកបានទទួលសារពីព្រះ ហើយអ្នកបានផ្សាយវាទៅមនុស្សឯទៀត ព្រមទាំងឃើញថាគេបានឆ្លើយតបព្រមទាំងទទួល។ បន្ទាប់មកអ្នកត្រឡប់មើលមកក្រោយវិញ ហើយនិយាយថា "អគុណព្រះវបិតា" ឱតើនឹងមានអំណរប៉ុណ្ណាដែលបានឃើញកូនកំពុងទទួលទាននំប៉័ង ដែលបានបញ្ជូនទៅពួកគេ! អ្នកបានទទួលស្គាល់រួចមកហើយថាមាននិមិត្តមួយកាលពីឆ្នាំមុន នៅទីនេះ ត្រង់អាសនានេះ? ពិតមែនហើយ "នំប៉័ងនៃជីវិត" បងប្រុសនេវីល(Neville)អ្នកនៅចាំ ប្រហែលហើយ។ ជាវេលាដ៏អស្ចារ្យ!

10 ឥឡូវ ចូរយើងបែរមកវិញ បើអ្នកចង់អានជាមួយគ្នាឬគូសចំណាំត្រង់ចំណុចខ្លះ គ្រាន់តែ...ខ្ញុំគិតថាវាមិនស័ក្តសមទេ ដែលមានពិធីជួបជុំដោយមិនមានការអានព្រះបន្ទូល ហើយចែកចាយនូវទស្សនៈខ្លះទោះបើជាពិធីប្រោសឲ្យជា ឬអ្វីផ្សេងទៀតនោះ។ យើងទាំងអស់គ្នាយល់ហើយ។ ពីព្រោះគ្មានអ្នកប្លែកមុខក្នុងចំណោមយើងនោះទេ ខ្ញុំរំពឹងគិតថាអញ្ចឹងចុះ។ ប៉ុន្តែយើងទាំងអស់គ្នាបានស្គាល់នូវអ្វីដែលហៅថាការប្រោសឲ្យជា។ វាមិនមែននរណាម្នាក់ ធ្វើឲ្យអ្នកទេ វាគឺជាអ្វីដែលព្រះបានធ្វើរួចហើយ សម្រាប់អ្នក។ សេចក្តីសង្គ្រោះគឺនៅលើបន្ទាត់តែមួយ។ រឿងតែមួយគត់ដែលយើងត្រូវធ្វើគឺនាំមនុស្សឲ្យជឿថានោះគឺជាក្តីពិត។ ហើយព្រះបង្រៀនវាក្នុងព្រះបន្ទូលរបស់ទ្រង់ ហើយបញ្ជាក់ទៅដល់ពួកអ្នកដែលជឿវា ដ្បិតទ្រង់មានបន្ទូលថា "គ្រប់ការនឹងសម្រេចដល់អស់អ្នកណាដែលជឿ។

11 អ្នកនិយាយថា "គ្មានអ្វីដែលព្រះធ្វើមិនបាននោះទេ" អ្នកជឿទេ? វាក៏គ្មានអ្វីដែលអ្នកធ្វើមិនបានដូចគ្នា។ "ដ្បិតគ្រប់ទាំងការនោះនឹងសម្រេចបានដល់ពួកគេ" (ព្រះជាអង្គតែមួយគត់) "ដល់អស់អ្នកណាដែលជឿ។" ឃើញទេ? ដូច្នេះហើយគ្មានអ្វីដែលថាមិនអាចទៅរួចទេសម្រាប់អ្នក បើសិនជាអ្នកអាចគ្រាន់តែជឿ។

12 ឥឡូវ នៅក្នុងពង្សាវតារក្សត្រ ទី១ ជំពូកទី១៧ ខ្ញុំចង់អានខទាំងប្រាំពីរដែលនៅដំបូងគេ តាមព្រះហឫទ័យព្រះ។

*គ្រានោះ អេលីយ៉ា ជាអ្នកស្រុកធេសប៊ី ដែលនៅជាមួយនឹងពួកស្រុកកាឡាត លោកទូលនឹងអ័ហាប់ថា ទូលបង្គំស្បថ ដោយនូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលដ៏មានព្រះជន្មរស់ ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា ក្នុងប៉ុន្មានឆ្នាំទៅមុខនេះនឹងគ្មានភ្លៀង គ្មានសន្សើមឡើយ វៀរតែដោយសារពាក្យទូលបង្គំប៉ុណ្ណោះ*

*រួចព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកបង្គាប់លោកថា ៣ ចូរចេញពីទីនេះបែរទៅខាងកើត ហើយពួនខ្លួននៅឯជ្រោះកេរីត ដែលនៅប្រទល់មុខនឹងទន្លេយ័រដាន់ទៅ*

*ឯងនឹងផឹកទឹកជ្រោះនោះ ហើយអញបានបង្គាប់ឲ្យក្អែកចិញ្ចឹមឯងនៅទីនោះដែរ។*

សម្គាល់ត្រង់ចំណុចនេះ "ចិញ្ចឹមឯងនៅទីនោះ" មិនមែនទីណាផ្សេងទេ។ "ទីនោះ!"

*ដូច្នេះ លោកក៏ធ្វើតាមព្រះបន្ទូលនៃ***ព្រះយេហូវ៉ា** *គឺទៅអាស្រ័យនៅក្បែរជ្រោះកេរីត ដែលនៅប្រទល់មុខទន្លេយ័រដាន់។*

*ហើយរាល់ព្រឹករាល់ល្ងាច ក្អែកតែងពាំនំប៉័ង និងសាច់មកជូនលោក លោកក៏ផឹកទឹកពីជ្រោះនោះ។*

*លុះកន្លងយូរបន្តិចមក ទឹកជ្រោះក៏រីងទៅ ពីព្រោះមិនមានភ្លៀងធ្លាក់នៅស្រុកនោះសោះ។*

13 សូមព្រះបន្ថែមព្រះពរទ្រង់ដល់អ្នកដែលអានព្រះបន្ទូលរបស់ទ្រង់។ ហើយឥឡូវយប់នេះ ខ្ញុំចង់ដកស្រង់អត្ថបទត្រង់ចំណុចនេះ ដោយដាក់ចំណងជើងថា "អាហារផ្នែកវិញ្ញាណ តាមរដូវកាលរបស់វា។" ព្រឹកនេះយើងមាន—មេរៀនដែលថា—ដែលហៅថា "ការធ្វើកម្មវិធីថ្វាយបង្គំ ឬក៏ព្យាយាមធ្វើពិធីថ្វាយបង្គំដោយគ្មាន...ដោយមិនគិតពីពេលណា រដូវកាលអ្វី កន្លែងណា ឬក៏បុគ្គលណា។" ហើយឥឡូវនេះគឺ *អាហារផ្នែកវិញ្ញាណតាមរដូវកាលដ៏ ស័ក្តសម។*

14 ហោរាអេលីយ៉ារូបនេះ យើងស្គាល់ពីគាត់បន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែយើងដឹងថា គាត់គឺជាអ្នកបម្រើរបស់ព្រះ ហើយជាអ្នកបម្រើរបស់ទ្រង់ក្នុងសម័យកាលនោះ។

15 ហើយព្រះបានប្រើព្រះវិញ្ញាណទ្រង់ ដែលសណ្ឋិតក្នុងអេលីយ៉ា រួចមកហើយចំនួនបីដង ព្រមទាំងសន្យាថានឹងមានពីរដងបន្ថែមទៀត សរុបគឺប្រាំដង សម្រាប់ព្រះគុណ។ ទ្រង់ប្រើវាទៅលើអេលីយ៉ា វាបានមកលើអេលីសេផ្ទួនៗ គឺនៅលើយ៉ូហានបាបទីស ដែលត្រូវមកផ្សព្វផ្សាយដល់សាសន៍ដទៃ ហើយជាមួយលោកម៉ូសេ ដើម្បីនាំជនជាតិយូដាត្រឡប់មកទឹកដីខ្លួនវិញ។ ពិតហើយ។ គឺប្រាំដងដែលព្រះសន្យាថានឹងប្រើវិញ្ញាណរបស់លោកអេលីយ៉ា ហើយបានសម្រេចបីដងរួចមកហើយ។

16 ឥឡូវហោរាធំរូបនេះ យើងមិនដឹងថាតើគាត់មកពីណាទេ។ យើងដឹងថាគាត់មកពីធេសប៊ី(Tishbite)។ ប៉ុន្តែតើគាត់មកដោយរបៀបណា...

17 យើងដឹងតិចតួចអំពីហោរា។ យើងមិនដឹងថាពួកគេមកពីកន្លែងណា។ គឺកម្រមាន...ដូចជា ខ្ញុំមិនដឹងថាមាននរណាមួយដែលចេញមកពីព្រះវិហារ ឬក៏ចេញពីពង្សាវតាអ្វីនៅខាងក្រោយពួកគេទ។ គឺគ្រាន់តែជាមនុស្សធម្មតា ដែលគ្មាន

ការភ័យខ្លាច ហើយភាគច្រើនមិនបានទទួលការសិក្សា។ ហើយពួកគេមិនដែលសរសេរអ្វី ពីខ្លួនពួកគេទេ។ អេសាយនិងយេរេមា ពួកគេទាំងពីរ បានសរសេរខ្លះ ប៉ុន្តែហោរាធំរូបនេះ មិនដែលសរសេរអ្វីមួយឡើយ។ មានច្រើនណាស់ក្នុងចំណោមពួកគេមិនបានសរសេរ ប្រហែលជាពួកគេមិនអាចសរសេរបាន។ ប៉ុន្តែពួកគេគឺជាមនុស្សដែលខ្លាំងក្លា។ គឺគ្មានមនុស្សណាក្នុងព្រះគម្ពីរ ដូចជាពួកហោរាចាស់ នោះឡើយ។ ពួកគេព្រមានដល់នគរស្តេច មនុស្ស ក្រុមជំនុំ និងអ្វីផ្សេងទៀត ហើយឈរមាំក្នុងព្រះបន្ទូលរបស់ព្រះ ហើយព្រះអះអាងថា ពួកគេជាមនុស្សសុចរិត។ ពួកគេខ្លាំងក្លាមែនទែន ក្នុងបុគ្គលិកលក្ខណៈ។

18 ហើយហោរាអេលីយ៉ារូបនេះគឺជាមនុស្សខ្លាំងក្លាជាងគេ ក្នុងចំណោមពួកគេ។ គាត់គឺជាមនុស្សនៃវាលរហោស្ថាន។ គាត់ចេញពីវាលរហោស្ថាន គាត់រស់នៅក្នុងទីរហោស្ថាន។ ព្រះគម្ពីរបានប្រាប់ថា គាត់ស្លៀករោមចៀម។ គាត់មានស្បែកសត្វចៀមរុំជុំវិញខ្លួនគាត់ ហើយបំណែកនៃស្បែកសត្វ ស្បែកសត្វអូដ្ឋរុំនៅចង្កេះមាន...ពុកមាត់នៅលើផ្ទៃមុខរបស់គាត់ ខ្ញុំបានគិតស្រមៃថា គាត់គឺជាមនុស្សដែលមើលទៅខ្លាំងក្លាមែនទែន បើតាមមើល។

19 ប៉ុន្តែយើងកុំ...ពួកគេទាំងនោះនៅមិនទាន់ស្លាប់ទាំងអស់ទេ។ ពួកគេមិនមែនទាំងអស់—គឺមិនស្លាប់ទាំងអស់ទេ។ នៅក្នុងសម័យកាល នៃ*ក្រុមប្រឹក្សានីសិន(Nicene Council)* ក្នុងចំណោមអ្នក បើមាននរណាបានអានពី *ក្រុមប្រឹក្សានីសិននៅសម័យកាលព្រះវិហារដំបូង (The Nicene Council of the Early Church)* នៅពេលដែលពួកគេចង់បង្កើតអង្គការចេញពីវា ហើយបានបំបែកក្រុមជំនុំផ្សេងៗ ឲ្យរួមមកតែមួយ នៅពេលដែលគេប្រជុំដើម្បីប្រឹក្សានោះ មនុស្សខ្លាំងក្លាដូចជាអេលីសេចេញពីទីរហោស្ថាន ដោយបរិភោគតែរុក្ខជាតិ គឺជាមនុស្សដ៏ខ្លាំងក្លា។ ប៉ុន្តែអ្នកដែលមានយសស័ក្ត ដែលមានអំណាចខ្ពង់ខ្ពស់ ដែលនៅក្រោមខនស្ទែនធីន(Constantine)ជាដើម បានស្ទាត់សម្លេងរបស់ពួកគេ។ ពីព្រោះពួកគេគឺជាហោរា ដែលដឹងថាគ្រាប់ពូជពោតនិងស្រូវសាលី នៃក្រុមជំនុំខាងកូនក្រមុំត្រូវតែធ្លាក់ទៅលើដី ដូចគ្នាទៅនិងគ្រាប់ពូជពោតនិងស្រូវសាលី នៃក្រុមជំនុំរបស់កូនលោះដែរ។ ហើយត្រង់ចំណុចនោះ វាបានអូសបណ្តោយរាប់ពាន់ឆ្នាំ។

20 ដូច្នេះហើយទើបពួកគេបានសរសេរក្នុងសៀវភៅមួយ សព្វថ្ងៃនេះ "តើព្រះដ៏ស្ងប់ស្ងាត់ដែលអាចក្រោកឈរនិងទតមើលនោះ ឃើញក្មេងតូចៗត្រូវគេសម្លាប់ ពួកស្ត្រីត្រូវបានហែកជាចំណែកៗដោយហ្វូងសត្វតោ តែទ្រង់អង្គុយនៅឋានសួគ៌ដោយគ្មានបន្ទូលអ្វីយ៉ាងដូច្នេះ?" ពួកគេមិនយល់ព្រះបន្ទូល។ គ្រាប់ពូជពោតនិងស្រូវសាលី ត្រូវធ្លាក់មកឯផែនដីឯណេះ។ តើព្រះដ៏សុចរិតអាចឈរ ទតមើលបុត្រាទ្រង់ត្រូវសុគត ត្រូវគេស្តោះដាក់និងអ្វីផ្សេងទៀតដោយរបៀបណា? ប៉ុន្តែវាគឺជាព្រះបន្ទូលដែលត្រូវតែសម្រេច។ នោះហើយគឺជាផ្លូវ រហូតមកដល់បច្ចុប្បន្ននេះ។

21 បុរសម្នាក់នេះ គាត់គឺជាមនុស្សអស្ចារ្យ។ គាត់មានពូជពង្សដែលពេញដោយអំពើបាប។ អ័ហាប់បានធ្វើជាស្តេចតពីបិតា ដែលសោយរាជ្យមុន ក៏បានប្រព្រឹត្តអាក្រក់។ លើសជាងជំនាន់ហ្លួងសាឡូម៉ូនគឺស្តេចបានប្រព្រឹត្តអាក្រក់ពីមួយជំនាន់ទៅមួយជំនាន់។ ហើយអ័ហាប់ម្នាក់នេះ គឺជាអ្នកដែលសោយរាជ្យម្ភៃពីរឆ្នាំក្នុងក្រុងសាម៉ារី ជាស្តេចដែលប្រព្រឹត្តអាក្រក់ជាងគេបំផុត។ គាត់គឺជាអ្នកសម័យនិយមពិតប្រាកដ។ គាត់ជឿស៊ុបលើសាសនា។ ហើយគាត់មានអ្វីគ្រប់យ៉ាងនៅក្នុងនិន្នាការសម័យទំនើប។ គាត់មានហោរាសាសន៍ហេព្រើរបួនរយនាក់ ហើយពួកគេទាំងអស់នោះគឺបានទទួលការបណ្តុះបណ្តាលនិងណែនាំបានល្អណាស់។ ព្រះជាម្ចាស់បានបញ្ជូនហោរាម្នាក់ទៅឲ្យគាត់ដែរតែគាត់មិនព្រមជឿទេហើយហោរានោះគឺជាលោកអេលីយ៉ា។

22 ប៉ុន្តែលោកអេលីយ៉ា អ្នកស្រុកធេសប៊ីនេះ គឺជាបុរសនៃវាលរហោស្ថាន។ មិនមែនជាអ្នកស្រណុក គាត់ជាបុរសម្នាក់ដែលរឹងមាំ។ ហើយនៅថ្ងៃមួយក្រោយពីព្រះបាទអ័ហាប់ បានប្រព្រឹត្តអំពើបាប រហូតដល់ព្រះមិនអាចទតមើលបានទៀត ទ្រង់ក៏មានបន្ទូលទៅកាន់លោកអេលីយ៉ា នៅវាលរហោស្ថាន។ ហើយនៅទីនេះគាត់បានចុះតាមផ្លូវទៅស្រុកសាម៉ារី ដូចខ្ញុំជាញឹកញាប់បានបង្ហាញប្រហែលជាគាត់មានពុកមាត់ជាច្រើន ដុះចេញនៅជុំវិញមុខរបស់គាត់ ក្បាលដែលទំពែកភ្លឺចាំងដោយព្រះអាទិត្យ មានភ្នែកតូចៗ ត្រឡប់មកវិញដោយមានដំបងនៅក្នុងដៃរបស់គាត់ មានស្នាមញញឹមលើផ្ទៃមុខក៏ដើរឡើងទៅគាល់ស្តេចអ៊ីស្រាអែល ហើយបាននិយាយថា"...នឹងគ្មានសូម្បីតែទឹកសន្សើមរហូតដល់ខ្ញុំហៅវាឲ្យធ្លាក់ចុះមក។"

23 ព្រះបានបញ្ជូនមនុស្សបែបនេះដល់យើង យើញទេ មនុស្សដែលដឹងពីកិច្ចការដែលពួកគេត្រូវធ្វើជាមួយ **ព្រះបន្ទូលរបស់ព្រះអម្ចាស់**។

24 ឥឡូវនេះ យើងរកឃើញថា មុនពេលដែលគាត់បានធ្វើការនេះ គឺព្រះបានត្រាស់ហៅគាត់។ ព្រះបានមានបន្ទូលទៅកាន់គាត់ ដូច្នេះហើយ គាត់មិនខ្លាចអ្វីទាំងអស់។ គាត់មិនភ័យខ្លាចពីសារនោះ ថាវានឹងមិនកើតឡើងឬទេ ពីព្រោះគាត់បានដឹងថា វានឹងកើតឡើងមែន! គាត់បានដឹងថាវាគឺយោងតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយគាត់ដឹងថាគាត់គឺជាហោរារបស់ព្រះ សម្រាប់សម័យនោះ។ ហេតុនេះហើយ ទោះបីស្តេចនឹងកាត់ក្បាលរបស់គាត់ ឬបោះគាត់ចូលទៅក្នុងគុក ឬអ្វីផ្សេងទៀតដែលពួកគេចង់ធ្វើ វាគ្មានអ្វីខុសគ្នាទេចំពោះគាត់ ព្រោះគាត់មានបេសកកម្មរបស់គាត់គឺ "**ព្រះបន្ទូលរបស់ព្រះអម្ចាស់**" នៅចំពោះមុខស្តេច។ តើជាមនុស្សរឹងមាំប៉ុណ្ណា! ប៉ុន្តែមុនពេលដែលគាត់បានធ្វើការទាយថា នឹងមានគ្រោះរាំងស្ងួត...

25 ដ្បិតព្រះជាម្ចាស់នឹងមិនអនុញ្ញាតឲ្យអំពើបាបរួចខ្លួនឡើយ។ ត្រូវតែមានការដាក់ទោស។ បើមានច្បាប់ដែលគ្មាន—គ្មានការដាក់ទោស នោះតើមានអ្វីល្អ? ធ្វើម៉េចឲ្យអ្នកដែលប្រព្រឹត្តល្អបាននិយាយថា "វាជាការប្រឆាំងនឹងច្បាប់ ដែលបើកភ្លើង" ហើយគ្មានការពិន័យនៅពីក្រោយវាទេ ឬគ្មានការដាក់ទោសនៅពីក្រោយវា? វានឹងមិនមែនជាច្បាប់ទេ។ ដូច្នេះនឹងមានការដាក់ទណ្ឌកម្ម ចំពោះអំពើបាប។ ហើយនៅពេលដែលព្រះបានបង្កើតច្បាប់ ហើយច្បាប់—ច្បាប់ត្រូវតែពិន័យបន្ទាប់មកច្បាស់ជាមានការដាក់ទោសសម្រាប់ការនោះ។

26 ហើយប្រទេសនេះ បានរំលោភបំពាន នូវអស់ទាំងក្រឹត្យវិន័យរបស់ទ្រង់។ អូពួកគេមានព្រះវិហារធំ ពួកគេមានក្រុមជំនុំ។ ពួកគេមានមនុស្ស ដែលមានការអប់រំជាច្រើននាក់។ ពួកគេមានហោរានៅទូទាំងប្រទេស មានសាលារៀនរបស់ពួកគេ ដែលឲ្យពួកគេងាកចេញដូចជាម៉ាស៊ីន។ ហើយពួកគេមានហោរា ជាច្រើននាក់ ពួកគេមាន—មានបូជាចារ្យរបស់ពួកគេ ក៏មានអាចារ្យនិងពួកកាន់សាសនាជាច្រើនប៉ុន្តែពួកគេនៅឆ្ងាយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដូច្នេះព្រះបានហៅបុរសម្នាក់ដែលក្រៅពីជួររបស់ពួកគេ ហើយបញ្ជូនគាត់ជាមួយនឹង **ព្រះបន្ទូលរបស់ព្រះអម្ចាស់**។

27 ហើយកត់សម្គាល់ ពីរបៀបដែលទ្រង់យកចិត្តទុកដាក់ ចំពោះរាស្ត្រទ្រង់។ មុនពេលដែលទ្រង់បញ្ជូនហោរារូបនេះជាមួយនិងសារទ្រង់មានបន្ទូលថា"អេលីយ៉ា ចូរចុះទៅប្រាប់អ័ហាប់ពីការទាំងនេះ។ ហើយឥឡូវនេះនៅពេល ដែលអ្នកបានប្រាប់ហើយ ចូរចេញពីស្ដេចឲ្យបានឆាប់រហ័ស ពីព្រោះអញបានធ្វើកន្លែងសម្រាប់ឯង ក្នុងអំឡុងពេលគ្រោះរាំងស្ងួតនោះ។ អញនឹងចិញ្ចឹមឯង អេលីយ៉ាបើឯងថ្លែងព្រះបន្ទូលអញ ចូរថ្លែងតែអ្វីដែលអញប្រាប់ឯងប៉ុណ្ណោះ។"

28 ឥឡូវនេះខ្ញុំនឹងនាំយកបេសកកម្មដ៏អស្ចារ្យនេះ សម្រាប់យប់នេះ ពីលោកអេលីយ៉ានិងសម័យរបស់លោកអេលីយ៉ា ជាមួយពេលវេលាដែលយើងឥឡូវនេះកំពុងរស់នៅ។ ខ្ញុំជឿថា វាជាបេសកកម្មដ៏ល្អឥតខ្ចោះ។ ខ្ញុំគិតពីជាតិសាសន៍នេះ... ប្រសិនបើខ្ញុំ...យើងមានពេលវេលាដើម្បីវិលត្រឡប់ទៅវិញ ប៉ុន្តែខ្ញុំចង់ដាក់ពេលពេលវេលាឲ្យបានច្រើនក្នុងជួរនៃការអធិស្ឋាន។

29 ដូច្នេះប្រសិនបើ យើងអាចត្រឡប់ទៅក្រោយវិញ ហើយឃើញអ៊ីស្រាអែលបានយកប៉ាឡេស្ទីនលើមូលដ្ឋានដូចគ្នាដែលយើងបានយកសហរដ្ឋអាមេរិកនេះ។ យើងចូលមកក្នុងសហរដ្ឋអាមេរិកនេះ ហើយបានត្រឡប់មកកាន់កាប់ ជនជាតិឥណ្ឌា ហើយបានចាប់យកទឹកដីនោះ។ ដូច្នេះហើយ អ៊ីស្រាអែលក៏ចូលមកក្នុងប៉ាឡេស្ទីន ក្រោមការដឹកនាំរបស់លោកយ៉ូស្វេ ក្រោមការដឹកនាំរបស់ព្រះ ហើយបានត្រឡប់មកវិញនិងបានកាន់កាប់យកទឹកដីនោះ។

30 ហើយស្ដេចដំបូងរបស់ពួកគេជាបុរសខ្លាំងពូកែម្នាក់គឺស្ដេចដាវីឌ សាឡូម៉ូននិងមនុស្សអស្ចារ្យផ្សេងជាច្រើននាក់ទៀត។ ប្រធានាធិបតីដំបូងរបស់យើងគឺជាមនុស្សខ្លាំងក្លាមានអំណាច គឺលោកវ៉ាស៊ីនតោន(Washington) លីនខុន(Lincoln) ជាដើម។ បន្ទាប់មក នៅទីបំផុតប្រធានាធិបតីឬស្ដេច បានក្លាយទៅជាពុករលួយ គ្រប់ពេលវេលា ហើយទីបំផុតពួកគេបានបញ្ចប់ដូចជាអ័ហាប់នេះ។ ជាក់ស្ដែងណាស់តួយ៉ាង នៅសម័យរបស់យើង។ មនុស្សដើរក្នុងសម័យទំនើបណាស់ ពួកគេមិនចង់ស្ដាប់ព្រះបន្ទូលពិត របស់ព្រះជាម្ចាស់ទេ។

31 ហើយអ្នកអាចស្រមៃមើល ទៅលើមនុស្សសម័យទំនើបបែបនេះ តើអ្នកបម្រើព្រះពិតប្រាកដ នឹងស្ដាប់ទៅដូចជាអ្វីសម្រាប់ពួកគេ។ "ហេតុអ្វី គាត់គឺជាមនុស្សឆ្កួត គាត់បាត់បង់សតិស្មារតី។ មិនអាចមានរឿងបែបនេះទេ។" ពួកគេជាអ្នកកាន់សាសនា កាន់សាសនាស៊ុបខ្លាំងណាស់។ ពួកគេមានមនុស្សដែលមាន

ចិត្តស្មោះ។ ពួកគេមានប្រជារាស្ត្រដែលស្មោះត្រង់។ គឺជាអ្នកកាន់សាសនាយ៉ាងល្អឥតខ្ចោះខ្លាំងណាស់។

32 ដូច្នេះគាត់បានដឹងថា វាត្រូវការយកលើសជាងទេវកសាស្ត្រធម្មតា វានឹងត្រូវយកលើជាង—ច្រើនជាងរាជសារធម្មតាណាមួយវានឹងច្រើនជាងការអធិប្បាយព្រះបន្ទូលដើម្បី បំបែកចិត្តថ្មរបស់ពួកគេ។ លោកបានដឹងថាត្រូវតែនាំយក**ព្រះបន្ទូលរបស់ព្រះអម្ចាស់** ដើម្បីបញ្ជូនការជំនុំជំរះ មកលើមនុស្សបែបនោះ ដូច្នេះគាត់បានដឹងថានៅពេលដែលគាត់បានចេញទៅជាមួយ**ព្រះបន្ទូលរបស់ព្រះអម្ចាស់**។ ហើយបើ **ព្រះបន្ទូលរបស់ព្រះអម្ចាស់**។ ត្រូវតែបំបែកការនោះនិងមានការជំនុំជំរះ។ យើងឃើញថានៅក្នុងជំនាន់យើងដូចគ្នា។ យើងឃើញការនេះរាល់ថ្ងៃ។ គ្មានអ្វីដែលសេសសល់ទេ មានតែការជំនុំជំរះ ជាពេលដែលអ្នកឈានជើងនៅលើបន្ទាត់នៃសេចក្តីមេត្តាករុណា។

33 ឥឡូវនេះ ហេតុការណ៍នោះ ខ្ញុំនឹងទាញយកអេលីយ៉ាជាមួយនឹងក្រុមជំនុំសព្វថ្ងៃនេះ។ នៅមុនពេលការជំនុំជំរះ គាត់បានទទួលដំណឹងនេះ។ អេលីយ៉ាគាត់ជាអ្នកតំណាង ត្រូវបានមើលថៃយ៉ាងយកចិត្តទុកដាក់ ពីធម្មជាតិ អាហារធម្មជាតិរបស់គាត់ ដោយសារតែឥឡូវនេះ មិនមានភ្លៀងធ្លាក់ បើយោងតាមព្រះបន្ទូលរបស់ព្រះ គឺរយៈពេលបីឆ្នាំប្រាំមួយខែ ឬរហូតទាល់តែដល់លោកអេលីយ៉ាហៅ។ "ពេលណាដែលអ្នកនិយាយ អេលីយ៉ា នោះវានឹងត្រូវកើតឡើង។" ដូច្នេះហើយគាត់បានដើរឡើងទៅគាល់ស្តេចនិងបាននិយាយថា "សូម្បីតែទឹកសន្សើមក៏មិនធ្លាក់ចុះមកដែរ រហូតដល់ខ្ញុំហៅវា។" នោះគឺពិតណាត់—ជាបន្ទុកមួយ មែនឬមិនមែន? នោះជាការពិតជាដំណឹងមួយ!

34 ឥឡូវនេះ យើងនឹងទាញយកហេតុការណ៍នោះ ជាមួយគ្រោះរាំងស្ងួតខាងវិញ្ញាណ នាពេលបច្ចុប្បន្ននេះ។ ឥឡូវនេះ យើងទាំងអស់គ្នាបានដឹងហើយ យើងមានការយល់ដឹងមែនទែន ថាមានគ្រោះរាំងស្ងួតខាងវិញ្ញាណ នៅក្នុងស្រុកនាពេលបច្ចុប្បន្ននេះ និយាយខាងវិញ្ញាណ។ ហើយអ្នកដឹងថា វាបានចែងទុករួចហើយដោយសាពួកហោរា គឺគ្រាន់តែមុនការយាងមកជាលើកទីពីរបស់ព្រះគ្រីស្ទ ដែលនិយាយថា "នឹងមានគ្រោះរាំងស្ងួតនៅក្នុងស្រុក ដ្បិតមនុស្សមិនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រាប់ឮព្រះបន្ទូលរបស់ព្រះវិញ។" ហើយថ្ងៃនោះគឺជាពេលបច្ចុប្បន្ននេះឯង "ឮព្រះបន្ទូលពិតរបស់ព្រះ។"

ឥឡូវនេះ ហេតុការណ៍នោះ គឺជាគ្រោះរាំងស្ងួតធម្មជាតិជាមួយនិង គ្រោះរាំងស្ងួតខាងវិញ្ញាណ។

35 អំពើបាបនិងការមិនជឿ ដោយគ្រូបង្រៀនខុសឆ្គង និងអ្នកសម័យនិយមនៅក្នុងព្រះវិហារ បាននាំយកការកាត់ទោស មកដល់។ បន្ទាប់មកពួកគេបានបែចេញពីព្រះបន្ទូលរបស់ព្រះនិងហោរារបស់ទ្រង់ ទៅខាងទ្រឹស្តីទំនើបនៃពាក្យ។

36 អ្នកសម្គាល់ឃើញនៅទីនេះ នៅពេលនោះ ដែលព្រះជាម្ចាស់តែងតែលើកឡើងនូវអ្វីមួយ។ គោលបំណង ទ្រង់តែងតែ ទ្រង់នឹងមិនធ្វើអ្វីសោះរហូតទាល់តែបានលេចមកឯរាស្ត្ររបស់ទ្រង់ជាមុន ហើយទ្រង់តែងតែបង្ហាញវាតាមរយៈអ្នកបម្រើរបស់ទ្រង់។

37 ឥឡូវនេះ ប៉ុន្តែលោកអេលីយ៉ាក្នុងអំឡុងពេលនេះ មានកន្លែងសម្ងាត់ដែលព្រះបានតែងតាំងឡើងសម្រាប់ឲ្យគាត់ទៅ។ នោះហើយជាអ្វីដែលយើងចង់ឃើញនៅពេលនេះ មុនពេលដែលយើង មានបន្ទាត់នៃសេចក្តីអធិស្ឋាន។ អេលីយ៉ាមានកន្លែងសម្ងាត់មួយ ដែលព្រះជាម្ចាស់ផ្ទាល់បានផ្តល់ឲ្យ។ ឥឡូវ ក្រុមជំនុំមិនដែលបានផ្តល់វាសម្រាប់គាត់ទេ គាត់ក៏មិនបានផ្គត់ផ្គង់ខ្លួនឯងដែរ តែព្រះបានផ្តល់ទីសម្ងាត់មួយកន្លែងសម្រាប់អេលីយ៉ា ដែលមានរបស់ហូបចុកគ្រប់ពេលវេលាក្នុង អំឡុងពេលគ្រោះរាំងស្ងួត ដែលជាកន្លែងដែលគាត់មានអាហារ ហូបចុកជារៀងរាល់ថ្ងៃ។ គាត់មិនត្រូវការបារម្ភថា តើនឹងមានអ្វីកើតឡើងនៅថ្ងៃស្អែក ឬភ័យខ្លាច បាត់បង់ការនោះឡើយ។ ព្រះបានមានបន្ទូលថា "អញបានបង្គាប់សត្វក្អែកឲ្យពួក វាចិញ្ចឹមឯង។" វាជារឿងអស្ចារ្យណាស់ កន្លែងសម្ងាត់របស់យើងគឺក្នុងព្រះគ្រីស្ទ។

38 នៅពេលដែលក្រុមប្រឹក្សាពិភពលោក និងអ្វីផ្សេងទៀតដែលបានកើតឡើងនាពេលបច្ចុប្បន្ននេះ បាននិយាយ "ថ្ងៃនៃការអស្ចារ្យនេះគឺកន្លងផុតហើយ។" អំណាចដ៏អស្ចារ្យនៃព្រះ ត្រូវបានដកចេញពីក្រុមជំនុំ។ វាហាក់បីដូចជា ពួកគេមិនមាន អ្វីសោះប៉ុន្តែ "ដូចជាលង្ហិននិងស្គរដែលឮខ្ទរ។" "យើងដឹងថាវាជាការពិត។ ហើយ ធ្វើទម្រង់បែបនៃព្រះ ព្រមទាំងបដិសេធអំណាចនោះ។"

39 វាគ្រាន់តែជារឿងដដែល ដែលដាវីឌបានធ្វើនៅព្រឹកនេះ ជាមួយរទេះគោហើយបានចាកឆ្ងាយពីព្រះបន្ទូលព្រះ។ នៅពេលដែលព្រះបន្ទូល ត្រូវបានបើក

សម្លេង និងប្រទានទៅពួកគេ ពួកគេមិនចង់បានវាទេ ដូច្នេះហើយរទើបពួកគេបាន នៅឆ្ងាយពីវា។

40 នោះគឺជាអ្វីដែលមនុស្សទាំងនោះបានធ្វើនៅក្នុងសម័យហោរាអេលីយ៉ា ដែលបានចាកឆ្ងាយពីព្រះបន្ទូលព្រះ។ ពួកគេបានគិតថាពួកគេមាន ព្រះបន្ទូលនោះ ប៉ុន្តែពួកគេមិនបានមានវាទេ។ ដូច្នេះយើងសម្គាល់ឃើញបន្ទាប់មក នៅក្នុង...

41 ក្នុងអំឡុងពេល ដែលទ្រង់នឹងដាក់ទោសអ្នកមិនជឿនេះ ទ្រង់បានរៀបចំផ្លូវសម្រាប់អ្នកជឿរួចហើយ។ រឿងដូចគ្នានេះដែរ ទ្រង់តែងតែធ្វើរាល់ពេល។ ក្នុងថ្ងៃដែលទ្រង់នឹងបំផ្លាញពិភពលោកដោយទឹក ទ្រង់បានរៀបចំផ្លូវមួយសម្រាប់លោកណូអេដើម្បីចាកចេញ។ ក្នុងថ្ងៃដែលទ្រង់ធ្វើឲ្យពួកអេស៊ីបលង់ទឹក ទ្រង់បានរៀបចំញែកសមុទ្រសម្រាប់ប្រជាជនរបស់ទ្រង់។ តើព្រះបានរៀបចំផ្លូវរបស់ទ្រង់របៀបណា! ហើយកន្លែងដែលមិនមានផ្លូវ នោះទ្រង់គឺជាផ្លូវ។ ទ្រង់គឺជាផ្លូវនោះឯង!

42 ឥឡូវនេះ យើងដឹងថាយើងកំពុងប្រឈមមុខ និង...សម័យកាលដ៏ធំមួយដែលប្រវត្តិសាស្រ្តមិនបានធ្លាប់ដឹង។ វាមិនមែនជាក្បាលគ្រាប់ភ្លើ ចាំងនៃមីស៊ីលដែលមានក្បាលនៅលើវា ថាយើងគួរតែមានការភ័យខ្លាចទេ។ វាគឺជាក្រុមជំនុំដែលយើងគួតែភ័យបារម្ភ។ វាគឺជាពេលវេលាដែលយើងកំពុងរស់នៅដែលយើងគួរតែសម្លឹងមើល។

43 ឥឡូវនេះសូមកត់សម្គាល់ តែព្រះបានរៀបផ្លូវសម្រាប់លោកអេលីយ៉ា ដើម្បីគេចផុតពីវា។ ហើយទ្រង់បានរៀបផ្លូវសម្រាប់កូនណាដែលជឿ ដើម្បីគេចផុតពីសេចក្តីក្រោធរបស់ទ្រង់ និងអ្វីដែលនឹងត្រូវមកផងដែរ។

44 ដោយព្រោះព្រះទ្រង់មិនអាចគ្រាន់តែ ដើម្បីជំនុំជំរះមនុស្សទាំងនោះ ហើយបញ្ជូនការផ្តន្ទាទោស ហើយពន្លិចក្រុងសូដុមនិងកូម៉ូរ៉ា ព្រមទាំងក្រុងកាពើណិមនៅកណ្តាលសមុទ្រ ហើយថ្កោលទោសជំនាន់ទាំងនោះ ដូចក្រុងសូដុមនិងក្រុងកូម៉ូរ៉ាបន្ទាប់មក ឲ្យយើងធ្វើជួបរឿងរាវដូចគ្នាដែរជាមួយវា។ យើងគ្រាន់តែប្រាកដថានឹងមានការជំនុំជំរះ ដូចដែលពួកគេត្រូវតែ ទទួលការជំនុំជំរះនោះយ៉ាងពិតប្រាកដ។ ឥឡូវនេះយើងបានកត់សម្គាល់ឃើញថា...

45 នៅពេលដែលរឿងទាំងនេះកើតឡើង ដែលជានិន្នាការសម័យទំនើបថ្ងៃនោះ ព្រះបានលើកបុរសម្នាក់ឡើង នៅក្នុងថ្ងៃនោះ ឬ ចិញ្ចឹមបុរសម្នាក់ជាជាង ប្រយុទ្ធប្រឆាំងនឹងកងកម្លាំងនេះ ហើយពួកគេមិនបានស្តាប់គាត់ទេ។ ពួកគេបានគិតថាគាត់គឺជាមនុស្សឆ្កួត "គាត់បានបាត់បង់សតិស្មារតីរបស់គាត់។ គាត់គឺគ្រាន់តែជាអ្នកបុរាណនិយម ល្ងីល្ងើចេញពីវាលរហោស្ថានមក ហាក់បីដូចជាសត្វព្រៃដែលឆ្កួត" ប៉ុន្តែគាត់មានព្រះបន្ទូលរបស់ព្រះអម្ចាស់។

46 "ព្រះបន្ទូលមិនមានន័យថាជាអ្វីដែលបាននិយាយទេ" ពួកគេនិយាយនៅថ្ងៃនេះ។ "អីយ៉ាប្រសើរមែន ព្រះគម្ពីរជាសៀវភៅប្រវត្តិសាស្ត្រមួយ។" ខ្ញុំគិតថាអ្នកបានឃើញការនេះ ថាឥឡូវនេះពួកគេបានអះអាងដូច្នេះ "អេវ៉ាមិនបានបរិភោគផ្លែប៉ោមនោះទេ នាងបានបរិភោគ..." តើជាអ្វីទៅ? ខ្ញុំជឿថា..."វាគឺជាសណ្តែកបាយ" ពួកគេបាននិយាយអញ្ចឹងឥឡូវនេះ។ "វាគឺជាសណ្តែកបាយ" ហើយបន្ទាប់មក ថា "លោកម៉ូសេមិនបាននាំមនុស្សដើរឆ្លងសមុទ្រក្រហមទេ។ វាមានចង្កោមមែកនៃដើមត្រែងយ៉ាងធំទោរមកដល់ទីនោះ ដល់ចុងម្ខាងនៃសមុទ្រ ហើយគាត់បានឆ្លងទៅកាត់សមុទ្រតាមគុម្ពត្រែងមួយនោះ។" អញ្ចឹងចុះជញ្ជាំងទឹក—ជញ្ជាំងទឹកដែលឈរសងខាង ដែលពួកគេបានដើរលើដីស្ងួតនោះ បន្ទាប់មកយ៉ាងម៉េច? អីយ៉ាផ្តេសផ្តាស់មែន! ប៉ុន្តែ អ្នកឃើញទេ វាត្រូវការហេតុការណ៍ដូចថ្ងៃមួយនោះដើម្បីនាំយកនូវសេចក្តីក្រោធរបស់ព្រះ ចុះមកលើប្រជាជន។ វាបានធ្វើដូច្នេះ។

47 ពួកគេបាននិយាយថា មិនមានរឿងបែបនេះដូចជា—ដូចជាបែបនេះ... សូម្បីតែមនុស្ស ដែលនៅក្នុងព្រះវិហារក៏មិនជឿលើការអស្ចារ្យដែរ។ "ខ្ញុំនឹងឲ្យអ្នកមួយពាន់ដុល្លារ" ពួកគេនិយាយ "ចូរធ្វើការអស្ចារ្យឲ្យខ្ញុំមើលផង។ បង្ហាញការអស្ចារ្យឲ្យខ្ញុំមើលមក!" មែនហើយ ពួកគេមិនអាចឃើញវាទេ ទោះបីមានការអស្ចារ្យមួយម៉ឺនដងបានធ្វើរួចហើយ នៅមុខពួកគេក៏ដោយ។ ហេតុអ្វីពួកគេ—ពួកគេ នឹងមិនឃើញវាដូច្នេះ។

អ្នកនិយាយថា "នេះជាការមិនអាចទៅរួចនោះទេ។" អូទេ វាគឺមិនមែនទេ។

48 មានពេលមួយ អេលីយ៉ាគាត់ចុះទៅក្រុងដូថាន់ ហើយកងទ័ពស៊ីរីបានមកហ៊ុំព័ទ្ធទីក្រុងនេះ ដើម្បីចាប់គាត់ពីព្រោះគេបានដឹងថា នោះជាកន្លែងដែល—ដែលអំណាចរបស់ទីក្រុងបានតាំងនៅ គឺនៅលើអ្នកមើលឆុត។ ហេតុអ្វី ស្តេច...បុរសម្នាក់ក្នុងចំណោមមនុស្សរបស់ស្តេច បានទូលប្រាប់ស្តេចរបស់ប្រទេសស៊ីរី ដោយ

និយាយថា "ហេតុអ្វីបានជាទ្រង់ព្រះករុណា ស្គាល់អេលីយ៉ាជាអ្នកស្រុកធេសប៊ី
ក៏បានទូលប្រាប់ស្ដេចរបស់ជនជាតិអ៊ីស្រាអែល នូវអ្វីដែលទ្រង់និយាយនៅក្នុង
បន្ទប់សំងាត់របស់ទ្រង់។"

49 ស្ដេចក៏បានបញ្ជាថា "ចូរទៅចាប់បុរសម្នាក់នោះ! នោះគឺជាបុគ្គលដែលនាំការ
រាំងស្ទះដល់យើង។" ហើយកងទ័ពស៊ីរីទាំងមូលបានចុះព័ទ្ធ ជុំវិញក្រុងដូថាន់។
ពួកគេទាំងអស់គឺនៅជុំវិញទីក្រុង។

50 ហើយកេហាស៊ីដែល—ដែលជាអ្នកបម្រើរបស់ហោរា គាត់បានភ្ញាក់ឡើង
ហើយបាននិយាយថា "អូ! ឪពុករបស់ខ្ញុំអើយ មានកងទ័ពជាច្រើន បានព័ទ្ធជុំវិញ
យើងទាំងអស់គ្នានៅទីនេះ។ យើងត្រូវបានហ៊ុំព័ទ្ធពេញទាំងស្រុងហើយ។"

51 ហោរាបាននិយាយថា "ហេតុអ្វីមានទាហាន ច្រើនណាស់នៅជាមួយយើង
ច្រើនជាងនៅជាមួយពួកគេទៅទៀត" ឃើញទេ?

ហើយកេហាស៊ីមើលជុំវិញ ក៏បាននិយាយថា "ខ្ញុំមិនឃើញមានទាហានណា
ម្នាក់ទេ នៅជាមួយយើង។"

52 ហោរាបាននិយាយថា "ព្រះអម្ចាស់ជាព្រះ សូមបើកភ្នែកក្មេងប្រុសនេះ
ឡើងផង។" ហើយភ្នែករបស់គាត់ក៏បានបើកឡើងឃើញភ្នំទាំងអស់មាន
ពេញដោយពួកទេវតានិងរទេះចំបាំងអគ្គុយជុំវិញនេះគឺជាកងកម្លាំងដែលមិនអាច
មើលឃើញ។

53 អេលីយ៉ាបានដើរឆ្ពោះទៅទីនោះ ហើយព្រះគម្ពីរបានចែងថា "គាត់វាយពួកគេ
ឲ្យពួកគេក្លាយជាមនុស្សខ្វាក់។" គាត់បានដើរចេញទៅកាន់ពួកគេ ពួកគេត្រូវបាន
ងងឹតនៅចំពោះគាត់។ គាត់បានដើរចេញក្រៅ ហើយនិយាយថា "តើអ្នកកំពុងតែ
ស្វែងរកលោកអេលីយ៉ាឬ?"

ពួកគេនិយាយថា "បាទយើងកំពុងសម្លឹងរកមើលគាត់។"

54 ក៏និយាយថា "អញ្ជើញមកខ្ញុំនឹងប្រាប់អ្នក ពីកន្លែងដែលគាត់នៅ" ហើយបាន
ដឹកនាំពួកគេចូលទៅកន្លែងវាយឆ្មក់ ត្រង់កន្លែងដែលកងទ័ពបានដើរចេញ និង
ចាប់យកពួកគេ។

55 ឥឡូវនេះ ព្រះគម្ពីរបានចែងថា "គាត់វាយពួកគេឲ្យពិការភ្នែក។" នោះវាបាន
ដោះស្រាយ។ សព្វថ្ងៃនេះមនុស្សកំពុងតែងងឹតខ្លាំងណាស់ខាងវិញ្ញាណ ទោះបីជា

ព្រះអម្ចាស់ជាព្រះចុះមកនៅកណ្តាលមនុស្សហើយធ្វើអ្វីទាំងអស់ ព្រមទាំងសេចក្តីដែលទ្រង់បានសន្យាផង ពួកគេនៅតែមិនអាចមើលឃើញ។ ពួកគេគឺខ្វាក់ខាងវិញ្ញាណមិនស្គាល់ព្រះជាម្ចាស់ មិនស្គាល់អំណាចអស្ចារ្យរបស់ទ្រង់។ ឥឡូវនេះ យើងបានសង្កេតឃើញថា ពួកគេបានធ្វើការនោះ នៅក្នុងសម័យលោកអេលីយ៉ា ហើយពួកគេនៅតែបន្តធ្វើវានៅសព្វថ្ងៃនេះ។ ព្រះបានវាយពួកគេឲ្យខ្វាក់។ ពួកគេបាននិយាយនៅថ្ងៃនេះថា "គ្មានការអស្ចារ្យទេ គឺមិនមានរឿងទាំងអស់នោះទេ នេះគឺជាអារម្មណ៍ស្រមើស្រម៉ៃ។"

56 ហើយពួកគេបាននិយាយអំពីហោរាអេលីយ៉ាដូចគ្នា ពីព្រោះពេលដែលគាត់ត្រូវបានលើកឡើង ហើយអេលីសេបានជំនួសកន្លែងរបស់គាត់ បុរសវ័យក្មេងម្នាក់ដែលទំពែកតាំងពីក្មេង មានកុមាររត់តាមពីក្រោយគាត់ ហើយស្រែកថា "តាទំពែកកញ្ចាស់អើយ ហេតុអ្វីបានជាតាឯងមិនឡើងទៅលើ ជាមួយនឹងលោកអេលីយ៉ាដូច្នេះ?" ឃើញទេ ពួកគេមិនបានសូម្បីតែជឿ តាំងពីពេលដើមដំបូងម្លេះ មនុស្សជំនាន់បន្តបន្ទាប់មកទៀត មានរឿងជាច្រើនត្រូវបានធ្វើ។ ហើយបុរសអស្ចារ្យរបស់ព្រះជាម្ចាស់រូបនេះ ត្រូវបានលើកឡើងទៅស្ថានសួគ៌ ដោយរទេះដែលឆេះដោយភ្លើង តែមនុស្សនៅតែមិនជឿការនេះទៀត។ ហើយកូនក្មេងតូចៗរបស់ពួកគេរត់ទៅពីក្រោយបុរសម្នាក់នេះ ទាំងស្រែកថា "តាទំពែកញ្ចាស់ ហេតុអ្វីបានជាតាឯងមិនឡើងទៅ?" ឃើញទេ? ហើយបន្ទាប់មកហោរាបានដាក់បណ្តាសា ដល់កូនក្មេងទាំងនោះ ហើយមានសត្វខ្លាឃ្មុំញីសម្លាប់ក្មេងទាំងនោះ ស្លាប់អស់សែសិបពីរនាក់(៤២)ក្នុងពួកគេ។

57 ឥឡូវនេះចំណាំ។ សព្វថ្ងៃនេះ ដូចជាពេលនោះអញ្ចឹង ពួកគេបានដាក់ការបកស្រាយផ្ទាល់របស់ពួកគេ ទៅក្នុងព្រះបន្ទូលព្រះ។ ឥឡូវនេះប្រសិនបើពួកគេចង់ធ្វើបែបនោះ នោះស្រេចតែពួកគេទៅចុះ ប៉ុន្តែពួកគេព្យាយាម ដើម្បីធ្វើឲ្យយើងជឿតាមទៀត។ ព្រះគម្ពីរបានចែងដូច្នេះ "ព្រះបន្ទូលនៃព្រះនេះ គឺគ្មានការបកស្រាយជាឯកជនទេ។" ព្រះធ្វើការបកស្រាយ ដោយអង្គទ្រង់ផ្ទាល់។ ព្រះជាម្ចាស់បញ្ជាក់ព្រះបន្ទូលរបស់ទ្រង់ ហើយនោះគឺជាការបកស្រាយរបស់វា។ ដូចដែលខ្ញុំបាននិយាយជាច្រើនដងហើយថាទ្រង់បានមានបន្ទូលជាមុនដំបូង "ចូរឲ្យមានពន្លឺឡើង" ដូច្នោះក៏មានពន្លឺឡើង។ ដែលមិនចាំបាច់ត្រូវការការបកស្រាយអ្វីទេ វាបានកើតឡើងមែន។ ទ្រង់មានបន្ទូលថា "នាងព្រហ្មចារីម្នាក់នឹងមានគភ៌" នាង

ក៏មានគភ៌មែន។ ទ្រង់មានបន្ទូលថាទ្រង់នឹង "ចាក់ព្រះវិញ្ញាណរបស់ទ្រង់" ទ្រង់ក៏ធ្វើ។ ហើយទ្រង់មានបន្ទូលថា "នៅក្នុងថ្ងៃចុងក្រោយនេះ" ការអ្វីដែលទ្រង់នឹងធ្វើ ទ្រង់កំពុងធ្វើវា! វាមិនត្រូវការការបកស្រាយណាមួយទេ ព្រះកំពុងធ្វើការបកស្រាយផ្ទាល់របស់ទ្រង់។ មិនថាមនុស្សល្ងង់និយាយយ៉ាងម៉េចទេ គឺមិនអាចបញ្ឈប់ព្រះបន្ទិចសោះឡើយ។

58 ពេលព្រះយេស៊ូវគង់នៅលើផែនដីនៅឡើយ ទ្រង់ជួបមនុស្សដែលមិនជឿជាច្រើន ដែលមកដើម្បីឈ្លោះជាមួយទ្រង់ ដូចដែលយើងបានជួប នៅសព្វថ្ងៃនេះ ហើយប្រហែលជានឹងមានច្រើនទៀត។ ប៉ុន្តែវាមិនបានបញ្ឈប់ទ្រង់ទេ ទ្រង់បានចេញទៅសម្តែងនិងធ្វើភារកិច្ចរបស់ទ្រង់ ហើយព្រះជាម្ចាស់បញ្ជាក់ពីអ្វីគ្រប់យ៉ាងដែលទ្រង់បានធ្វើ។ ទ្រង់មានបន្ទូលថា "ខ្ញុំមិនមែនធ្វើ ដោយអាងអំណាចខ្លួនឯងទេ ព្រះវរបិតាហើយនិងខ្ញុំគឺតែមួយទេ ទ្រង់គង់នៅក្នុងខ្ញុំ វាមិនមែនជាខ្ញុំទេដែលធ្វើការនោះ វាគឺជាព្រះវរបិតាដែលស្ថិតនៅក្នុងខ្ញុំវិញ។ ហើយប្រសិនបើខ្ញុំធ្វើកិច្ចការរបស់ទ្រង់ បន្ទាប់មកអ្នកមិនជឿខ្ញុំ! ប៉ុន្តែប្រសិនបើខ្ញុំធ្វើកិច្ចការនោះ ហើយអ្នកមិនអាចជឿខ្ញុំនៅឡើយទេ ចូរជឿលើកិច្ចការទាំងនោះចុះ" ឃើញទេ? នៅក្នុងពាក្យផ្សេងទៀតពួកគេបាន..."ស្វែងរកបទគម្ពីរ" ទ្រង់មានបន្ទូលថា "ដ្បិតកន្លែងដែលអ្នកគិតថាអ្នកបានទទួលជីវិតអស់កល្បជានិច្ច គឺដោយយល់បទគម្ពីរនេះ។ ហើយបទគម្ពីរនោះឯង ធ្វើបន្ទាល់ពីខ្ញុំ។" អាម៉ែន! មើលប្រយោគនេះនែ "ព្រះបន្ទូលគឺជាព្រះបន្ទូល បទគម្ពីរប្រាប់អ្នកថា ខ្ញុំជានរណា" នេះជាព្រះបន្ទូលរបស់ព្រះយេស៊ូវ។

59 ហើយជាបទគម្ពីរដែលបានប្រាប់អ្នកអំពីសម័យកាល ដែលយើងកំពុងរស់នៅសព្វថ្ងៃ។ ហើយរឿងអ្វីដែលអ្នកបានឃើញនិងកើតឡើង វាគឺជាព្រះអង្គទ្រង់ផ្ទាល់នៅក្នុងកណ្តាលប្រជាជនរបស់ទ្រង់។ គ្មាននរណាអាចប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញបានទេ ប៉ុន្តែព្រះទ្រង់អាច។ គ្មាននរណាដែលអាចធ្វើកិច្ចការណាមួយដែលទ្រង់បានធ្វើពេលនេះបានទេប៉ុន្តែមានតែទ្រង់តែមួយគត់។ ព្រោះព្រះគម្ពីរបានចែងថា "ទ្រង់នៅតែដដែល កាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត។"

60 ឥឡូវនេះយើងឃើញនិន្នាការ សម័យទំនើបរបស់មនុស្ស បន្ទាប់មកទៀត "អូ ថ្ងៃនោះកន្លងផុតទៅហើយ គ្មានរឿងអស្ចារ្យបែបនេះទៀតទេ មនុស្សដែលពេញដោយមនោសញ្ចេតនាទាំងនោះ បានបង្កើតរឿងហ្នឹងឡើង។"

61 ចូរស្តាប់លោកអេលីយ៉ាដែលជាហោរា ស្រែកប្រឆាំងនឹងពួកសាសនាវិទូទាំងនោះ។ ចំណាំ ចំណាំគាត់បាននិយាយដូចជាគាត់គឺជាព្រះផ្ទាល់។ អេលីយ៉ាលោកនិយាយដូចជាគាត់ខ្លួនឯងគឺជាព្រះ "ទឹកសន្សើមនឹងមិនធ្លាក់ចុះពីស្ថានសួគ៌ទេ រហូតទាល់តែខ្ញុំហៅវា។" អាម៉ែន! បាទមែនហើយ។ ហោរារូបនេះបានពឹងផ្អែកទាំងស្រុងនៅក្នុងវត្តមាននៃព្រះ!

62 ពួកហោរានៅក្នុងសម័យសញ្ញាចាស់ ឬពេលណាទៀត នៅពេលដែលពួកគេរស់នៅក្នុងវត្តមានរបស់ព្រះ ពួកគេបានក្លាយជាអ្នកថ្លែងព្រះបន្ទូល សាររបស់ពួកគេគឺជាព្រះបន្ទូលនេះឯង។ ហើយចូរចងចាំ លោកបាននិយាយពី "**ព្រះបន្ទូលរបស់ព្រះអម្ចាស់។**" ហើយនៅពេលដែលបុរសទាំងនោះ មានសារទាំងនោះពីព្រះហើយ ការគិតរបស់ពួកគេផ្ទាល់ បានរុំជាប់នឹងព្រះបន្ទូល...វាអាចប្រឆាំងទៅនឹងការគិតរបស់ពួកគេ ពួកគេប្រហែលជាមិនអាចមើលឃើញ—ឃើញច្បាស់លាស់។ ប៉ុន្តែពួកគេបានថ្លែងព្រះបន្ទូលរបស់ព្រះ "**ព្រះបន្ទូលរបស់ព្រះអម្ចាស់។**"

63 "វានឹងមិនមានទឹកភ្លៀងណាមួយធ្លាក់ចុះឡើយ រហូតដល់ខ្ញុំហៅវា។" អូ! មើលប្រយោគនេះនែ! គាត់បានរស់នៅក្នុងវត្តមានរបស់ព្រះ ហើយត្រូវបានបើកសម្តែងយ៉ាងល្អឥត ខ្ចោះ។ ហើយចូរចងចាំ តាមរយៈព្រះគម្ពីរអេម៉ុស ៣:៧ "*ពិតប្រាកដជាព្រះយេហូវ៉ា ទ្រង់នឹងមិនធ្វើអ្វីដូច្នោះឡើយ លើកតែទ្រង់សំដែងឲ្យពួកហោរា ជាអ្នកបំរើទ្រង់ ឃើញគំនិតលាក់កំបាំងរបស់ទ្រង់ផង*" បានចែងថា "វានឹងមិនធ្លាក់ភ្លៀងណាមួយទេ!" ទ្រង់បង្ហាញជាមុន...

64 គេបានសើចចំអកដាក់គាត់ ពួកគេបានគិតថាគាត់គឺជាមនុស្សឆ្កួត "គួរឲ្យចាប់អារម្មណ៍ណាស់!" ប៉ុន្តែសូមមើល គាត់មាន**ព្រះបន្ទូលរបស់ព្រះអង្គម្ចាស់** ថានឹងមិនមានភ្លៀងធ្លាក់។ ហើយមុនពេលព្រះធ្វើការនោះ ទ្រង់បានបើកសំដែងឲ្យអេលីយ៉ាជា អ្នកបម្រើរបស់ទ្រង់ឃើញមុន។ ហើយគាត់គឺ ជាហោរាត្រឹមត្រូវ ដែលបង្ហាញឲ្យឃើញ ដូច្នេះប្រជាជនត្រូវមានការប្រែចិត្ត។ ប៉ុន្តែជំនួសឲ្យការនោះ ពួកគេបានសើចចំអកដាក់គាត់ ហើយនិយាយថា "អូ! យើងបានទទួលភ្លៀងច្រើនពេកហើយ! អាងទឹកនេះមានទឹកពេញហូហៀរហើយ។ ទឹកទន្លេនេះកំពុងហូរបានល្អណាស់។"

65 ព្រះគម្ពីរបានចែងថា "មិនមានសូម្បីតែទឹកសន្សើម អស់រយៈពេលបីឆ្នាំប្រាំមួយខែ។" អស់ទាំងបឹងរីងស្ងួតគ្មានទឹកនៅគ្រប់ទីកន្លែង។ នោះតើមិនមែន

ជាបុរសម្នាក់នោះទេឬ ដែលព្រះមានបន្ទូលតាមរយៈបុរសម្នាក់នោះ។ នោះគឺជា "អញ" មែនហើយ។ យើងបានស្គាល់ហើយ។ ដូច្នេះគាត់...

66 យើងបានរកឃើញថា នៅពេលដែលមនុស្សម្នាក់បានមក ដែលព្រះបានបញ្ជូនមកបានតែងតាំងឡើងដោយព្រះជាម្ចាស់ដោយមានសេចក្តីពិត ពី**ព្រះបន្ទូលរបស់ព្រះអម្ចាស់** សារនិងអ្នកនាំសារគឺតែមួយហើយដូចគ្នា។ ដោយសារតែគាត់ត្រូវបានបញ្ជូនទៅជាតំណាង **ព្រះបន្ទូលរបស់ព្រះអម្ចាស់** ពីមួយពាក្យទៅមួយពាក្យ ដូច្នេះគាត់ហើយនិងសាររបស់គាត់ គឺដូចគ្នា។

67 មនុស្សក្នុងនិកាយក្រោមការទំនុកបម្រុងរបស់និកាយ គាត់ហើយនិងក្រុមជំនុំរបស់គាត់គឺ "តែមួយ"។ អ្នកល្បីខាងទេវវិទ្យា នៅក្រោមការសិក្សាពីសាសនាមួយដែលបង្កើតឡើងដោយនិកាយមួយចំនួន គាត់ហើយនិងសាររបស់គាត់គឺតែមួយ ក្រុមជំនុំនៃទេវសាស្រ្ត អ្នកបង្រៀនពីទេវវិទ្យា។ ត្រឹមត្រូវហើយ។

68 បន្ទាប់មកនៅពេលដែលបុរសម្នាក់បានមកជាមួយ**ព្រះបន្ទូលរបស់ព្រះអម្ចាស់** គាត់ហើយនិងសាររបស់គាត់គឺតែមួយ។ ហើយនៅពេលដែលអេលីយ៉ាបានមកជាមួយនឹង **ព្រះបន្ទូលរបស់ព្រះអម្ចាស់** លោកហើយនិងសាររបស់លោកបានក្លាយជាតែមួយ។ ដូចជាព្រះយេស៊ូវដែរ នៅពេលដែលទ្រង់យាងមក ទ្រង់គឺជាព្រះបន្ទូល ដែលមានចែងក្នុងយ៉ូហាន ១។ ដូច្នេះព្រះបន្ទូលរបស់ព្រះជាម្ចាស់និងអ្នកនាំសារ នៅគ្រប់សម័យកាល គឺជារឿងតែមួយគ្រប់ពេលវេលា។ ត្រូវហើយ។

69 ព្រះយេស៊ូវគឺ ជាព្រះបន្ទូលដែលត្រូវបានទាយទុក។ ទ្រង់គឺជាអ្វីដែលពួកហោរាបានថ្លែងថានឹងកើតឡើង "នាងព្រហ្មចារីនឹងមានគភ៌ ហើយប្រសូត្របានបុត្រាមួយអង្គ។" ត្រឡប់ទៅក្រោយវិញ ព្រះបានប្រាប់ពួកគេដោយបន្ទូលថា "ពូជរបស់ស្រ្តីនឹងកិនក្បាលសត្វពស់ ហើយសត្វពស់ នឹងចឹកកែងជើងរបស់នាង។" សេចក្តីទំនាយទាំងនេះត្រូវបានសម្រេច។ ដាវីឌយំសោក អស់ទាំងហោរាដែលនៅសល់ជំនាន់ក្រោយ បានទាយពីទ្រង់។ ទ្រង់គឺជាព្រះបន្ទូលដែលបានសម្តែង! ហា លេលូយ៉ា!

70 ឥឡូវនេះតើអ្នកឃើញពីកន្លែងដែលខ្ញុំកំពុងតែព្យាយាមទៅទេ? ខ្ញុំបាននិយាយជាមួយអ្នក ក្នុងភាពស្រស់បំព្រង ពីធម្មជាតិនៅព្រឹកនេះ។ តើអ្នកមិនឃើញអំណាចនៃព្រះដ៏រស់ នៅក្នុងព្រះវិហារដ៏រស់នៃកូនក្រមុំទេឬអី? អ្នក

ឈើត្រូវបានប្រោសឲ្យជា មនុស្សស្លាប់បានរស់ឡើងវិញ មនុស្សពិការបានដើររួច មនុស្សខ្វាក់បានមើលឃើញ ដំណឹងល្អចេញទៅនៅក្នុងអំណាចរបស់ខ្លួន ពីព្រោះសារហើយនិងអ្នកនាំសារគឺតែមួយ។ ព្រះបន្ទូលគឺនៅក្នុងក្រុមជំនុំ នៅក្នុងមនុស្ស។

71 ព្រះបន្ទូលរបស់ព្រះគឺនៅក្នុងលោកអេលីយ៉ា នៅពេលដែលគាត់បានដើរឡើងទៅទីនោះជាមួយ **ព្រះបន្ទូលរបស់ព្រះអម្ចាស់** ដែលថែងថា "វានឹងមិនមានភ្លៀងធ្លាក់ឡើយ។" នោះមិនមែនជាហោរាអេលីយ៉ាទេ គឺជាព្រះនៅក្នុងអេលីយ៉ាវិញ។

72 ខ្ញុំបាននិយាយជាច្រើនដងហើយ ដូចជាស្ត្រីវិទ្យាសាស្ត្រគ្រីស្ទានម្នាក់ បានប្រាប់ខ្ញុំក្នុងពេលមួយថា។ ខ្ញុំបានប្រាប់ជាច្រើនដងហើយអំពីវា។ នាងនិយាយថា "លោកប្រាណហាំ អ្នកដាក់ក្តីអំនួតច្រើនពេកហើយនៅលើព្រះយេស៊ូវ។"

ខ្ញុំបាននិយាយថា "ខ្ញុំសង្ឃឹមថានោះគឺជាចម្លើយតែមួយគត់ដែលខ្ញុំមាន។"

ហើយនាងបាននិយាយថា "អ្នកព្យាយាមធ្វើឲ្យទ្រង់ក្លាយជាព្រះ។"

ខ្ញុំបាននិយាយថា "ទ្រង់គឺជាព្រះរួចហើយ។"

73 នាងបន្តទៀតថា "អូ! គាត់គឺជាហោរាម្នាក់ គាត់ជាមនុស្សល្អប៉ុន្តែគាត់មិនមែនជាព្រះទេ។"

74 ហើយខ្ញុំបាននិយាយថា "មិនអីទេ សូមបង្ហាញខគម្ពីរណាមួយ ដែលនិយាយថាទ្រង់មិនមែនជាព្រះមកអញ្ចឹង។"

75 នាងបាននិយាយថា "នៅក្នុងសៀវភៅរបស់យ៉ូហាន បានប្រាប់ថាគាត់បាន 'យំ' នៅពេលដែលទ្រង់យាងទៅផ្នូររបស់ឡាសារ។"

76 "ប្រសើណាស់" ខ្ញុំនិយាយ "ប្រាកដមែន ទ្រង់បានយំ។ ទ្រង់គឺជាមនុស្សហើយក៏ជាព្រះដែរ។ ទ្រង់ជាមនុស្សដែលអាចយំ ប៉ុន្តែទ្រង់ជាព្រះដែលប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ។" ពិតមែន។ ខ្ញុំនិយាយទៀត "ទ្រង់គឺជាមនុស្សម្នាក់ដែលឃ្លាន ប៉ុន្តែទ្រង់ជាព្រះ ដែលផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់ ជាមួយនឹងនំពីរត្រីប្រាំកន្ទុយ។" នោះជាការពិត។ "ទ្រង់ជាមនុស្សម្នាក់ដែលបានដេកនៅក្នុងទូកខាងក្រោយ ប៉ុន្តែមានព្រះដែលគង់ក្នុងទ្រង់ ដែលបានធ្វើឲ្យសមុទ្របានស្ងប់។" សម្រាប់អ្វី? ទ្រង់ហើយនិងសាររបស់ទ្រង់គឺតែមួយ។

77 ទ្រង់មានបន្ទូលថា "ខ្ញុំនិងព្រះបិតាខ្ញុំគឺតែមួយទេ។ ព្រះបិតារបស់ខ្ញុំស្ថិតនៅក្នុងខ្ញុំ។" ទ្រង់គឺជាភាពពេញលេញនៃរូបកាយព្រះ។

78 ខ្ញុំគិតថា វាគួរឲ្យភិតភ័យមែនទែន នៅពេលដែលខ្ញុំបាននាំយក *សម័យកាលព្រះវិហារទាំងប្រាំពីរ។* ដើម្បីចាប់ផ្តើមបិទជាមួយ ខ្ញុំ—ខ្ញុំមិនអាចឲ្យព្រះយេស៊ូវឈរនៅទីនោះជាមួយ...ជាមួយភាពសស្គុសនៅព័ទ្ធជុំវិញបែបនេះ ដែលបាននិយាយថា "កេសាររបស់ទ្រង់គឺសដូចជារោមចៀម។" ខ្ញុំមិនអាចយល់បានទេ ថាបុរសដែលមានវ័យសាមសិបបីឆ្នាំ ក្លាយជាព្រិលសរ។

79 ខ្ញុំបានហៅ អ្នកល្បីខាងទេវសាស្រ្ត ទេវសាស្រ្តខាងពេនទីកុស Pentecostal ដែលជាមិត្តជាទីស្រលាញ់។ មែនហើយ អ្នកនោះគឺជាបងប្រុស ជេគម័រ(Jack Moore)។ គាត់ជាបុរសឆ្លាតវៃ ឧស្សាហ៍។ គាត់និយាយថា "បងប្រុសប្រាណហាំ នោះគឺព្រះយេស៊ូវគ្រីស្ទ ដែលបានសំដែងសិរីរុងរឿង។ នោះហើយគឺជាភិនភាគទ្រង់ បន្ទាប់ពីទ្រង់បានសំដែងសិរីរុងរឿង។" ទេខ្ញុំមិនអាចជឿបានទេ។ អត់ទេ។

ខ្ញុំ—ខ្ញុំ—ខ្ញុំនិយាយថា "ប្រសើណាស់ បងប្រុសម័រ សូមអរគុណ" ។

80 ខ្ញុំបានចូលក្នុងបន្ទប់នៅទីនោះ ហើយបាននិយាយទៅកាន់ព្រះជាម្ចាស់។ ខ្ញុំបានសម្រួលមាលីសព្ទរបស់ខ្ញុំ ដើម្បីដកស្រង់ពីទ្រង់ត្រឡប់ទៅដានីយ៉ែលវិញ ជាកន្លែងដែលបានចែងថា "ហើយគាត់បានចូលមកក្នុងសម័យកាលដើម ជាអ្នកដែលមានសក់សដូចជារោមចៀម។"ខ្ញុំនិយាយថា "ព្រះអម្ចាស់អើយខ្ញុំ—ខ្ញុំ—ខ្ញុំមិនដឹងថាត្រូវនិយាយអ្វីនោះទេហើយខ្ញុំមានទំនួលខុសត្រូវចំពោះការនេះ។" ឥឡូវនេះនោះ គឺមុនពេល-...ហើយចូរចងចាំថាមុនពេលត្រាទាំងប្រាំពីរបានបើកប្រហែលមួយឆ្នាំ ឬច្រើនជាងនេះ។ ខ្ញុំបានអធិស្ឋាននៅទីនោះថា "បពិត្រព្រះអម្ចាស់! តើវាជាអ្វី?"

81 ហើយខ្ញុំសម្លឹង មើលទៅមានបុរសម្នាក់បានឈរចំពោះមុខខ្ញុំ ហើយគាត់ជាចៅក្រមមួយ ហើយគាត់មានពាក់សក់ស។ ចៅក្រមនៃសម័យបុរាណត្រូវបានពាក់សក់ស ដើម្បីបង្ហាញថាគាត់ជាអាជ្ញាធរកំពូល។

82 ហើយបន្ទាប់មក នៅពេលដែលខ្ញុំបានមើលឃើញព្រះយេស៊ូវ ដោយពាក់សក់ ស ខ្ញុំបាននិយាយថាវាគ្រាន់តែបញ្ជាក់ការពិត ឲ្យយើងបានស្គាល់ថា ទ្រង់ជា

អាជ្ញាធរកំពូល។ ព្រះទ្រង់បានធ្វើជាទីបន្ទាល់រឿងដដែលនេះនៅលើភ្នំ ដែលបានឲ្យដឹងថា "នេះជាកូនស្ងួនភ្ងាអញ ចូរស្តាប់ទ្រង់ ទ្រង់គឺជាអាជ្ញាធរកំពូល!"

83 បន្ទាប់មកត្រឡប់មកវិញនៅទីនោះ នៅដើមនៃត្រាទាំងប្រាំពីរ នៅពេលដែលទេវតាទាំងប្រាំពីរចុះមក នៅក្នុងបែបនៃរាងពីរ៉ាមីតនោះ បានឈរនៅទីនោះ ហើយបានប្រាប់ខ្ញុំឲ្យត្រឡប់មកវិញនៅទីនេះហើយនិយាយនៅលើត្រាទាំងប្រាំពីរ ហើយទ្រង់នឹងគង់នៅជាមួយខ្ញុំ ទ្រង់នឹងបង្ហាញខ្ញុំថាពួកគេជានរណា ជាអ្វីដែលបានបាត់បង់។ ខ្ញុំតែងតែគិតថា វាត្រូវបានផ្សាភ្ជាប់នៅផ្នែកខាងក្រោយនៃសៀវភៅនេះហើយវានឹងមានអ្វីមួយ មិនត្រូវបានសរសេរនៅក្នុងសៀវភៅនោះ ប៉ុន្តែវាបានប្រែក្លាយឲ្យស្គាល់ថា ទ្រង់មិនអាចធ្វើដូច្នោះ។ វាមិនមែនជាអ្វីដែលបានសរសេរនៅក្នុងសៀវភៅ...វាជាអ្វីដែលត្រូវបានលាក់ទុកនៅក្នុងសៀវភៅនេះ។ "ចំពោះអ្នកណាដែលដកព្រះបន្ទូលចេញ ឬ បន្ថែមពាក្យណាមួយទៅវា..." ដូច្នេះវាគឺជាការអាថ៌កំបាំងដែលមាននៅក្នុងសៀវភៅនេះ នៅក្នុងសម័យកាលព្រះវិហារទាំងប្រាំពីរ។ សៀវភៅនីមួយៗបានបង្កើត—ការអាថ៌កំបាំង គឺទាំងពិធីបុណ្យជ្រមុជទឹក និងអ្វីផ្សេងទៀតដែលពួកគេបានរាវរក អស់រយៈពេលយ៉ាងយូរដូច្នេះ។

84 បន្ទាប់មកនៅពេលដែលបានហោះឡើង អ្នកសង្កេតការធំមួយបានចុះពីរដ្ឋកាលីហ្វរញ៉ា ចុះពីយន្តហោះទៅកាន់ម៉ិកស៊ិកគោ ជុំវិញតាក់សុន នៅគ្រប់ទីកន្លែង ថតរូបភាពនៃការនេះ។ វាជាការមើលឃើញចម្លែក។ បងប្រុស ហ្វ្រីឌ សុទ្ធមែន(Fred Sothmann)នៅទីនោះ អង្គុយនៅខាងក្រោយទីនោះ ហើយខ្ញុំ និងបងប្រុស ជីនន័រមែន (Gene Norman)ឈរនៅកន្លែងបង្ហាញនោះ នៅពេលដែលវាបានហោះទៅលើ។ ពួកគេបានថតរូបភាព តែពួកគេនៅតែមិនអាច ដឹងថាវាជាអ្វី។ ទីនេះពេលយូរមកហើយ មនុស្សគ្រប់គ្នានិយាយថា "មើលនៅទីនេះ មើលទៅ*បែបនេះ* ហើយស្លាបពួកទេវតារបស់ពួកគេ ម៉េចបានបត់បែបហ្នឹង។"

85 ថ្ងៃមួយ សូមងាកទៅខាងស្តាំ សម្លឹងមើល គឺជារូបព្រះយេស៊ូវគ្រីស្ទ ដែលហូហ្វមែន(Hofmann)បានគូរយ៉ាងល្អឥតខ្ចោះ ជាងរូបភាពព្រះយេស៊ូវដែលគាត់ធ្លាប់បានគូរ។ ទ្រង់បានឈរនៅទីនោះ ជាមួយសក់ពាក់ពណ៌ស សម្លឹងចុះមកផែនដី បង្ហាញថាទ្រង់គឺជាអាជ្ញាធរកំពូល។ ឋានសួគ៌បានប្រកាសប្រាប់ ព្រះគម្ពីរបានប្រកាសប្រាប់ រាជសារបានប្រកាសប្រាប់ ទាំងអស់គឺដូចគ្នា។ អាជ្ញាធរកំពូល ជាមួយសក់ពាក់ពណ៌ស អ្នកមើលឃើញពុកចង្ការខ្មៅរបស់ទ្រង់ស្ថិតនៅ

ខាងក្រោម។ មនុស្សជាច្រើនក្នុងចំណោមអ្នកបានឃើញរូបភាពនោះ។ យើងមានវានៅខាងក្រោយនៅទីនោះ។ សូមមើលទៅខាងស្តាំ ត្រង់ចំហៀងសម្លឹងមើលទៅ។ ទ្រង់នៅទីនោះ ទ្រង់គឺល្អឥតខ្ចោះ ដូចជារូបថតទ្រង់អញ្ចឹង។ ពួកគេសម្លឹងមើលទៅទេវតាដែលខុស។ អ្នកគួរតែសម្លឹងមើលទេវតាដែលពិតប្រាកដ។ ហើយមានតែព្រះជាម្ចាស់ទេ ដែលអាចបង្ហាញមួយណាត្រូវ។ ត្រឡប់ទៅខាងស្តាំរបស់អ្នក ហើយសម្លឹងមើលទៅ។ ទ្រង់នៅទីនោះទ្រង់ល្អឥតខ្ចោះ ដែលមានរូបថតនៅទីនោះ។

86 លើកទីមួយដែលខ្ញុំឃើញទ្រង់ នោះទ្រង់មើលទៅដូចជា*សិរិសារនៃ*...ហូហ្មែន(Hofmann)។ ខ្ញុំមិនដែលឃើញពីមុនមកទេ។ ហើយនៅថ្ងៃអាទិត្យប៊ីលីរោងឧបោសថប៉ុន្មានឆ្នាំក្រោយមក ខ្ញុំបានឃើញវា។ ផ្ទះរបស់ខ្ញុំមិនដែលគ្មានរូបភាពចាប់តាំងពីពេលនោះ។

87 បន្ទាប់មក នៅលើមេឃទីនេះ ដោយនិយាយថាព្រះដែលខ្ញុំបានឃើញនៅក្នុងនិមិត្ត គឺគ្រាន់តែជាក្មេងប្រុសតូចម្នាក់ ដែលចេញពី សាលារៀនផ្ទះតាំងនៅ ទ្រង់គឺបែបហ្នឹង។ ហើយនៅនៅស្ថានសួគ៌ឯណោះវិញ សាមសិបបីឆ្នាំក្រោយមក បានប្រកាសថា វាជាការពិត។ នោះគឺជាភិនភាគរបស់ទ្រង់! មិនមែនជាអ្វីមួយដែលរៀបចំធ្វើ ដោយគំនិតរបស់នរណាម្នាក់។

88 ដូចនៅវ៉ាទីកង់ ពួកគេ—គូរ—រូបព្រះគ្រីស្ទ នៅទីនោះជាមួយនឹងចិញ្ចៀនពណ៌សតូចៗ នៅក្រោមពុកចង្ការ ជុំវិញចង្ការរបស់ទ្រង់ ប្រវែងពាក់កណ្តាលអ៊ីងឥទ្ធនៅជុំវិញផ្នែកខាងលើនៃព្រះឱស្ឋរបស់ទ្រង់ គឺ*ដូច្នេះ* ហើយហៅថានោះគឺព្រះគ្រីស្ទ។

89 នោះគ្រាន់តែធ្វើឲ្យក្នុងចិត្តខ្ញុំ គិតដល់សិល្បករក្រិចម្នាក់ ដែលខ្ញុំបានឃើញក្នុងវេលាមួយ នៅក្នុងព្រះវិហារបុរាណ ដែលបង្ហាញពីភិនភាគរបស់អ័ដាមនិងអេវ៉ា ពួកគេមើលទៅដូចជាសត្វឬអ្វីមួយ។ នោះជាអ្វីដែលគំនិតខាងសាច់ឈាមគិតឃើញរឿងខាងវិញ្ញាណមួយចំនួន។ ខ្ញុំគិតថាអ័ដាមគឺជាបុរសសង្ហាបំផុត ដែលមិនធ្លាប់មាន ហើយអេវ៉ាជាស្ត្រីម្នាក់ល្អឥតខ្ចោះនៅគ្រប់ជ្រុងជ្រោយ។

90 ឥឡូវនេះ គំនិតខាងសាច់ឈាម បានចាប់បញ្ចូលទស្សនៈ របស់ពួកគេផ្ទាល់ ហើយព្រះទ្រង់យាងចុះមក ហើយលាតត្រដាង ដោយអំណាចរបស់ទ្រង់។ នោះហើយជាអ្វីដែលបានកើតឡើងនៅទីនេះ ក្នុងថ្ងៃនៃអ័ហាប់។

91 ឥឡូវនេះយើងឃើញថាហោរាអេលីយ៉ាអាចនិយាយដូច្នេះពីព្រោះវាជាដំណឹងនៃសម័យកាលនិងព្រះបន្ទូលរបស់ព្រះ ឬក៏ អ្នកនាំសារ រាជសារ—រាជសារហើយនិងព្រះបន្ទូល គឺពិតជាដូចគ្នា។ ពួកហោរា ព្រះបន្ទូល សារហើយនិងអ្នកនាំសារ សារ និងសារគឺដូចគ្នា។ ព្រះយេស៊ូវមានព្រះបន្ទូលថា "ប្រសិនបើខ្ញុំមិនធ្វើការ ដែលបានចែងទុកពីខ្ញុំ នោះកុំជឿខ្ញុំឡើយ។" នោះគឺល្អ។ មនុស្សណាម្នាក់ហើយនិងសាររបស់គាត់គឺតែមួយ។

92 នោះហើយជាមូលហេតុនៅសព្វថ្ងៃនេះ ដែលពួកគេមិនជឿក្នុងការធ្វើកិច្ចការរបស់ព្រះជាម្ចាស់ ដោយសារពួកគេមិនទទួលយកដំណឹងល្អរបស់ព្រះ។ ពួកគេមិនបានជឿដំណឹងនេះ។

93 តែ ឯអស់អ្នកណាដែលជឿពេលវេលារបស់ព្រះដែលយើងរស់នៅ ទាំងអស់នេះ ជាអាហារដ៏លាក់កំបាំង។ គ្រាន់តែគិតថា ព្រះបានលាក់ទុកវាដូច្នេះ ពួកគេបានមើលហើយ តែមិនឃើញវាទេ។ ដូចគ្នាដែលអេលីយ៉ាធ្វើឲ្យកងទ័ពស៊ីរីទៅជាងងឹត។ ដូចគ្នាដែលព្រះបានធ្វើឲ្យអ្នកមិនជឿ មើលមិនឃើញអាហារពិតរបស់កូនដែលជឿ។

94 តើពួកគេបានហៅលោកណូអេថាជាអ្វី "មនុស្សជ្រុលនិយម" សាងសង់ទូកធំមួយ ភ្នែករបស់គាត់ត្រូវបានបើកដោយព្រះបន្ទូលរបស់ព្រះ ហើយនិងសេចក្តីសន្យា។ រឿងដែលថាពួកគេបានហៅថា អ្នកនិយមជ្រុល បានសង្គ្រោះលោកណូអេនិងគ្រួសាររបស់គាត់។ ឃើញទេ វាជារឿងដដែលនេះ។ រឿងដែលមនុស្សសើចចំអក គឺជាអ្វីដែលយើងអធិស្ឋានសម្រាប់។ អ្វីដែលមនុស្សថា "ឆ្កួត" យើងហៅថា "អស្ចារ្យ!" អ្វីដែលលោកិយថា "អស្ចារ្យ" ហើយព្រះថា "ល្ងង់ខ្លៅ។" ហើយអ្វីដែលលោកិយហៅថា "ល្ងង់ខ្លៅ" ព្រះជាម្ចាស់ហៅថា "អស្ចារ្យ!" វាគ្រាន់តែជាភាពផ្ទុយគ្នារវាងត្រូវហើយនិងខុស។ យេស៊ូវគ្រីស្ទគឺនៅតែដដែល កាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។

95 សូមចាំថាគាត់បានចូលទៅក្នុងកន្លែងសម្ងាត់របស់គាត់ តាមផែនការរបស់ព្រះ តាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ហើយតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អេលីយ៉ា ចូលទៅក្នុងទីសំងាត់របស់គាត់ ដោយដឹងជាមុនមកពីព្រះ ផែនការនិងការត្រាស់ហៅលើជីវិតរបស់គាត់ ហើយតាមព្រះបន្ទូលព្រះ។ ប្រសិនបើការនោះ

មិនមែនជារបៀបដែលយើងបានចូលមក ខ្ញុំមិនដឹងថាយើងអាចចូលទៅទីនោះដោយរបៀបណាទេ។

96 ហើយ សូមកត់សម្គាល់ មុនពេលចាប់ផ្តើមគ្រោះរាំងស្ងួតនេះ លោកអេលីយ៉ាបានចូលទៅក្នុងកន្លែងរស់នៅដ៏សម្ងាត់របស់គាត់។ ប្រភេទមួយមុនការជំនុំជំរះវាយផែនដី ក្រុមជំនុំត្រូវបានត្រាស់ហៅរួចមកហើយ កូនក្រមុំគឺបានជ្រើសរើសរួចហើយ ហើយគ្រាន់តែរង់ចាំពេលនៃការជំនុំជំរះ។ កំពុងតែរង់ចាំរួចទៅហើយ បរិភោគអាហារនៃព្រះជាម្ចាស់ រីករាយពរជ័យនៃព្រះ។ មនុស្សម្នាក់ៗនៅក្នុងគំនិតធម្មតាៗ បានដឹងថាយើងកំពុងដឹកនាំត្រង់ទៅមុខយើងកំពុងរស់នៅក្នុងវេលានៃការជំនុំជំរះ។

97 ចូរមើល! បងប្រុសប៊ែង(Banks) ពីរបីនាក់ក្នុងចំណោមអ្នករាល់គ្នា នៅទីនេះយប់នេះ ឈរនៅលើភ្នំនៅព្រឹកនោះ។

98 ហើយខ្ញុំចង់និយាយអំពីភ្នំនោះ នៅព្រឹកថ្ងៃអាទិត្យក្រោយ តាមព្រះហឫទ័យព្រះអម្ចាស់។ បានទទួលការបើកសម្តែងដ៏អស្ចារ្យ មួយបន្ថែមទៀតដែលខ្ញុំមិនអាចស្ទើរតែរក្សាបានក្នុងការប្រាប់វា ក្នុងយប់នេះ។ ប៉ុន្តែខ្ញុំបាន...ឃើញទេ? ហើយវាគ្រប់ពេលវេលាជានិច្ច រឿងមួយកើតឡើងបន្ទាប់ពីរឿងផ្សេងទៀត។ ឃើញទេ? វានឹងមិនបញ្ឈប់ការកើតឡើងនេះទេ ព្រោះវាជា **ព្រះបន្ទូលរបស់ព្រះអម្ចាស់។**

99 គ្រប់គ្នានៅទីនេះ រាប់ពាន់ដងលើរាប់ពាន់ដង នៅលើកាសែត បានឮខ្ញុំឈរហើយនិយាយ "**ព្រះបន្ទូលរបស់ព្រះអង្គម្ចាស់** ដូច្នេះវានឹងត្រូវបាន*ដូច្នេះ*ហើយ*ដូច្នេះ*។" ហើយសូម្បីតែកាសែតនិងទស្សនាវដ្តីមានការប្រកាសដូច្នេះ។ ពួកគេមិនដឹងថា វានិយាយពីអ្វីទាំងអស់ ប៉ុន្តែពួកគេបានឃើញវា។ ពួកគេមិនបានស្គាល់ថាវាជាអ្វី ប៉ុន្តែពួកគេបានមើលឃើញវា ធ្វើឲ្យព្រះបន្ទូលជាសេចក្តីពិត។

100 យើងបានឈរនៅខាងក្រោមទន្លេនេះ ទេវតារបស់ព្រះអម្ចាស់បានចុះក្នុងថ្ងៃនោះ ឆ្នាំសាមសិបបី ឬក៏ឆ្នាំ១៩៣៣ វាបានចុះមកហើយនិយាយរឿង ដែលទ្រង់បានធ្វើ។ ដើរចេញ ហើយមនុស្សជាច្រើនបានឈរនៅទីនោះ បាននិយាយថា "តើវាមានន័យដូចម្តេចប៊ីលី (Billy)?"

101 ខ្ញុំនិយាយថា "នោះមិនមែនសម្រាប់ខ្ញុំទេ! នោះគឺសម្រាប់អ្នក។ ខ្ញុំបានជឿជាក់ អ្នកមិនបានជឿទេ។" ហើយគ្រាន់តែបានដើរទៅ។

102 បន្ទាប់មកគ្រូគង្វាលនិយាយមកកាន់ខ្ញុំ គាត់បាននិយាយថា "អ្នកមានន័យថា អ្នកជាមួយការអប់រំត្រឹមថ្នាក់ទីប្រាំពីរ នឹងទៅលើពិភពលោកទាំងមូល ហើយអធិស្ឋានសម្រាប់ក្សត្រ និងអ្នកខ្លាំងពូកែ ហើយនិងស្តេច ព្រមទាំងរឿងអ្វីផ្សេងទៀតឬ? អូ!" បានហើយ "បំភ្លេចវាចោលទៅ!"

103 ខ្ញុំមិនអាចបំភ្លេចវាបានទេ វាត្រូវបានឆ្លាក់ក្នុងបេះដូងរបស់ខ្ញុំ។ ឥឡូវនេះនៅទីនេះ សាមសិបបីឆ្នាំក្រោយមក អ្វីគ្រប់យ៉ាងដែលទ្រង់បានមានបន្ទូល ត្រូវបានកើតឡើងយ៉ាងល្អឥតខ្ចោះ វិធីដែលទ្រង់មានបន្ទូលទ្រង់នឹងធ្វើវាបាន។ ទ្រង់គឺជាព្រះដែលមិនអាចបរាជ័យ។ ទ្រង់តែងតែរក្សាព្រះបន្ទូលរបស់ទ្រង់។ ទ្រង់…កុំមានការសង្ស័យ។

104 ឥឡូវនេះ កត់សម្គាល់ គាត់បានទៅតាមផែនការរបស់ព្រះ(ការដឹងមុន)ការត្រាស់ហៅនៃព្រះជាម្ចាស់ ហើយតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយបានទៅមុនពេលដែលគ្រោះរាំងស្ងួតបានកំណត់ទុក។

ឥឡូវយើងដឹងថា ការជំនុំជំរះគឺបានត្រៀមជាស្រេច ក្នុងការបំផ្លាញ។

105 ឈរនៅលើភ្នំនៅថ្ងៃនោះ បងប្រុស ប៉ែងវូដ (Banks Wood) ឈរនៅទីនេះ យើងបានដើរឡើងភ្នំនេះ។ ប្រហែលជាខ្ញុំបានដកស្រង់វាម្តងទៀត ដូច្នេះអាចសង់ជំនឿរបស់អ្នក សម្រាប់ជួរការអធិស្ឋាននេះ ដែលដូចគ្នាដើម្បីយកពេលដប់ទៅដប់ប្រាំនាទីបន្ទាប់។ ខ្ញុំបានដើរមុខបងប្រុសប៉ែងបន្តិច។ គាត់បាន…ខ្ញុំគិតថាគាត់បានចាកចេញពីបងស្រី រ៉ាប់ប៊ី(Ruby) នៅពេលដែលនាងមានជំងឺ។ ហើយគាត់បានចូលមកនៅពីក្រោយខ្ញុំ ខ្ញុំបានកត់សម្គាល់ឃើញមុខរបស់គាត់ក្រហម។ ខ្ញុំបានមើលត្រឡប់មកក្រោយ។ ខ្ញុំគិតថាភ្នំនេះប្រហែលជាពិបាកបន្តិចសម្រាប់គាត់ក្នុងការឡើងដូច្នេះ ខ្ញុំក៏បន្ថយដំណើរយឺតបន្តិច។ នៅឯក្នុងវាលរហោស្ថាននៅឯ លើភ្នំ*ដូចនោះ* នៅត្រង់កន្លែងដែលទេវតានៃព្រះបានលេចមក។ យើងបានធ្វើដំណើរដំរង់ទៅទិសដៅនោះជាកន្លែងដែលពួកគេបានលេចមកពីរបីខែមុននោះ។

106 ហើយនៅពេលដែលខ្ញុំបានឡើងទៅលើភ្នំ ព្រះវិញ្ញាណនៃព្រះ...ពេលខ្ញុំបែរមកវិញសម្លឹងមើលលើកំពូលភ្នំទ្រង់មានបន្ទូលថា "រើសថ្មនោះឡើងហើយនិយាយទៅគាត់ថា 'ព្រះបន្ទូលរបស់ព្រះអង្គម្ចាស់ **ព្រះបន្ទូលរបស់ព្រះអង្គម្ចាស់** ឯងនឹងឃើញសិរីល្អនៃព្រះនៅរយៈពេលពីរបីម៉ោងក្រោយ។'"

107 ខ្ញុំក៏ចាប់យកថ្មឡើងហើយនិយាយថា "បងប្រុសប៊ែង ខ្ញុំមិនដឹងហេតុអ្វី" បោះវាទៅលើទៅ ហើយខ្ញុំនិយាយថា "**ព្រះបន្ទូលរបស់ព្រះអង្គម្ចាស់** អ្នកនឹងបានឃើញសិរីល្អនៃព្រះ។"

គាត់តបថា "ចង់មានន័យពីរ៉ាប់ប៊ីឬ?"

108 ខ្ញុំនិយាយថា "អត់ទេ ខ្ញុំគិតថាវាគ្មានអ្វីទាក់ទងជាមួយរ៉ាប់ប៊ី ប៊ែងឬក៏រ៉ាប់ប៊ីណាឡើយ។ ខ្ញុំគ្រាន់តែគិតថា បាននិយាយថា '**ព្រះបន្ទូលរបស់ព្រះអង្គម្ចាស់** នឹងមានរឿងអ្វីមួយដែលនឹងកើតឡើង។'"

109 ហើយនៅព្រឹកបន្ទាប់ នៅពេលដែលយើងកំពុងឈរនៅទីនោះ មនុស្សជាច្រើន ខ្ញុំមិនដឹងថាតើមានប៉ុន្មាននាក់ដែលកំពុងអង្គុយនៅទីនេះឥឡូវនេះ។ មានប្រហែល ដប់ពីរ ឬដប់បួន ដប់ប្រាំក្នុងចំណោមយើងអង្គុយនៅទីនោះ។ ភ្លាមៗនោះអ្នកដឹកនាំបានដើរសំដៅមករកខ្ញុំ ហើយនិយាយថា "បងប្រុសប្រាណហាំ" គាត់បាននិយាយ "ខ្ញុំឈ្មោះអញ្ចេះ—ហើយ—អញ្ចេះ" និយាយទៀតថា "ខ្ញុំគឺជាម្នាក់ដែលបានឧបត្ថម្ភអ្នក ក្នុងរដ្ឋកាលីហ្វញ៉ា(California)។"

110 ខ្ញុំនិយាយថា "ខ្ញុំរីករាយណាស់ដែលបានជួបលោក" ឌូងហ្គ្លាស ម៉ាកហុក(Douglas McHughes)។ គាត់និយាយថា "ខ្ញុំ..."ខ្ញុំនិយាយថា "ខ្ញុំរីករាយណាស់ដែលបានជួបអ្នក។" ចាប់ដៃជាមួយគាត់។

111 គាត់និយាយថា "ប្រសើរណាស់ឥឡូវនេះ ខ្ញុំចង់សួរអ្នកនូវសំណួរមួយ។" និយាយថា...រ៉យរូបប័រសាន់ ទុកចិត្តបាននៅទីនេះ បងប្រុសវូដ ធីរីនិងប៊ីលលីហើយនិង អូ បងប្រុសម៉ាកអាណាលលី ហើយនិង ខ្ញុំមិនចាំថាមានអ្នកណាខ្លះទេឈរនៅទីនោះ។ ហើយខ្ញុំ...គាត់និយាយថា "ខ្ញុំចង់សួរអ្នកនូវរឿងខ្លះ" គាត់បាននិយាយថា "តើព្រះអង្គម្ចាស់ធ្លាប់ផ្តល់និមិត្តដល់អ្នកបែបនេះទេ?"

112 ខ្ញុំតបថា "បាទបងប្រុស ប៉ុន្តែខ្ញុំមកទីនេះ គឺថាដើម្បីជៀសចេញឆ្ងាយពីវា ដើម្បីសម្រាក។"

ហើយខ្ញុំបានមើលជុំវិញ*ដូចនេះ* ហើយខ្ញុំឃើញវេជ្ជបណ្ឌិតពិនិត្យជំងឺធ្ងន់ធ្ងរ សម្លឹងមើលទៅគាត់ និយាយថា "លោកគ្រូ ម៉ាកហុក ប្រតិកម្មអាឡែហ្ស៊ីនៅក្នុងភ្នែករបស់អ្នក មិនយូប៉ុន្មានភ្នែករបស់អ្នកនឹងលានចេញ។ ខ្ញុំបានព្យាបាលអ្នករយៈពេលពីរឆ្នាំហើយ ខ្ញុំនៅតែមិនអាចធ្វើអ្វីបានសោះអំពីវា។"

ហើយខ្ញុំបានងាកទៅគាត់។ ខ្ញុំនិយាយថា "លោកសួរខ្ញុំដើម្បីអ្វី គ្រូពេទ្យរបស់អ្នកបានប្រាប់អ្នក ថ្ងៃបន្ទាប់មកទៀត 'ប្រតិកម្មអាឡែហ្ស៊ីនោះ នៅក្នុងភ្នែករបស់ អ្នក។' វាគឺពាក់កណ្តាលថ្ងៃ ប្រហែលម៉ោងដប់មួយ ហើយគាត់ត្រូវបានពាក់វ៉ែនតា។ ខ្ញុំបាននិយាយថា "មូលហេតុដែលអ្នកមិនពាក់វា ដោយសារតែព្រះអាទិត្យ វាដោយសារតែភ្នែករបស់អ្នក។ គាត់បានប្រាប់អ្នក 'អ្នកនឹងបាត់បង់ភ្នែកនោះ។'"

ហើយគាត់បានចាប់ផ្តើមយំ រួចនិយាយថា "ត្រូវហើយ។"

113 ខ្ញុំបានបែរទៅដើរនៅជុំវិញ ជាថ្មីម្តងទៀត មានប៉ែលមួយនៅក្នុងដៃរបស់ខ្ញុំ។ ហើយខ្ញុំមើលទៅ! ខ្ញុំបានឃើញគាត់ឈរនៅទីនោះសម្លឹងមើលខ្ញុំ ភ្នែករបស់គាត់ភ្លឺថ្លាណាស់។ ខ្ញុំបាននិយាយថា "**ប៉ុន្តែព្រះអម្ចាស់មានព្រះបន្ទូលដូច្នេះ** អ្នកនឹងមិនបាត់បង់ភ្នែកនោះទេ។" ខ្ញុំបានប្រម៉ាញ់ជាមួយគាត់រដូវរំហើយ ចុងក្រោយនេះគាត់អាចមើលឃើញបានល្អប្រសើរជាងខ្ញុំ និងជាងអ្នកណាទាំងអស់ក្នុងហ្វូងមនុស្ស។ គាត់មិនដែល...

114 ហើយខ្ញុំមើលឃើញថា មានស្ត្រីវ័យចំណាស់ទាញស្រោមជើងរបស់នាងចុះ ហើយសើយសំពត់ម្នាងរបស់នាងឡើង។ នាងបាននិយាយថា "កូនអើយប្រសិនបើអ្នកឃើញបងប្រុសប្រាណហាំ ប្រាប់គាត់ឲ្យអធិស្ឋានសម្រាប់ជើងរបស់ខ្ញុំផង។" ហើយខ្ញុំបានមើលចុះនៅទីនោះ ហើយមើលទៅដូចជាតិចតួច...ដូចជាដុំសាច់ព្យួរនៅលើជើងរបស់នាង នៅជុំវិញទាំងអស់។

115 ខ្ញុំនិយាយថា "ម្តាយរបស់អ្នកគឺជាស្ត្រីដែលមានសក់ស្កូវ 'កូនប្រុសរបស់ខ្ញុំអើយ' អ្នកឃើញទេ។ នាងបានប្រាប់អ្នកថា មុនពេលដែលអ្នកចាកចេញ ប្រសិនបើអ្នកបានឃើញខ្ញុំ គឺឲ្យខ្ញុំអធិស្ឋានសម្រាប់ជើងនាងផង។ នាងមានដុំសាច់រុំជុំវិញជើងរបស់នាង។" គាត់មើលទៅដូចជាសន្លប់។

បាននិយាយថា "នោះជាការពិត"

ខ្ញុំបាននិយាយ "ប្រាប់នាងទៅថាមិនអីទេ កុំបារម្ភអី។"

116 ខ្ញុំបានចាប់ផ្ដើមដើរនៅជុំវិញ។ បន្ទាប់មកខ្ញុំបានឮសម្លេងរបស់ព្រះជាម្ចាស់បានមានបន្ទូលថា "ចូរចេញពីផ្លូវឲ្យឆាប់"។

លោករ៉យរូបប័រសាន់(Roy Roberson) ឈរនៅទីនោះ ដឹងថាគាត់គឺជាជើងចាស់នៃសង្គ្រាមមួយរូប ខ្ញុំបានដាក់ដៃរបស់ខ្ញុំនៅលើស្មារបស់គាត់ ខ្ញុំបាននិយាយថា "បងប្រុសរ៉យ ចូរលោក់ខ្លួនឲ្យលឿន តាមដែលអាចធ្វើបាន!"

បាននិយាយថា "តើមានបញ្ហាអ្វី?"

ខ្ញុំនិយាយថា "ចូរចេញពីផ្លូវនេះ! លាក់ខ្លួន!"

117 ហើយគ្រាន់តែបានចាប់ផ្ដើមដើរនៅជុំវិញ ដាក់ប៉េលរបស់ខ្ញុំចុះ មើលនៅជុំវិញនោះ ក៏បានដោះមួកខ្ញុំចេញ។ ហើយនៅទីនេះទ្រង់យាងមក សិរីល្អនៃព្រះធ្លាក់ចុះនៅក្នុងខ្យល់គួចដែលបានហែកផ្នែកម្ខាងនៃភ្នំនេះចេញដូចនោះ ហើយបំផ្ទុះនិងប្រេះចេញពីកន្លែងដូចនោះបានកាត់កំពូលនៃព្រៃចេញ ប្រហែលបីឬបួនប្រាំជំហានពីលើក្បាលរបស់ខ្ញុំ។ បានត្រឡប់ទៅកន្លែងតែមួយដូច្នេះ វាបានបំបែកម្ដងទៀត។ ហើយនៅទីនេះ វាកើតឡើងបីដង។

118 បន្ទាប់មកវាបានចាកចេញទៅ លើកទីបី បងប្រុសប៉ែងបានមកនិយាយថា "នោះហើយជាអ្វីដែលអ្នកធ្លាប់បាននិយាយឬ?"

ខ្ញុំបាននិយាយថា "បាទ។"

បាននិយាយថា "តើវាគឺជាអ្វី?"

119 ខ្ញុំបាននិយាយថា "ព្រះលេចឡើងក្នុងខ្យល់គួច។" ខ្ញុំមិនដឹងថាតើទ្រង់ចង់ឲ្យខ្ញុំប្រាប់ប្រជាជនឬក៏អត់។

120 បន្ទាប់មកខ្ញុំបានទៅនិងបានអធិស្ឋានបន្តិច។ បន្ទាប់មកទ្រង់បានប្រាប់ខ្ញុំថាខ្ញុំអាចប្រាប់ពួកគេ។ ខ្ញុំបាននិយាយថា "វាគឺជាការជំនុំជំរះ ដើម្បីដាក់ទោសដល់មនុស្សនៅសមុទ្រខាងលិច។" សូមមើលនៅថ្ងៃនេះ! មើលអ្វីដែលបានកើតឡើងប៉ុន្មានម៉ោងបន្ទាប់មក។ រដ្ឋអាឡាសស្កានៃសហរដ្ឋអាមេរិចបានស្រុតចុះ ហើយឥឡូវនេះរឿងទាំងមូលនឹងស្ថិតក្រោម។ យើងកំពុងចូលក្នុងទីជំនុំជំរះ។ សេចក្ដីមេត្តាករុណាត្រូវបានគេមើលងាយមើលថោក។

121 ប៉ុន្តែសូមអរព្រះគុណដល់ព្រះ ដែលយើងមានអាហារលាក់កំបាំង អាហារខាងវិញ្ញាណ ដែលយើងកំពុងរស់នៅលើសេចក្តីល្អ ហើយនិងសេចក្តីមេត្តាករុណា នៃការបើកសម្តែងរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងថ្ងៃចុងក្រោយនេះ ទ្រង់សម្តែងអង្គទ្រង់ក្នុងចំណោមប្រជាជនរបស់ទ្រង់។ អាម៉ែន! ពួកគេចូលទៅក្នុង។ អេលីយ៉ាបានទៅ មុនពេលដែលគ្រោះរាំងស្ងួត ដែលបានកំណត់នៅក្នុងស្រុក។ សូមអរគុណព្រះសម្រាប់ការដឹកនាំ មុនសេចក្តីជំនុំជំរះបានកំណត់។ ឥឡូវនេះគឺជាពេលវេលានៃការចាកចេញហើយចូលមកក្នុង ចេញពីអង្គការទាំងនោះ ហើយចូលទៅក្នុងព្រះគ្រីស្ទពេលវេលាសម្រាប់ចេញមកហើយចូលក្នុង សម្រាប់អស់អ្នកជឿពិតប្រាកដ។

122 បន្ទាប់មកគាត់ត្រូវបានហៅ និងស្នាក់នៅទីនោះ។ សូមចាំថា គាត់មិនដែលបានចាកចេញជ្រោះនេះ រហូតដល់ព្រះបានហៅគាត់។

123 ហើយបន្ទាប់ ពីគ្រោះរាំងស្ងួតនេះជិតផុតហើយ ទ្រង់បានហៅគាត់ចេញពីទីនោះចុះទៅផ្ទះរបស់ស្ត្រីមេម៉ាយ។ ចំណាំ ទ្រង់បានហៅស្ត្រីមេម៉ាយនេះ។ ហើយស្ត្រីមេម៉ាយនេះ មិនជាប់ទាក់ទងខ្លួននាងជាមួយនឹងអ្នកមិនជឿឡើយ បានយកសញ្ញារបស់សត្វក្នុងអំឡុងគ្រោះរាំងស្ងួតនេះ។ ដូច្នេះទ្រង់បានហៅនាងចេញទៅ... បានហៅហោរាអេលីយ៉ាដើម្បីទ្រទ្រង់ស្ត្រីមេម៉ាយនេះ។ ពួកគេគ្រាន់តែមាននំតិចតួចមួយរបស់តិចតួច ដែលនាងក្តាប់ជាប់នៅដៃនាង។ ហើយអេលីយ៉ាបាននិយាយថា "សូមឲ្យវាមកខ្ញុំ ជាលើកដំបូង។ នេះជា**ព្រះបន្ទូលរបស់ព្រះអម្ចាស់** ធុងនោះនឹងមិននៅ ជាទទេហើយដបនេះក៏នឹងមិនស្ងួត រហូតដល់ថ្ងៃដែលព្រះអម្ចាស់ជាព្រះបានបញ្ជូនភ្លៀងធ្លាក់លើផែនដីនេះ។" យកព្រះជាទីមួយគឺយកព្រះបន្ទូលរបស់ទ្រង់ជាដំបូង!

124 ចំណាំ មានអាហារនៅក្នុងធុងនោះ។ រាល់ពេលនាងបានរស់ដោយសារបរិភោគអាហារ មានអាហារនៅក្នុងធុងនោះ។ វាមានប្រេងនៅក្នុងដបនេះ រាល់ពេលនាងបានការទ្រទ្រង់ពីវា។ ហេតុអ្វី? អាហារតំណាងឲ្យព្រះគ្រីស្ទនៅក្នុងតង្វាយម្សៅ។ ឯប្រេងត្រូវបានកំណត់ដើម្បីកិន ពួកគេនីមួយៗ។ រាល់ប្រេងក្នុងអាហារគឺដូចគ្នា ដែលបង្ហាញថាទ្រង់គឺដូចគ្នា កាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត។ នោះគឺជាព្រះបន្ទូលជានំបុ័ងនៃជីវិតដូចខាងក្រោមនេ ជាសារដើម្បីបង្ហាញឲ្យឃើញពីព្រះបន្ទូល។

125 ដូច្នេះវាជាថ្ងៃនេះ សម្លាញ់។ ដូច្នេះវាគឺជាថ្ងៃនេះ ដែលនំបុ័ងនៃជីវិតដែលកុមារបរិភោគ គឺសម្រេចតាមព្រះបន្ទូលរបស់ព្រះ ដើម្បីទ្រទ្រង់ពួកគេក្នុងអំឡុងពេលនៃគ្រោះរាំងស្ងួត។ តើប្រសិនបើទ្រង់ឈរក្នុងវត្តមានរបស់យើងនៅថ្ងៃនេះយ៉ាងម៉េចវិញ? ចុះបើទ្រង់កំពុងឈរនៅក្នុងវត្តមានរបស់យើងឥឡូវនេះវិញ? ទ្រង់នឹងធ្វើសកម្មភាពដូចជាទ្រង់បានធ្វើ ដូចជាកាលទ្រង់នៅក្នុងសាច់ឈាមនៅលើផែនដីនេះ។ កូនក្រមុំជាផ្នែកមួយនៃប្តី ហើយព្រះវិហារដូចគ្នានឹងព្រះគ្រីស្ទដែរ។ "កិច្ចការដែលខ្ញុំបានធ្វើ អ្នកត្រូវធ្វើផងដែរ។" វាគឺជាព្រះបន្ទូលដែលបានសម្រេចហើយ។ ទ្រង់បានប្រាប់យើងថា អ្វីដែលទ្រង់បានធ្វើ យើងនឹងធ្វើផងដែរ។

126 យើងបានកត់សម្គាល់ឃើញនៅទីនេះជាថ្មីម្តងទៀត ប្រសិនបើព្រះបន្ទូលនៅក្នុងពួកយើងហើយបានមកដល់ពួកយើងដូចជាបានធ្វើក្នុងសម័យហោរាអេលីយ៉ា ទ្រង់នឹងធ្វើដូចគ្នា ទ្រង់នឹងចិញ្ចឹមគេយ៉ាងសម្ងាត់ ព្រះជាម្ចាស់បានលាក់ពីលោកិយ។ អូ! ជាថ្មីម្តងទៀត វាធ្វើឲ្យសារនិងអ្នកនាំសារគឺតែមួយ។ អាហារខាងវិញ្ញាណត្រៀមជាស្រេច ហើយវានៅក្នុងរដូវកាលនៅពេលនេះ។ ហើយគ្រប់គ្នាអាចមានអាហារនេះប្រសិនបើអ្នកចង់បានវា ប្រសិនបើអ្នកមានបំណងចេញឆ្ងាយពីអស់ទាំងអ្នកមិនជឿ ក្នុងសម័យនេះ ប្រសិនបើអ្នកត្រៀមខ្លួនជាស្រេចដើម្បីចូលមកក្នុងព្រះគ្រីស្ទ ចូលទៅក្នុងសេចក្តីសន្យារបស់ទ្រង់។

ហើយចងចាំការសន្យារបស់ទ្រង់ ក្នុងម៉ាឡាគី ៤ លូកា ១៧:៣០ នៅក្នុងយ៉ូហាន១៤:១២ ហើយមានបទគម្ពីរបន្ថែមទៀតដែលបានប្រាប់ យ៉ូអែល ២:៣៨ និងអ្វីទាំងអស់ដែលទ្រង់នឹងធ្វើឬ ២:២៨ ជាជាងអ្វីដែលទ្រង់នឹងធ្វើនៅក្នុងថ្ងៃចុងក្រោយ។ និងរបៀបដែលពួកហោរាបានទាយថា វានឹងមានពន្លឺនៅក្នុងថ្ងៃចុងក្រោយនេះធ្វើដោយរបៀបណាតើគួរធ្វើអ្វី បទគម្ពីរទាំងអស់ចង្អុលទៅថ្ងៃចុងក្រោយនេះ។ ហើយនោះគឺជាព្រះគ្រីស្ទ! ប្រសិនបើអ្នកអាចពួនចេញឆ្ងាយឥឡូវនេះ នៅក្នុងទីកន្លែងសម្ងាត់នោះ អ្នកអាចបរិភោគនិងមើលសេចក្តីល្អនិងសេចក្តីមេត្តាករុណានៃព្រះ។ ប្រសិនបើអ្នកឈឺ មានអ្នកព្យាបាលនៅទីនោះ។

127 អ្នកចាំពេល ដែលលោកអេលីសេ នៅពេលក្រោយ បានត្រាស់ហៅឲ្យចុះ... បន្ទាប់ពីអាហារតង្វាយព្រះគ្រីស្ទ ដែលទ្រទ្រង់ផ្ទះស្ត្រីមេម៉ាយ ជាមួយម្សៅនោះ។ ចូរកត់សំគាល់ ពេលក្រោយមក នៅពេលដែលលោកបានហៅភ្លើងចុះពីស្ថានសួគ៌ ហើយបន្ទាប់មកទៀត បានបង្ហាញដល់អ្នកនាំសារនៃព្រះ នូវវិញ្ញាណនៃហោរា។

128 ចំណាំនៅវាលរហោស្ថាន នៅពេលដែលគាត់បានដេកនៅទីនោះ នៅក្រោមដើមឃីហុប ទេវតាមួយចុះមក ជាមួយប្រភេទដូចគ្នានៃអាហារ ហើយដុតនំមួយចំនួនចិញ្ចឹមគាត់។ ហើយបន្តិចក្រោយមក គេបានដាក់គាត់ឲ្យដេកជាថ្មីម្តងទៀត ហើយដាស់គាត់ឲ្យភ្ញាក់ឡើង ហើយគាត់មានអាហារបន្ថែមទៀតដុតនៅទីនោះសម្រាប់គាត់។ ហើយគាត់មានកម្លាំងនៃនំទាំងនោះ រយៈពេលសែសិបថ្ងៃ។ថ្វាយសិរីល្អដល់ព្រះ! ទ្រង់នៅដដែលកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ អូ! យើងស្រឡាញ់ទ្រង់យ៉ាងណាហ្នអាហារខាងវិញ្ញាណនៅក្នុងរដូវកាលដ៏ស័ក្តសម!

129 "វាមិនគួរយកអាហារ របស់កូនក្មេងឲ្យទៅសត្វឆ្កែទេ។" តើព្រះយេស៊ូវមិនបាននិយាយពាក្យដូចគ្នានេះ ទៅស្ត្រីសាសន៍ស៊ីរូទេឬអី? ទ្រង់បានបញ្ជូនតាមផែនការទ្រង់។ ត្រឹមត្រូវហើយ។ ហើយនោះជាអ្នកដែលព្រះអង្គបានចូលមក...ទ្រង់មិនបានទៅឯពួកសាសន៍ដទៃទេ។

130 ហើយឥឡូវនេះ ថ្ងៃនេះទ្រង់បានទៅឯសាសន៍ដទៃ ក្នុងសម័យពួកគេ ហើយមិនបានជួប...

131 អ្នកនិយាយថា "ហេតុអ្វីបាន ជាដំណឹងល្អរមិនចេញទៅក្រៅ ទៅកន្លែងធំអស្ចារ្យទាំងនេះ បូជនីយកិច្ចធំទាំងនេះ ដូចជាក្នុងចំណោមនិកាយនេះ?"

132 វាមិនមែនជាអាហាររបស់ពួកគេ។ វាមិនមែនជាព្រះវិហារអាចហៅថាអាហារ។ វាជាអាហារកូនក្រមុំ។ វាជាអាហារខាងវិញ្ញាណនៅក្នុងរដូវកាល។ វានឹងធ្វើឲ្យ ពួកគេឈឺក្រពះ។ វាសម្បូរបែបផងដែរ សម្រាប់ពួកគេ។ សូមមើល? ឃើញទេ? អ្នក—អ្នក—អ្នកមិនអាចធ្វើវាបានទេ។ ប៉ុន្តែសម្រាប់កុមារ វាជានំប៉ុងវាជាជីវិត វាជាព្រះយេស៊ូវគ្រីស្ទ ដែលនៅដដែល កាលពីម្សិលមិញថ្ងៃនេះនិងជារៀងរហូត។

133 យើងនឹងយឺតពេលជាមិនខាន បើយើងមិនចាប់ផ្តើមជួរ អធិស្ឋានពេលនេះ ដូច្នេះចូរយើងអោនក្បាលរបស់យើងក្នុងពេលនេះ។

134 ព្រះអង្គជាទីស្រលាញ់អាហារនៅក្នុងរដូវកាល អាហារខាងវិញ្ញាណ។ អ្វីដែលលោកិយមិនស្គាល់។ យើងឮព្រះអម្ចាស់របស់យើង បានមានបន្ទូលនៅយប់នោះយ៉ាងណាឬនៅថ្ងៃនោះដែលនៅស្រុកសាម៉ារី ជាកន្លែងដូចគ្នាដែលអេលីសេបាន

ដើរឡើងហើយបាននិយាយថា "ហេតុអ្វីបានជាទឹកសន្សើមនឹងមិនធ្លាក់ចុះរហូតដល់ខ្ញុំបានហៅវា។" នៅទីនេះព្រះយេស៊ូវបានឈរ ប្រាប់ពួកសិស្សរបស់ទ្រង់។

និយាយថា "លោកគ្រូអើយ ហេតុអ្វីបានជាទ្រង់មិនបរិភោគ?"

ទ្រង់មានបន្ទូលថា "ខ្ញុំមានអាហារដែលអ្នកមិនបានស្គាល់"។

135 ច្បាស់ណាស់ ព្រះអម្ចាស់អើយ អាហាររបស់ទ្រង់គឺដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះ ដើម្បីមើលឃើញការងាររបស់ព្រះ បានសម្តែងមកក្នុងវេលានោះ។ ទ្រង់បាននៅទីនោះដើម្បីមើលថាវាត្រូវបានសម្រេច។ "ខ្ញុំមិនធ្វើអ្វីឡើយលើកលែងតែព្រះបិតាខ្ញុំបានបង្ហាញខ្ញុំជាលើកដំបូង។ អ្វីដែលព្រះបិតាបានបង្ហាញខ្ញុំ ខ្ញុំនឹងធ្វើ។"

136 ហើយព្រះបិតាអើយ ដូច្នេះថ្ងៃនេះ។ ព្រះវិហារ អ្នកជឿពិតប្រាកដ រូបកាយអ្នកជឿ បានចូលមករកអាហារខាងវិញ្ញាណ ដែលមនុស្សធម្មតា មិនបានស្គាល់សោះអំពីវា។ លោកិយមិនបានស្គាល់អាហារនេះទេ ព្រះបិតាអើយ។ ប៉ុន្តែ ក្រុមជំនុំរបស់ទ្រង់ រាស្ត្ររបស់ទ្រង់ ដែលជាកូនក្រមុំនៃព្រះរាជបុត្រារបស់ទ្រង់ស្រឡាញ់វា។

137 យើងបានចូលទៅព្យាបាលរាងកាយរបស់យើង នៅពេលដែលគ្រូពេទ្យបានបរាជ័យ។ យើងបានចូលក្នុងដំណើរនេះ។ វាជាផ្នែកអាហារមួយរបស់ព្រះជាម្ចាស់ដែលទ្រង់បានផ្តល់ឲ្យក្រុមជំនុំរបស់ទ្រង់ ហើយបានសន្យា នៅក្នុងថ្ងៃចុងក្រោយដល់កូនណាដែលជឿទ្រង់។ បិតាអើយ សូមជួយយើងឲ្យក្លាយជាកូន ដែលជឿលើទ្រង់។ ព្រោះគ្រប់កិច្ចការទាំងអស់ គឺអាចធ្វើទៅបាន ដល់អ្នកណាដែលជឿ។ សូមទ្រង់ប្រោសប្រទាន បិតាជាទីស្រឡាញ់។ យើងទូលសុំនៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

138 ខ្ញុំជឿប៊ីលី(Billy)បានប្រាប់ ខ្ញុំជឿថា ពួកគេបានផ្តល់កាត អធិស្ឋានមួយចំនួន។ ប្រសិនបើមាននរណាម្នាក់ នឹងប្រាប់ខ្ញុំពីលិខិតនៃសេចក្តីអធិស្ឋាននៅលើកាតនោះ នោះហើយជាអ្វីដែលខ្ញុំចង់បាន។ [នរណាម្នាក់បាននិយាយថា "C"—Ed។] C មិនអីទេ ចូរចាប់ផ្តើមដោយកាត Cជាការចាប់ផ្តើម រហូតខ្ញុំអាចទទួលជួរចាប់ផ្តើម។ សូមមើល ឥឡូវនេះពួកគេអាចនឹងនៅជុំវិញ។ ឥឡូវនេះប្រសិនបើគ្រប់គ្នា...មិនអីទេ មើល ខ្ញុំនឹងព្យាយាម។ ខ្ញុំមិនដឹងថា យើងអាចធ្វើវា

បានឬអត់ នោះទេ។ ឬក៏យើងគ្រាន់តែអាចហៅតាមបន្ទាត់កន្លែងអ្នកអង្គុយ។ វាមិនមានបញ្ហាទេចំពោះខ្ញុំ។ ប្រសិនបើអ្នកចង់មកទីនេះនៅលើវេទិកានេះ ឬហៅតាមបន្ទាត់ វាមិនសំខាន់ទេគ្រាន់តែជាវិធីណាមួយក៏បាន។ ខ្ញុំគ្រាន់តែពឹងផ្អែក តែលើព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ។ ខ្ញុំកំពុងពឹងផ្អែកលើទ្រង់ ដើម្បីការពារព្រះបន្ទូលដែលខ្ញុំបានផ្សាយ។

139 បងប្រុស ចច រ៉ាហ្គ(George Wright)ខ្ញុំជឿជាក់។ ចាប់តាំងពីក្មេងប្រុសតូចបានចុះមកផ្ទះរបស់អ្នក ជាច្រើនឆ្នាំកន្លងមកហើយស្តាប់សម្លេងដើមឈើវាយវាត់ ខ្ញុំនៅតែជឿលើដំណឹងល្អដដែលនោះ។ ខ្ញុំជឿថាវាដូចគ្នា។

140 មិនអីទេ ខ្ញុំឃើញថាពួកគេកំពុងប្រមូលត្រឡប់មកវិញ នៅទីនេះ សម្រាប់ជួរអធិស្ឋាន។ មិនអីទេ កាតអធិស្ឋា C លេខមួយ ពីរ បី បួន ប្រាំ មកឈរនៅទីនេះ។ ប្រសិនបើអ្នកមិនអាចក្រោកឈរបាន បើអ្នកគ្រាន់តែលើកដៃរបស់អ្នកឡើង នោះគេនឹងទៅទទួលអ្នក។ [នរណាម្នាក់និយាយទៅកាន់បងប្រុសប្រាណហាំ—Ed។] តើវាគឺជាអ្វី? យេ។ អាសហា។ កាតអធិស្ឋាន C លេខមួយ ពីរ បី បួន ប្រាំ។ ហើយឥឡូវនេះចំណាំ អ្នកណាដែលមិនមានកាតអធិស្ឋាន...

141 ឥឡូវនេះ ខ្ញុំមិនដែលបានឮប្រភេទនៃការអធិស្ឋាននេះ អស់រយៈពេលជាយូរមកហើយ។ តើមានមនុស្សប៉ុន្មាននាក់ ចងចាំប្រតិបត្តិការរបស់ខ្ញុំ នៅពេលដែលយើងបានសាងសង់រោងឧបោសថនៅទីនេះ? និយាយមក "ធ្វើការងារជាគ្រូផ្សាយដំណឹងល្អ" កុំនិយាយថាខ្ញុំជាអ្នកផ្សាយដំណឹងល្អ។ និយាយថា "ធ្វើការងារជាគ្រូផ្សាយដំណឹងល្អ" មើល "ពេលវេលានឹងមកដល់ ដែលត្រូវបានផ្លាស់ប្តូរ។" ពេលនោះបានមកដល់ហើយ។ ត្រូវហើយ។ ឥឡូវនេះ នៅក្នុងនេះ ទ្រង់...

142 អ្នកមិនអាចលាយព័ន្ធកិច្ចពីរឬបីរួមគ្នាទេ ជាគ្រូគង្វាលនិងគ្រូផ្សាយដំណឹងល្អ ក្នុងពេលតែមួយទេ។ អ្នកមិនអាចធ្វើជា—ជាហោរា ផងហើយប្រហែលជាគ្រូគង្វាលផងក្នុងពេលតែមួយបានទេ ឃើញទេ ពីព្រោះអ្នកមានការងារខុសគ្នាហើយមានព័ន្ធកិច្ចខុសគ្នា។

143 ប៉ុន្តែព្រះអម្ចាស់បានប្រទានដល់ខ្ញុំ នូវអ្វីដែលខ្ញុំគួរធ្វើ នៅក្នុងដំណឹងល្អរបស់ខ្ញុំ។ ប៉ុន្តែបន្ទាប់មកទ្រង់មានបន្ទូលថា "ធ្វើការងារជាអ្នកផ្សាយដំណឹងល្អ បញ្ជាក់ ឲ្យច្បាស់នូវព័ន្ធកិច្ចរបស់អ្នក ព្រោះនឹងមានពេលមកដល់ ដែលពួកគេនឹង

មិនស៊ូទ្រាំក្នុងគោលលទ្ធិ។˝ ប្រសិនបើនោះមិនបានមកឥឡូវនេះ! គ្រប់ព្រះវិហារនិកាយនីមួយៗ បានប្រែឲ្យខ្ញុំធ្លាក់ចុះ។ ពួកគេនឹងមិនស៊ូទ្រាំនឹងគោលលទ្ធិសំឡេងទេ។ ˝ប៉ុន្តែបន្ទាប់ពីចិត្តលោភលន់របស់ខ្លួនរួច ពួកគេនឹងនាំយកគ្រូផ្ទាល់របស់ពួកគេចូលទៅក្នុង ហើយពួកគេនឹងត្រូវបានប្រែក្លាយ ទៅជារឿងព្រេងនិទានវិញ។ ហើយពួកគេនឹងធ្វើអ្វីអស្ចារ្យដែលអាចទាញយកដូចជា យ៉ាមប្រេសហើយនិងយ៉ាណែស(Jambres ans Jannes)ដែលបានប្រឆាំងនឹងលោកម៉ូសេ ប៉ុន្តែភាពល្ងីល្ងើរបស់ពួកគេនឹងត្រូវបានបើកសម្តែង។˝ មើលចុះ? ឃើញទេ? មិនអីទេបុគ្គលបន្លំខ្លួន! អ្នកមើលឃើញពីរបៀបដែលយ៉ាមប្រេស...

144 ហើយព្រះនៅស្ថានសួគ៌ទ្រង់ជ្រាប ថាថ្មជ្រុងយ៉ាងឯក(នៃរោងឧបោសថ)... ដែលនៅទីនោះ ចាប់តាំងពីឆ្នាំ ១៩៣៣ បានសរសេរនៅលើទំព័រ នៃព្រះគម្ពីរមួយ ដាក់ផ្តេកនៅទីនោះ។ មើលពីរបៀបដែលពួកគេបានធ្វើវា។ មើលអ្វីដែលបានកើតឡើង។ ក្លែងបន្លំ ពិតប្រាកដណាស់។ និយាយ ˝ចូរឲ្យពួកគេនៅតែឯងចុះ ភាពល្ងីល្ងើរបស់ពួកគេ នឹងត្រូវធ្វើឲ្យគេស្គាល់ ដូចគ្នានឹងយ៉ាមប្រេសនិងយ៉ាណែស។˝ នៅទីនេះ យើងនៅក្នុងសម័យនោះ។

145 ខ្ញុំបានឃើញព្រះវិហារ បន្ទាប់មកនៅពេលយើងត្រូវបានដាក់គ្រឹះ មនុស្សលេងកំសាន្តនៅជុំវិញ ឈរនៅជុំវិញជញ្ជាំងនៃរោងឧបោសថ។ គឺនៅទីនោះ។ ពួកគេបាននិយាយថានៅពេលដែលវាបានឡើងមក ប្រជាជននៃទីក្រុងនេះ បាននិយាយថា ˝ក្នុងរយៈពេលចន្លោះពីប្រាំមួយខែនេះ...˝ ប្រាក់ដុល្លាបូកប៉ែតសិបសេន ដើម្បីកសាងរោងឧបោសថមួយ អ្នកជួសជុលរថយន្តជាច្រើនសម្រេចចិត្តថា វាត្រូវបានក្លាយទៅជាកន្លែង យានដ្ឋានរបស់ពួកគេ។ ប៉ុន្តែវានៅតែមានទ្រុងចៀម សម្រាប់ចៀមរបស់ព្រះ។

146 មួយ ពីរ បី ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់។ C ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់។ ត្រឹមត្រូវ។

147 ឥឡូវ ˝អញជាព្រះអម្ចាស់បានដាំវាអញ នឹងស្រោចទឹកវាទាំងថ្ងៃនិងយប់ ក្រែងលោមានអ្នកណាឆក់យកវាពីដៃអញចេញ។˝ សូមមើល អ្នកពូកែរិះគន់! គ្មាននិកាយណាគាំទ្រវាឡើយ។ គ្មានក្រុមជំនុំដូចនោះនៅក្នុងប្រទេសនេះទេ។ គ្មានពេនតេកុស្តនៅក្នុងប្រទេស ក៏មិនមានអ្វីផ្សេងទៀត ដើម្បីទ្រទ្រង់វាឡើយ។ គ្រប់គ្នាប្រឆាំងនឹងការជ្រមុជទឹក គ្រប់គ្នាប្រឆាំងនឹងអ្វីផ្សេងទៀត ទាំងអស់នេះ។

សូម្បីតែគ្រួសាររបស់ខ្ញុំផ្ទាល់ឪពុករបស់ខ្ញុំផ្ទាល់ បានដេញខ្ញុំចេញពីទ្វារ ខ្ញុំបានដាក់សម្លៀកបំពាក់របស់ខ្ញុំ នៅក្នុងបាវក្រដាសតូចមួយ ហើយបានទៅរស់នៅក្នុងក្រុងញូវអាល់បាននី(New Albany)។មែនហើយ។

ប៉ុន្តែតាមរយៈគ្រោះថ្នាក់ជាច្រើន ការលំបាកនិងអន្ទាក់
ខ្ញុំបានឆ្លងកាត់រួចហើយ
វាជាព្រះគុណដែលបាននាំខ្ញុំ ឲ្យបានសង្គ្រោះ

ខ្ញុំមានអាយុហាសិបប្រាំមួយឆ្នាំ ហើយមិនយូរប៉ុន្មានខ្ញុំត្រូវឆ្លងកាត់ទន្លេ។

ព្រះគុណនាំខ្ញុំ។

ពេលខ្ញុំបាននៅទីនោះម៉ឺនឆ្នាំហើយ
នឹងមានពន្លឺភ្លឺដូចព្រះអាទិត្យ
យើងនឹងមិនមានថ្ងៃតិចទៀតទេ នឹងច្រៀងសរសើរព្រះ
ជាងពេលយើងចាប់ផ្តើមដំបូង។

អូរ ខ្ញុំសែនស្រឡាញ់ព្រះយេស៊ូវ! ទ្រង់ជាអ្វីទាំងអស់ក្នុងពិភពលោករបស់ខ្ញុំ!

148 អូរមិនអីទេ ប៉ុន្មានដងហើយដែលខ្ញុំ...ខ្ញុំចប់ដល់ត្រឹមណាទៅហើយ? តើយើងអាចធ្វើមួយចំនួនបន្ថែមទៀតបានទេ? មិនអីទេ។ តើនោះជាអ្វី ដប់ ដប់ប្រាំ? មិនអីទេ។ C ដប់ទៅដប់ប្រាំ មិនថានៅកន្លែងណា បើអ្នកអាច សូមក្រោកឡើងហើយចូលមក។ និយាយថាម៉េច? ហា? មិនអីទេ C ដប់ប្រាំទៅម្ភៃ។ ចូរយកពី C ដប់ប្រាំទៅម្ភៃ។ ដែលនឹងត្រូវមានដប់នាក់បន្ថែមទៀត។ យើងឃើញ...អ្នកឃើញឃើញកន្លែងដែលបន្ទាត់ដែលឈរនៅទីនោះ យើងមិនបានទទួលពួកគេទេ ទទួលពួកគេឲ្យមកជុំវិញ។ ហើយយើងនឹង...មិនអីទេ។

149 ឥឡូវនេះ សូមប្រុងស្មារតីឲ្យពេញទំហឹង យើងនឹងមិនមានពេលយូរទេ។ តែពេលនេះអូ ពេលនេះជាពេលណាហើយ! ខ្ញុំ—ខ្ញុំមានបំណងចង់ឲ្យអ្នករាល់គ្នាអាចស្រឡាញ់ព្រះអម្ចាស់។ ខ្ញុំ—ខ្ញុំមានបំណងចង់ឲ្យ យើងអាចមកដល់ចំនុចនោះដើម្បីសម្រេចបានសក្តានុពលនៃនាទីនេះ។ ចូរសាកល្បងវា។ គ្រាន់តែផ្តល់ការយកចិត្តទុកដាក់របស់អ្នកដល់ខ្ញុំ។

150 តើអ្វី—អ្វីដែលយើងព្យាយាមធ្វើនៅទីនេះ? យើងត្រូវបានដាក់ព្រះបន្ទូលរបស់ព្រះតាមរយៈការធ្វើតេស្តមួយ។ អេលីយ៉ាបានធ្វើរឿងដូចគ្នា បានដើរចេញពីលើ

ភ្នំបន្ទាប់ពីគាត់បានដឹងថាគាត់ត្រូវបានបញ្ជូនមកពីព្រះដើម្បីធ្វើការ។ គាត់និយាយថា "ឥឡូវនេះសូមបញ្ជាក់ថាព្រះជានរណា សូមឲ្យព្រះជាម្ចាស់ ដែលឆ្លើយតបដោយភ្លើងនោះ គឺជាព្រះពិត។"

151 ហើយអ្នកមិនជឿត្រូវបានកាត់ចេញ អូ និយាយ "ជាការប្រសើរណាស់ ប្រាកដណាស់គ្មានទេ..." ពួក—អ្នកមិនជឿបានដឹងថា ភ្លើងនឹងមិនធ្លាក់ចុះមកទេ ដូច្នេះពួកគេចាប់ផ្តើមស្រែកបន្តទៀត។

152 ប៉ុន្តែលោកអេលីយ៉ាបានដឹងថា វានឹងធ្លាក់ចុះមក ព្រោះលោកមាននិមិ្មតមកពីព្រះអម្ចាស់។

អ្នកនិយាយថា "គាត់មាននិមិ្មត?"

153 ហ្នឹងហើយ! នៅពេលដែលគាត់មានអ្វីគ្រប់យ៉ាង ដែលដាក់នៅក្នុងលំដាប់លំដោយហើយ គាត់បាននិយាយថា "បពិត្រព្រះអម្ចាស់ ខ្ញុំបានធ្វើការទាំងអស់នេះ នៅក្នុងពាក្យបញ្ជារបស់ទ្រង់។" ហើយបន្ទាប់មកភ្លើងបានចាប់ផ្តើមធ្លាក់ចុះ។ ពេលណាព្រះបន្ទូលរបស់ព្រះ ត្រូវបានរក្សាទុកទៅនឹងលិខិត បន្ទាប់មកវាជាកិច្ចការរបស់ព្រះ ដើម្បីថែរក្សាអ្វីដែលសេសសល់។ ទ្រង់គ្រាន់តែសុំឲ្យអ្នកដាក់វានៅទីនោះ។ ហើយត្រូវប្រាកដថា អ្នកកំពុងហៅ ដើម្បីដាក់វា នៅទីនោះ។ ឃើញទេ? ហើយប្រសិនបើអ្នកបានដាក់ហើយ ទ្រង់នឹងធ្វើអ្វីដែលនៅសល់។

154 ឥឡូវនេះនៅទីនេះមនុស្សនឹងចូលមកតាមរយៈជួរដែលខ្ញុំនឹងត្រូវអធិស្ឋាន... ឥឡូវនេះ ប្រសើរណាស់ អ្នកបាននៅជិតនឹងជញ្ជាំងហើយ មិនអីទេ ទៅកាន់បន្ទាត់ដើម្បីចាប់ផ្តើម។ ឥឡូវនេះជាលើកដំបូង យ៉ាងហោចណាស់មានកន្លែងណាមួយនៅទីនេះ នៅក្នុងអគារនេះមនុស្សមួយចំនួន...

តើមានប៉ុន្មាននាក់នៅទីនេះ ដែលមានជំងឺហើយមិនមានកាតអធិស្ឋានលើកដៃឡើង។ ឃើញទេ មានច្រើនណាស់។ ឥឡូវអ្នកបានដឹងថាបើព្រះអម្ចាស់របស់យើង...ហើយខ្ញុំជឿថាទ្រង់ប្រទាន ប្រសិនបើទ្រង់នៅតែដដែល កាលពីម្សិលមិញថ្ងៃនេះនិងជារៀងរហូត។ ទ្រង់ឆ្លើយតបបន្ទាត់ការអធិស្ឋាន។ មនុស្សមករកទ្រង់នៅក្នុងជួរដ៏ធំ ទាំងហ្វូង ទ្រង់ពាល់ពួកគេ ប្រទានពរអោយគេ។ បន្ទាប់មកទ្រង់បានសម្រាកហើយមានបន្ទូលថា "តើអ្នកណាបានពាល់ខ្ញុំ?" មើលជុំវិញបានប្រាប់ស្ត្រីម្នាក់ថា តើប៉ះទ្រង់ដើម្បីអ្វី ហើយនាងបានតបថាបញ្ហាឈាមរបស់នាងត្រូវបានឈប់ សេចក្តីជំនឿរបស់នាង បានធ្វើឲ្យនាងជា។

155 ចុះបើនាងងាកមកហើយនិយាយអញ្ចេះវិញថា "មែនហើយខ្ញុំមិនដឹងទេព្រះអង្គម្ចាស់អើយ ខ្ញុំមានជំងឺនេះយូរមកហើយ?" វានឹងមិនកើតឡើងទេ។ ទេ វានឹងមិនកើតឡើងឡើយ។ គ្មានទេ។

156 ចុះបើទ្រង់បានប្រាប់ស្ត្រីម្នាក់នោះថា "ដោយសារតែពាក្យនេះ ដែលអ្នកបាននិយាយ នោះកូនស្រីរបស់អ្នក ដែលមានអារក្សចូលនោះ អារក្សបានចេញពីនាងហើយ" បើនាងឆ្លើយបែបនេះវិញ "មែនហើយឥឡូវនេះព្រះអម្ចាស់អើយ ខ្ញុំ—ខ្ញុំចង់ឲ្យទ្រង់ធ្វើតាម*វិធីមួយនេះ*វិញ?" អារក្ស—អារក្សនោះនឹងនៅតែសណ្ឋិតក្នុងក្មេងស្រីនោះ។ ប៉ុន្តែនាងបានរំពឹងថានឹងបានរកឃើញកូនរបស់នាង តាមវិធីដែលទ្រង់បានមានបន្ទូល នាងនឹងរកឃើញ។

157 ឥឡូវនេះទ្រង់បានប្រាប់យើងថា "បើឯងមានសេចក្តីជំនឿ! តែបន្តិចនឹងនិយាយទៅភ្នំនេះថា 'ចូររើចេញ' ហើយមិនសង្ស័យនៅក្នុងចិត្ត ប៉ុន្តែជឿថាអ្វី ដែលអ្នកបាននិយាយថានឹងបានសម្រេច អ្នកអាចមានវា។ នៅពេលដែលអ្នកអធិស្ឋានចូរជឿថាអ្នកបានទទួលវា ហើយវានឹងប្រទានឲ្យអ្នកជាក់ជាមិនខាន។" តើវាជាការសន្យាដ៏អស្ចារ្យយ៉ាងណាហ្ន៎!

158 ឥឡូវនេះពួកអ្នកដែលបានប្រកាសដំណឹងល្អ ក្នុងសង្គមសព្វថ្ងៃ មិនបានជឿការនោះទាំងស្រុងទេ។ គាត់ដើរឡើងទៅឯទ្វារ សម្លឹងមើល ឬក៏ឈរនៅទីនោះ ហើយបាននិយាយថា "ជាការប្រសើរណាស់ គ្រាន់តែជាក្រុមបរិសុទ្ធមួយផ្សេងទៀត" ហើយគាត់បានដើរចេញទៅ។ ឃើញទេ? ប៉ុន្តែគាត់មិនបានដឹងថា នេះគឺជាអាហារដែលលាក់កំបាំងទេ។ គាត់មិនបានដឹងថា នេះគឺជារឿងសម្ងាត់ដែលបានលាក់ទុកពីគាត់ឡើយ។ គាត់មិនស្គាល់វាទេ។ វា—វាត្រូវ—វាជាការគួរឲ្យសោកស្តាយ គួរឲ្យអាណិតគំនិតទទេ វេទនា ខ្វាក់និងមិនស្គាល់។ ឃើញទេ? នោះគឺជារឿងអាក្រក់។

159 ឱព្រះជាម្ចាស់អើយ សូមឲ្យខ្ញុំស្លាប់ចុះ ជាជាងឲ្យខ្ញុំក្លាយជាបែបនេះ។ ខ្ញុំចង់ស្លាប់ជាជាង(បាទ ពិតមែន)ជាងការធ្វើដូចនោះ។ ខ្ញុំគិតថាយើងគ្រប់គ្នាក៏ដូចគ្នាមិនអញ្ចឹងឬ? [ក្រុមជំនុំបាននិយាយថា "អាម៉ែន។"—Ed ។]

160 ប៉ុន្តែឥឡូវនេះ ព្រះបានសន្យាដល់យើងនូវរឿងទាំងនេះ នៅក្នុងថ្ងៃចុងក្រោយនេះ។ ក្នុងម៉ាឡាគីជំពូក៤ បានចែងថា ព្រះយេស៊ូវគ្រីស្ទនឹងយាងចុះមក ក្លែងអង្គទ្រង់ នៅក្នុងសាច់ឈាមរបស់មនុស្ស ដូចជាទ្រង់បានធ្វើនៅក្រុងសូដុម។ ពិតមែន

ហើយ ហើយបានមានបន្ទូលថា ពិភពលោកនឹងមានសណ្ឋានដូចនៅ ក្នុងក្រុង សូដុម។ ហើយថែងទៀតថា "ហើយបន្ទាប់ពីការនោះមក កូនមនុស្សនឹងលេចមកនៅថ្ងៃនោះ។" ឃើញទេ បុរសម្នាក់ដែលបានចុះមក នៅក្នុងទំរង់នៃមនុស្សម្នាក់ ដែលជា "អេឡូហ៊ីម" ដោយលោកអ័ប្រាហាំ មុនពេលកូនប្រុសក្នុងសេចក្តីសន្យាបានមក។ មើលនោះជាអ្វីលោកអ័ប្រាហាំបាននិយាយថាវាគឺជាព្រះ។ ហើយព្រះគម្ពីរបានថែងថា មានបុរសបីនាក់នាំគ្នាមករកគាត់ មានធូលីដីលើសំលៀកបំពាក់របស់ពួកគេ ពួកគេធ្វើដំណើរ អង្គុយចុះ បរិភោគដូចមនុស្ស។ ហើយព្រះយេស៊ូវមានព្រះបន្ទូលថា "នឹងមានពេលមកដល់ ជាវេលាដែលលោកិយមានលក្ខណៈដូចក្រុងសូដុម បន្ទាប់មកកូនមនុស្សនឹងលេចមកម្តងទៀត។" មិនមែនជាព្រះរាជបុត្រានៃព្រះទេ គឺជាកូនមនុស្ស ឃើញទេ នឹងបង្ហាញអង្គទ្រង់។

161 ឥឡូវ គួសចំណុចនេះជាមួយអ្វីដែលហោរាចុងក្រោយបានទាយ "មើល អញបានចាត់ឯងឲ្យទៅឯអេលីយ៉ាជាហោរា ហើយ—ហើយលោកនឹងបង្វែរចិត្តកូនឲ្យមកឯឪពុកវិញ។" ឃើញទេ? ដំណឹងមួយដើម្បីនាំពួកគេត្រឡប់ទៅព្រះគម្ពីរ ហើយកូនមនុស្ស នឹងបង្ហាញអង្គទ្រង់នៅក្នុងថ្ងៃនោះ។ ហើយនៅថ្ងៃនៃសំឡេងនៃពួកជំនុំចុងក្រោយ ទេវតា ទីប្រាំពីរ អាថ៌កំបាំងនៃព្រះ ត្រូវបានបើកសម្តែងនៅក្នុងថ្ងៃនោះ។ ត្រាទាំងប្រាំពីរនឹងត្រូវបានខូច។ អាថ៌កំបាំងរបស់ក្រុមជំនុំនិងរឿងទាំងអស់បានកើតឡើងនិងអ្វី—...តើអ្វីដែលបានកើតឡើង។

162 ឃើញទេ ពួកគេមិនស្គាល់វាទេ។ ព្រះយេស៊ូវមានព្រះបន្ទូលថា "ពួកផារិស៊ីជាមនុស្សខ្វាក់!" ក៏បានបន្ថែមទៀតថា "ប្រសិនបើមនុស្សខ្វាក់នាំមនុស្សខ្វាក់ពួកគេទាំងពីរនឹងដួលធ្លាក់នៅក្នុងប្រឡាយ" សូមមើល នោះហើយជាហេតុផលដែលមនុស្សទាំងនោះមិនបានមើលឃើញ។

163 អាថ៌កំបាំងនេះ គឺជាត្រាទាំងនោះ ក្រុមជំនុំនីមួយៗបង្កើតអង្គការចូលទៅក្នុងវាហើយការសម្ងាត់មួយក្នុងនោះគឺខុសចំពោះព្រះ។ អ្នកឃើញទេ លោកបណ្ឌិតលី (Lee)? ឃើញទេ មើលចុះ។ នោះហើយ។ រឿងដែលនៅទីនោះ។ នោះជាផ្នែកមួយនៃការសម្ងាត់។ ពួកគេបានរៀបចំ ហើយមើល វាខុសពីបំណងព្រះហឫទ័យព្រះទាំងស្រុង។ ហើយនោះនឹងត្រូវបានប៉ះពាល់ នៅក្នុងថ្ងៃចុងក្រោយ ហើយនាំមនុស្ស មិនមែនដើម្បីសាសនា ឬនិកាយមួយទេ ប៉ុន្តែត្រឡប់ទៅព្រះបន្ទូលពិត។ ហើយព្រះបន្ទូលពិតនឹងមកដល់ក្រុមដាក់លាក់មួយហើយកូនមនុស្សនឹង

លេចមកបង្ហាញអង្គទ្រង់នៅកណ្ដាលគេ "ដូចកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត"។

164 អូរខ្ញុំ! អូខ្ញុំស្រឡាញ់ការនោះ។ ខ្ញុំស្រឡាញ់—ខ្ញុំស្រឡាញ់ក្នុងការអួតពីទ្រង់។ ខ្ញុំស្រឡាញ់—ក្នុងការធ្វើឲ្យទ្រង់អស្ចារ្យនៅចំពោះមនុស្ស។ ខ្ញុំមិនចាំបាច់ធ្វើឲ្យទ្រង់អស្ចារ្យទេ ព្រោះទ្រង់អស្ចារ្យរួចទៅហើយ។ ទ្រង់ខ្ពស់សម្បើម ដែលអ្នកមិនអាចរំលងទ្រង់បាន ហើយក៏ជ្រៅណាស់ ដែលអ្នកមិនអាចមុជជ្រៅជាងទ្រង់ ទូលាយដែលអ្នកមិនអាចក្រឡឹងជុំវិញទ្រង់ឡើយ តែអ្នកនៅតែមានបន្ទប់សម្រាប់ទ្រង់គឺជាចិត្តរបស់អ្នក។ អ្នកនឹងមិនទទួលទ្រង់ទេឬ? តើព្រះអង្គម្ចាស់របស់យើងអស្ចារ្យយ៉ាងណាហ្ន៎។ មិនអីទេ។

165 ឥឡូវនេះ សូមគ្រប់គ្នាស្ងប់ស្ងាត់ឲ្យមែនទែន។ ឥឡូវនេះយើងនិយាយអំពីការនេះ។ ហើយឥឡូវនេះជារឿងរបស់វា វាពិតទេ? ឥឡូវនេះវាអាចនឹងមានអ្នកប្លែកមុខមួយចំនួននៅទីនេះ។ ខ្ញុំអាចនិយាយថាបើ...ទៅអ្នក ប្រសិនបើព្រះគ្រីស្ទគឺនៅតែដូចកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត តើទ្រង់នឹងធ្វើអ្វីនៅក្នុងនាទីនេះ? ទ្រង់នឹងធ្វើរឿងដដែលដែលទ្រង់បានធ្វើ នៅពេលដែលទ្រង់បាននៅទីនេះកាលពីគ្រាមុន។ តើវាត្រូវទេ? ជំនឿរបស់មនុស្ស នឹងបានពាល់ព្រះពស្ត្ររបស់ទ្រង់ ហើយទ្រង់នឹងងាកមក។ ដូចជាទ្រង់បានធ្វើទៅកាន់ស្ត្រីម្នាក់ នៅឯអណ្ដូងទឹកផងដែរ ហើយទ្រង់បានធ្វើកន្លែងផ្សេងទៀត ហើយទ្រង់បានជ្រាបគំនិតរបស់ពួកគេ។

ឥឡូវនេះអ្នកនិយាយថា "តើទ្រង់អាចប្រោសខ្ញុំបានទេ?"

166 ព្រះបន្ទូលរបស់ទ្រង់បានឱ្យដឹងថា ទ្រង់បានធ្វើរួចទៅហើយ។ ប៉ុន្តែរឿងរបស់វាគឺ គឺដើម្បីបង្ហាញអង្គទ្រង់ផ្ទាល់ ឲ្យគេបានស្គាល់ថាទ្រង់នៅទីនេះ។

167 ឥឡូវនេះបើទ្រង់លេចមកឲ្យយើងឃើញ ក្នុងរាងកាយសាច់ឈាម មើលទៅដូចជាលោកហូហ្វម៉ាន់(Hofmann's) *សិរីសារនៃព្រះគ្រីស្ទនៅវ័យសាមសិបបីឆ្នាំ*ហើយឈាមរត់ចេញពីព្រះហស្តរបស់ទ្រង់ តទៅទៀត ស្នាមដែកគោលនិងស្នាមជាំ នៅទូទាំងរាងកាយទ្រង់ ខ្ញុំនឹងមិនទទួលយកបានទេ។ ទេ ទេ។ ទេ ទេ។ នៅពេលដែលទ្រង់យាងមក ដោយអង្គទ្រង់ "ភ្នែកទាំងអស់នឹងឃើញទ្រង់ គ្រប់ទាំងអណ្ដាតនឹងថ្លែងពីទ្រង់ ហើយដូចផ្លេកបន្ទោរ មកពីទិសខាងកើតទៅឯលោកខាងលិច វានឹងបានដូច្នេះ"។ ឃើញទេ? យើងមិនជឿ សត្វគោនិងដីឥដ្ឋធម្មតាទាំងនេះទេ។ យើងជឿលើព្រះដ៏ជាព្រះបន្ទូល។

168 ប៉ុន្តែទ្រង់តំណាងអង្គទ្រង់ ដោយយករាងកាយអ្នក ហើយនិងខ្ញុំប្រទានអំណោយទានដល់អ្នកហើយនិងខ្ញុំហើយតាមរយៈអំណោយទានទាំងនេះ ទ្រង់បានបង្ហាញអង្គទ្រង់ឲ្យយើងស្គាល់។ នោះហើយជាអាហារសម្ងាត់។ មិនថាទ្រង់បង្ហាញអង្គទ្រង់ឲ្យស្គាល់ប៉ុណ្ណាដោយសារខ្ញុំ អ្នកត្រូវតែជឿ អ្នកត្រូវតែមានអំណោយទាននៃក្តីជំនឿផងដែរ ដើម្បីជឿ។ តើអ្នកជឿទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed។] ហើយឥឡូវនេះបើសិនជាទ្រង់នឹងបង្ហាញព្រះអង្គទ្រង់នៅក្នុងលក្ខណៈដូច្នេះតើអ្នកនឹងជឿទ្រង់ទេ? ["អាម៉ែន។"]អស់ពីចិត្តរបស់អ្នក តើអ្នកជឿទ្រង់ទេ? អូ! អស្ចារ្យណាស់ គ្រាន់តែរង់ចាំទ្រង់ទៅ គ្រាន់តែរង់ចាំមើលអ្វីដែលទ្រង់មានបន្ទូល។

169 ទីនេះបុរសម្នាក់ឈរនៅទីនេះ។ ខ្ញុំមិនដែលឃើញគាត់នៅក្នុងជីវិតរបស់ខ្ញុំបើតាមខ្ញុំដឹង។ មើលទៅដូចជាមនុស្សល្អ ខ្លាំងក្លា មានសុខភាពល្អ ហើយគាត់ប្រហែលជាខ្ញុំ—ខ្ញុំ—ខ្ញុំមិនដឹងទេ។ ប៉ុន្តែគាត់កំពុងឈរនៅទីនោះ។ ឥឡូវនេះខ្ញុំអាចទៅដាក់ដៃលើគាត់ ហើយអធិស្ឋានសម្រាប់គាត់ សួរគាត់ថាតើគាត់អាចជឿឬទេ។ គាត់អាចឈរនៅទីនេះ ហើយប្រាប់ខ្ញុំដោយនិយាយថា "ខ្ញុំ—ខ្ញុំ—ខ្ញុំចង់ឱ្យអ្នកអធិស្ឋានឲ្យ *ដូច្នេះ—និង—ដូច្នេះ ។* ហើយខ្ញុំបាន—ខ្ញុំបានធ្លាក់ចុះយ៉ាងដំណំ។ ខ្ញុំឈឺក្បាលជានិច្ច។ ខ្ញុំមានដំបៅក្នុងក្រពះរបស់ខ្ញុំ" ឬអ្វីទៀត។ គាត់—គាត់ ខ្ញុំមិនដឹងទេ។ គាត់អាចនិយាយពាក្យណាមួយ ក្នុងចំណោមពាក្យទាំងនេះ។

170 ខ្ញុំចង់និយាយថា "បាទបងប្រុស មិនអីទេ។ ខ្ញុំនឹងដាក់ដៃលើអ្នកហើយអធិស្ឋានសម្រាប់អ្នក។" ច្បាស់ជាមិនអីទេ។ នោះហើយជាអ្វីដែលយើងបានធ្វើចុះមកតាមសម័យកាល។ តើវាត្រូវទេ?

171 ប៉ុន្តែសូមចាំថាព្រះយេស៊ូវបានមានបន្ទូលថា វានឹងមានភាពខុសគ្នា មុនវេលាដែលទ្រង់យាងមក ដូចជានៅក្នុងថ្ងៃនៃក្រុងសូដុម។ ហើយបុរសដែលបានឡើងមក បានត្រឡប់ទៅតង់ដែលជាកន្លែងដែលសារ៉ានៅ ហើយទ្រង់មានបន្ទូលថា (មិនមែនជា"អាប់រ៉ាម" ទៀតទេ។ ឥឡូវ) គឺ "អ័ប្រាហាំ" វិញ។

172 ឃើញទេគាត់ជាលោកអាប់រ៉ាមថ្ងៃមុន។ ប៉ុន្តែលោកបានជួបនិមិត្តមួយហើយព្រះអម្ចាស់បានប្រាប់គាត់ថា "អញនឹងផ្លាស់ប្តូរឈ្មោះរបស់ឯង" ។

173 ហើយនៅទីនេះគឺព្រះអម្ចាស់ទ្រង់ផ្ទាល់ នៅក្នុងទំរង់ជាមនុស្ស ដែលបរិភោគនិងផឹកជាមួយគាត់។ បានមានបន្ទូលថា "អ័ប្រាហាំ ឯណាភរិយាសារ៉ាររបស់អ្នក?" សា—...រ៉ា មិនមែនសា—រ៉ា—យ ទេ។

លោកបាននិយាយថា "នាងនៅក្នុងតង់ដែលនៅពីក្រោយទ្រង់" ។

174 បានមានបន្ទូលថា "អញនឹងទៅលេងឯង នេះតាមការសន្យារបស់អញកាលពីម្ភៃប្រាំឆ្នាំមុន"។

175 ហើយសារ៉ាប្រហែលជាសើចដល់ខ្លួននាង។ ទ្រង់មានបន្ទូលថា "សារ៉ាសើចនៅក្នុងតង់ដោយពោលថា 'តើការទាំងនេះអាចនឹងកើតឡើងដូចម្ដេច?'" អូ! ហា។ "មិនមានអ្វីជាការលំបាកទេសម្រាប់ព្រះ?" សូមមើល? គ្មានអ្វីសោះ។ ទេលោក។

176 ឥឡូវ ទ្រង់មានបន្ទូល ព្រះយេស៊ូវបានសន្យាថា "ទ្រង់ជាកូនមនុស្ស" ដែលជាព្រះបន្ទូល(តើអ្នកជឿទេ?) "នឹងមកនៅក្នុងថ្ងៃចុងក្រោយ ហើយបង្ហាញអង្គទ្រង់ផ្ទាល់នៅក្នុងពេលដែលលោកិយបានដូចជាក្រុងសូដុមនិងក្រុងកូម៉ូរ៉ា។" អ្នកជឿការនោះត្រូវទេ?

177 មុនពេលដែលយើងមានសេចក្ដីអធិស្ឋានមួយ មានអ្នកខ្លះបានអធិស្ឋាននៅទីនោះ និងមើលថាតើកូនមនុស្ស គឺនៅតែដូចកាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត។ គ្រាន់តែសួរប្រសិនបើគាត់និយាយថា "ព្រះអម្ចាស់អើយ មនុស្សមិនស្គាល់ខ្ញុំ ប៉ុន្តែខ្ញុំដឹងថាទ្រង់នៅតែដដែល កាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត" មើលថាតើគាត់បានប្រាប់អ្នកដូច្នេះ។

បាទលោក។ ឥឡូវនេះងើបក្បាលរបស់អ្នកបន្តិច។

178 នៅពីក្រោយខ្ញុំ។ វាជាកូនក្មេង។ វាមានកំដៅក្ដៅខ្លាំង ដោយសាជំងឺគ្រុនក្ដៅ។ វាគឺជាក្មេងស្រីតូច។ អ្នកមកពីក្រៅទីក្រុង។ កុមារមានបញ្ហាក្រពះ។ មែនហើយ។ គ្រាន់តែជឿ។

179 ឥឡូវនេះ តើនោះគឺជាអ្វីដែលទ្រង់មានបន្ទូលថាទ្រង់នឹងធ្វើឬ? ខ្ញុំមិនដែលឃើញមនុស្សម្នាក់នោះក្នុងជីវិតរបស់ខ្ញុំឡើយ។ ព្រះជាម្ចាស់គង់នៅស្ថានសួគ៌ទ្រង់ជ្រាប។

180 បុរសម្នាក់នេះនៅទីនេះ មើលទៅគាត់គឺខ្លាំងនិងមានសុខភាពល្អ។ ប៉ុន្តែមើលស្រមោលនៅលើគាត់នៅទីនោះ? នោះមានន័យថា លុះត្រាតែព្រះជួយគាត់ គាត់នឹងមិននៅយូរទេ។ គាត់មានជំងឺមហារីក។ វាគឺនៅក្នុងសួតរបស់អ្នក។

ឥឡូវនេះ កូនមនុស្សគឺនៅទីនេះ។

គាត់មានបន្ទុកដែលនៅក្នុងចិត្តរបស់គាត់ សម្រាប់ក្មេងប្រុសតូចនេះ។ ត្រូវទេ? អ្នកជឿថាព្រះអាចប្រាប់ខ្ញុំបានទេ ថាតើមានអ្វីមិនប្រក្រតីជាមួយកូននោះ? [ប្អូនប្រុសនិយាយថា "ខ្ញុំដឹងថាទ្រង់អាចធ្វើបាន។"—Ed] ទ្រង់អាចធ្វើបាន។ គាត់បានសន្លប់ដោយសារត្រូវអំពើរមន្តអាគម ដូចទំរង់នៃជំងឺឆ្កួតជ្រូក។ វាបានកើតឡើងមួយដងរួចហើយក្នុងពេលថ្មីៗនេះ។ ["ព្រឹកមិញនេះ"។] ត្រូវហើយ គឺកាលពីព្រឹកមិញនេះ។ ហើយអ្នកជឿថាអ្នកនឹងរស់ដើម្បីចិញ្ចឹមក្មេងប្រុសនេះឲ្យធំឡើង ហើយគាត់នឹងមិនអីទេ? ["បាទ"។]

181 តើឆាលីកុក(Charlie Cox)នៅឯណា? គាត់នៅឯណា? ឆាលលីអ្នកនៅឯណា? ខ្ញុំបានគិតថាគាត់នៅទីនេះយប់នេះ។ នៅទីនេះ ឆាលលី (Charlie)។ លោកការី(Gary)អ្នកនៅឯណា? លោកឡារី(Larry)តើគាត់នៅទីនេះទេ? កូនតូចរបស់គាត់មានរឿងដូចគ្នា ច្បាស់ណាស់គឺដូចគ្នានេះដែរ។ អ្នកនៅកន្លែងណាលោកឡារី(Larry)? សូមអញ្ជើញមកទីនេះមួយនាទី។ ប្រសើរណាស់ អ្នកនៅទីនេះ។ ក្មេងប្រុសតូចនេះនៅទីនេះ មានបញ្ហាដូចគ្នា។ ឪពុកនិងម្តាយរបស់គាត់ជាមិត្តល្អរបស់ខ្ញុំ។ ឆ្នាំមុនខ្ញុំចុះទៅទីនោះ ហើយក្មេងប្រុសតូចនេះ ត្រូវមន្តអាគមហើយក៏ប្រកាច់ដួលសន្លប់។ វាគឺជាជំងឺឆ្កួតជ្រូក។ ខ្ញុំចាប់វានៅលើក្មេងប្រុសតូចនេះ ហើយបានសូមព្រះដើម្បីប្រោសគាត់ឲ្យបានជា។ ចាប់តាំងពីពេលនោះមកគាត់មិនដែលប្រកាច់ទៀតទេ។ នោះជាឪពុករបស់គាត់ម្តាយរបស់គាត់បានកំពុងអង្គុយនៅទីនេះកន្លែងណាមួយ ហើយនៅទីនេះគឺជាក្មេងប្រុសតូចនោះផ្ទាល់។

182 ឥឡូវនេះតើលោកជឿដែរឬទេ? (សូមអរគុណលោកឡារី Larry)។ លោកជឿទេ? សូមឲ្យព្រះនៃស្ថានសួគ៌បានប្រទានឲ្យបានដូចអ្នក ហើយអ្នកនឹងរស់នៅដើម្បីចិញ្ចឹមបីបាច់កុមារនេះទៀត។ សូមព្រះប្រទានពរអ្នក។

ចូរអធិស្ឋាន។

183 ព្រះអង្គជាទីស្រឡាញ់ សូមជួយគាត់។ ខ្ញុំអធិស្ឋានសូមឲ្យសេចក្ដីមេត្តានិង ព្រះគុណរបស់ទ្រង់ ធ្លាក់មកលើគាត់និងប្រទានពរដល់គាត់។ នៅក្នុងព្រះនាម ព្រះយេស៊ូវ។

184 ត្រឡប់ទៅរដ្ឋល្វីសៀនណា(Louisiana)ឥឡូវនេះ រីករាយ សរសើរតម្កើងព្រះ សំរាប់គាត់។

185 អូរ មែនហើយគាត់បានមកពីរដ្ឋល្វីសៀនណា(Louisiana)ប្រាកដជានៅ ជុំវិញបឹងឆាលេស។ ពិតហើយ។ ឃើញទេ ខ្ញុំអាចចាប់គំនិតរបស់អ្នកបាន ឥឡូវនេះ។ សូមលើកសរសើរដល់ព្រះ!

186 មែនហើយអ្នកកំពុងសូមនូវ—រឿងល្អ អ្នកចង់មានកូន។ អ្នកមានកូនពីរនាក់ រួចទៅហើយ ប៉ុន្តែអ្នកចង់បានមួយទៀត។ សូមឲ្យព្រះនៃស្ថានសួគ៌ប្រទានពរ ប្អូនស្រី។ សូមអញ្ជើញមកនៅទីនេះខ្ញុំចង់ដាក់ដៃលើអ្នក។

187 ព្រះអង្គជាទីស្រឡាញ់ សូមប្រោសឲ្យស្ត្រីនេះបានសម្រេចតាមបំណងនៃ ដួងចិត្តរបស់នាង ព្រោះវាជាមូលហេតុសក្តិសម។ នៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

ឥឡូវនេះសូមទៅមានបុត្រចុះ។

188 ព្រះទ្រង់ជាព្រះដែលល្អ។តើអ្នកជឿដែរឬទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed] ទ្រង់ជ្រាបអ្វីទាំងអស់ដែលយើងត្រូវការ។ ទ្រង់ផ្គត់ផ្គង់រៀងរាល់សេចក្ដីត្រូវ ការប្រសិនបើយើងជឿ។ ទ្រង់មានបន្ទូលថា "ប្រសិនបើអ្នកអាចជឿ!"

189 ខ្ញុំបានចាប់ដៃរបស់អ្នកនៅកន្លែងណាមួយ។ ខ្ញុំមិនចាំថាជាកន្លែងមួយណាទេ ប៉ុន្តែនៅកន្លែងណាខ្ញុំបានចាប់ដៃរបស់អ្នក។ ខ្ញុំមិនច្បាស់ក៏មិនចាំបានទេ ប៉ុន្តែ យើងបានជួបគ្នាកន្លែងណាមួយ នៅថ្ងៃនេះនៅកន្លែងណាមួយ ប៉ុន្តែខ្ញុំមិនដឹង ថា នៅត្រង់ណាទេ។ ប៉ុន្តែនោះមិនមែនជាកន្លែងណា ដែលយើងនៅទីនេះដើម្បី និយាយនោះទេ។ អ្នកនៅទីនេះដើម្បីនិយាយឬដើម្បីអធិស្ឋាន ចង់ឲ្យខ្ញុំអធិស្ឋាន សម្រាប់នរណាម្នាក់ផ្សេងទៀត។ នោះជាការពិត។ គាត់មិននៅទីនេះទេ។ គាត់ នៅក្នុងរដ្ឋចចគៀរ(Georgia)គាត់ឈឺ។ មិនត្រឹមតែផ្នែកសាច់ឈាមប៉ុណ្ណោះដែល គាត់ឈឺទេ ខាងវិញ្ញាណក៏គាត់ឈឺដែរ! បងប្អូនជីដូនមួយរបស់អ្នក។ អ្នកជឿថា

ព្រះជាម្ចាស់នឹងថែរក្សាការនេះ ពីព្រោះអ្នកបានឈរសម្រាប់ទ្រង់? អ្នកឈរមាំ? សូមអញ្ជើញមកនៅទីនេះនិងអធិស្ឋានរួមគ្នា។

190 ព្រះអង្គជាទីស្រឡាញ់ សូមប្រោសដល់បុរសម្នាក់នេះតាមបំណងចិត្តរបស់គាត់ ថាគាត់អាចនឹងចូលទៅនិងឃើញបុរសម្នាក់ស្រែករកព្រះ។ នៅក្នុងព្រះនាមព្រះយេស៊ូវខ្ញុំសូមទូលថ្វាយ។ អាម៉ែន។

សូមព្រះប្រទានពរអ្នក។ កុំសង្ស័យ។ ជឿដោយអស់ពីបេះដូងរបស់អ្នក។

191 តើអ្នកសុខសប្បាយទេ? វាមិនមានន័យថាខ្ញុំមិនអាចចាប់ដៃរបស់អ្នក អង្រួនដល់នោះទេ ប៉ុន្តែពេលដែលអ្នកលាតដៃចេញមក ខ្ញុំបានឃើញមួយ។ វាជាស្រមោល ងងឹតហើយខ្មៅ។ នោះហើយជាមូលហេតុ។ ខ្ញុំដឹងថាខ្ញុំបានចាប់ដៃរបស់អ្នក ខ្ញុំរកឃើញវាតាមវិធីនោះ ឃើញទេ។ ប៉ុន្តែវាគឺជាជំងឺមហារីក។តើអ្នកជឿថាព្រះអង្គអាចបណ្តេញវាចេញទេ? វានៅលើសុដន់ខាងឆ្វេងរបស់អ្នក។ អ្នកចង់ត្រឡប់ទៅរដ្ឋការូលីនណា (Carolina) ដើម្បីសរសើរតម្កើងព្រះអម្ចាស់ សម្រាប់ការប្រោសឲ្យជាមែនឬទេ? យល់អ្វីដែលខ្ញុំចង់មានន័យទេ? ចូរអធិស្ឋាន។

192 ព្រះអង្គជាទីស្រឡាញ់ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ដែលមានវត្តមានឥឡូវនេះ ក្មេងៗបរិភោគនំប៉័ងរបស់ព្រះជាម្ចាស់ សូមឲ្យក្មេងម្នាក់នេះរីករាយក្នុងក្តីជំនឿដែលជានំប៉័ងនៃព្រះ ដែលទ្រង់បានប្រទានឲ្យគាត់ឥឡូវនេះ សម្រាប់ព្យាបាលគាត់។ សូមឲ្យគាត់បានចូលទៅនិងបានសះស្បើយ នៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

ព្រះប្រទានពរអ្នកប្អូនប្រុស។ ជឿដោយអស់ពីចិត្តរបស់អ្នក។

តើអ្នកសុខសប្បាយទេ?

193 តើនេះមិនមែនជាពេលវេលាមួយ ដែលអស្ចារ្យទេឬ? មើលទៅដូចជាមានភាពរីករាយធ្លាក់ចុះមកលើមនុស្ស។ ឬ វាប្រហែលជាស្តាប់ទៅដូចជាត្រចៀករបស់ខ្ញុំមានអ្វីចេញពីតែ "ហ្វីវ" គឺមានសម្លេង "ហ្វីវ" ដូច្នេះ ឃើញទេ។ វាជានំប៉័ងរបស់ក្មេង។ ឃើញទេ? វាគឺជារបស់អ្នក។ វាគឺសម្រាប់អ្នក។ វាមិនមែនសម្រាប់ខ្ញុំទេ! វាគឺសម្រាប់អ្នក។ ខ្ញុំពិតជាអរគុណខ្លាំងណាស់ ក្នុងពេលឥឡូវនេះ ខ្ញុំមិន...ខ្ញុំបានប្រសើរណាស់តាមខ្ញុំដឹង ប៉ុន្តែវាជានំប៉័ងសម្រាប់ខ្ញុំផងដែរ នៅពេលដែលខ្ញុំត្រូវ

ការ។ វាជានំប៉័ងសម្រាប់អ្នក។ វាជាការលើកទឹកចិត្ត។ ដល់អស់អ្នកដែលមិនគ្រាន់តែសម្រាប់អ្នកឈឺនោះទេ គឺនាំមកនូវដួងចិត្តរបស់យើងឡើងចំពោះព្រះ។

194 នេះគឺពិតជានៅក្នុងរដូវកាល អ្វីដែលទ្រង់មានបន្ទូលទ្រង់នឹងធ្វើ "ហើយដូចនៅក្នុងថ្ងៃនៃក្រុងសូដុម ដូច្នេះវានឹងត្រូវបាននៅក្នុងការយាងមករបស់កូនមនុស្សក្នុងវេលាដែលកូនមនុស្សត្រូវបានលេចមក។" ឃើញទេ? "ហើយមើល អញបានបញ្ជូនអេលីយ៉ាឲ្យអ្នក មុនពេលដែលថ្ងៃដ៏ធំគួរស្ញែងខ្លាចរបស់ព្រះអម្ចាស់។ លោកនឹងស្តារចិត្តរបស់ប្រជាជនត្រឡប់ទៅព្រះបិតាវិញ។" មើល? ឃើញទេ?

195 "ហើយមនុស្សសុចរិតនឹងដើរចេញពីលើផេះនៃ—មនុស្សអាក្រក់។" ពួកគេនឹងដុតដូចជាឡរដុតនំ ឃើញទេ ផែនដីនឹងឆេះ។ យើងមើលឃើញថាវានឹងធ្លាក់ចុះនៅត្រង់កន្លែងនោះ។ ភ្នំភ្លើងនឹងរីករាលដាលនៅទូទាំងផែនដីហើយផ្ទៃមេឃនឹងមានពេញដោយភ្លើង។

ឱថ្មនៃសម័យកាល សូមអាណិតមេត្តាដល់ខ្ញុំឥឡូវនិងបន្តទៀត។

196 តើអ្នកសុខសប្បាយទេ? ល្អណាស់ មានរឿងមួយ អ្នកមាននារីម្នាក់មានបញ្ហា បញ្ហាស្ត្រី។ មានរឿងផ្សេងទៀត។ អ្នកភ័យខ្លាចដូចក្នុងសម័យកាលគួរឲ្យភ័យខ្លាច។ មានផលវិបាកនៃគ្រប់ប្រភេទ។ ប៉ុន្តែអ្នកមានបំណងប្រាថ្នាមួយផងដែរ គឺទទួលព្រះវិញ្ញាណបរិសុទ្ធ។ នោះគឺត្រូវហើយ។ នោះហើយ។ តើអ្នកជឿទេថាអ្នកកំពុង...តើអ្នកបានសារភាពអ្វីគ្រប់យ៉ាង? អ្នកជឿថាប្រសិនបើខ្ញុំដាក់ដៃលើអ្នករាល់គ្នា ហើយសុំព្រះឲ្យធ្វើវា នោះព្រះវិញ្ញាណបរិសុទ្ធនឹងយាងមក? [បងស្រីបាននិយាយថា"ចាស"—Ed។] តើអ្នកជឿការនោះទេ។ ["ចាសលោក។"]ចូរអធិស្ឋាន។

197 ព្រះអង្គជាទីស្រឡាញ់ ខ្ញុំដាក់ដៃរបស់ខ្ញុំលើស្ត្រីម្នាក់នេះ ដែលនៅក្នុងទំរង់នៃពួកសាវក ហើយសូមឲ្យនាងបានទទួលបុណ្យជ្រមុជនៃព្រះវិញ្ញាណបរិសុទ្ធ។ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ សូមឲ្យនាងបានទទួលវា។ អាម៉ែន។

198 កុំសង្ស័យ។ វាជាកម្មសិទ្ធិរបស់អ្នកឃើញទេ។ វាគឺជារបស់អ្នក។ វាជា—ជានំប៉័ងរបស់ក្មេង។

199 មានអារម្មណ៍គួរឱ្យ អស់សំណើចបន្តិច នៅពេលដែលខ្ញុំនិយាយថា "បញ្ហាស្ត្រី"? មែនឬមិនមែន? ព្រោះនោះជាអ្វីដែលអ្នកមានផងដែរ។ ឥឡូវ អ្នកជឿថាអ្នកទាំងអស់គ្នា នឹងមិនអីទេមែនទេឥឡូវនេះ? ទៅចុះ ហើយអរគុណព្រះអម្ចាស់។

200 តើអ្នកសុខសប្បាយទេ? តើអ្នកជឿដោយអស់ពីចិត្តរបស់អ្នកទេ? អ្នកជឿថាអ្នកនឹងអាចបរិភោគដូចជាអ្នកបានធ្វើជាយូរមកហើយ? ត្រូវហើយ។ ទៅចុះហើយនិយាយថា "សូមអរគុណព្រះអម្ចាស់។ ខ្ញុំជឿហើយ។" វត្តមានរបស់ព្រះអម្ចាស់។

201 អ្នកជឿថាបញ្ហាឈឺខ្នងនឹងចាកចេញពីអ្នក ហើយអ្នកនឹងបានប្រសើរឡើងឬ? មិនអីទេ។ គ្រាន់តែចូលទៅហើយនិយាយថា "សូមអរគុណ ព្រះជាទីស្រឡាញ់" ហើយព្រះនឹងប្រទានវា។

202 អ្នកជឿថា អ្នកអាចជាព្រះអម្ចាស់នឹងធ្វើឲ្យអ្នកបានសះស្បើយ ហើយនឹងមិន មានជំងឺរលាកសន្លាក់នោះទេ តែនឹងបានប្រសើរហើយនិងមានសុខភាពល្អ? អ្នកជឿទេ? ចូរទៅអរគុណទ្រង់និយាយថា "ព្រះអម្ចាស់អើយខ្ញុំទទួលយកដោយអស់ពីចិត្តខ្ញុំហើយខ្ញុំជឿហើយ"។

តើអ្នកទាំងអស់គ្នានៅទីនោះជឿយ៉ាងម៉េចអំពីវា?

203 អ្នកនៅទីនេះ ដាក់ដៃរបស់អ្នកនៅលើ ស្ត្រីម្នាក់អង្គុយជាប់នឹងអ្នកនៅទីនោះ ប្រាប់នាងថាសរសៃនិងជំងឺរលាកសន្លាក់នឹងចាកចេញពីនាង។ នៅពេលដែលនាង...?...

204 ព្រះប្រទានពរអ្នក។ អ្នកជឿថាអ្នកនឹងជាសះស្បើយនៅពេលនេះ? ចូរទៅផ្ទះហើយឲ្យបានជាចុះ។ ព្រះប្រទានពរអ្នក។ ចូរទៅតាមលើផ្លូវរបស់អ្នកហើយនិយាយថា "សូមអរគុណព្រះអម្ចាស់យេស៊ូវ។"

205 តើអ្នកសុខសប្បាយទេ? [បងស្រីបាននិយាយថា "សរសើរតម្កើងព្រះអម្ចាស់។—Ed។] អ្នកជឿថារោគស្ត្រីនឹងចាកចេញពីអ្នកដែរឬទេ? ["ខ្ញុំជឿ"។] ហើយអ្នកនឹងបានជា? ["សូមអរគុណព្រះយេស៊ូវ។"]ចូរទៅហើយនិយាយថា "អរគុណព្រះអម្ចាស់។" ["សូមអរគុណព្រះយេស៊ូវ។"]

206 តើអ្នកសុខសប្បាយទេ? [បងស្រីបាននិយាយថា "ទាញឆ្អឹងខ្ចីមួយ។"—Ed] ហេតុអ្វី ខ្ញុំអើយ ខ្ញុំ! ["ថូធិន"]ខ្ញុំស្គាល់ឈ្មោះរបស់អ្នក។ ខ្ញុំ—ខ្ញុំធ្លាប់...["ថូធិន"] នៅពេលដែលខ្ញុំជាគ្រូគង្វាលក្រុមជំនុំបាទីស្ទ។ ["Totten"]ថូធិន។ បងស្រី

ដេល្លា ថូធិន (Dala Totten)។ អ្នកកំពុងរងទុក្ខវេទនាជាមួយនឹងបញ្ហាខ្នង ឥឡូវនេះ។[''ចាស''] វានឹងមិនអីទេឥឡូវនេះ។ អ្នកជឿថាទ្រង់នឹងធ្វើឲ្យអ្នកប្រសើរ ឡើងបានទេ? [''ចាស''។] អ្នកចងចាំនូវអ្វីដែលបានកើតឡើងកាលពីប៉ុន្មានឆ្នាំមុន នៅ ព្រះវិហារបាទីស្ទមីលថោនទេ(Milltown)?[''ចាសខ្ញុំចាំបាន'']ទ្រង់នៅតែជា ព្រះជាម្ចាស់តែមួយ នៅថ្ងៃនេះ។ [''អូ! អរគុណព្រះ!'']ព្រះប្រទានពរដល់អ្នក ប្អូនស្រី ខ្ញុំអើយ។

លោកចចវ៉ាយ អ្នកនៅឯណា? អ្នកចាំបានទេ? ខ្ញុំអើយ ដោយរបៀបណា...

អ្នកជឿថាប្រសិនបើខ្ញុំគ្រាន់តែដាក់ដៃរបស់ខ្ញុំនៅលើអ្នក ដោយមានការ ចាក់ប្រេងតាំង អ្នកជឿថាអ្នកនឹងបានជាឬទេ? មកនេះ។ នៅក្នុងព្រះនាមនៃ ព្រះយេស៊ូវគ្រីស្ទ នាងបានជាសះស្បើយ។ អាម៉ែន។ មានជំនឿឡើង!

ប្រសើរណាស់ តើអ្នកទាំងអស់គ្នាជឿដោយអស់ពីចិត្តរបស់អ្នកទេ? [ក្រុមជំនុំ និយាយថា ''អាមែន''—Ed] ។

207 ឥឡូវ ជាការប្រសើរយ៉ាងណាហ្ន ដែលនាំមកនូវការចងចាំចាស់ ឲ្យបាន ឃើញស្ត្រីនោះ! ខ្ញុំមិនអាចគិតពីឈ្មោះរបស់នាងនៅឡើយទេ ប៉ុន្តែខ្ញុំ...[នរណា ម្នាក់និយាយថា ថូធិន ''Totten''។—Ed។]ថូធិន។ ថូធិនត្រូវហើយ។ អូ បាទ កូនស្រីរបស់នាងគឺ ប៊ឺតធី(Bertie)។ ត្រឹមត្រូវ។ នោះពិតជាត្រឹមត្រូវណាស់។ កុំ គិតថាខ្ញុំហួសព្រំដែន ខ្ញុំគ្រាន់តែដូចជា អ្នកដឹងទេ វាដូចជា...ខ្ញុំមិនអាចពន្យល់ បានទេ។

208 ប៉ុន្តែបញ្ហាខ្នងរបស់អ្នកត្រូវបានបាត់ហើយ។ ចូរទៅសរសើរតម្កើងព្រះអម្ចាស់ ហើយយាយថា ''អរគុណព្រះជាម្ចាស់។''

209 អ្នកជឿថាបញ្ហាបេះដូងរបស់អ្នកនឹងបានជាសះស្បើយផងដែរ មែនទេ? [អ្នកជំងឺនិយាយថា ''បាទ''—Ed] ចូរទៅដោយអរសប្បាយហើយនិយាយថា ''សូមអរគុណព្រះអម្ចាស់យេស៊ូវ'' ហើយជឿ។ ត្រូវហើយ។ មានជំនឿឥឡូវ។ កុំ សង្ស័យ។

210 អញ្ជើញមកនាងអើយ។ តើអ្នកជឿដោយអស់ពីចិត្តរបស់អ្នកទេ? អ្នកមាន បញ្ហាជាច្រើន។ អ្នកមានបញ្ហាខ្នងផងដែរ។ អ្នកជឿថាព្រះនឹងព្យាបាលអ្នកដែរ ឬ? មិនអីទេ គ្រាន់តែចូលទៅហើយអរសប្បាយចុះ។ ថានោះជាទ្រង់ដែលធ្វើឲ្យ

អ្នកមានអារម្មណ៍បែបនោះ។ សូមអរគុណព្រះអម្ចាស់។ ព្រះជាម្ចាស់ប្រទានពរដល់អ្នកប្អូនស្រី។

211 សួស្តីសាន់នី(Sonny)។ [ក្មេងប្រុសនិយាយថា "សួស្តី!"—Ed] តើអ្នកជឿថាព្រះ នឹងប្រោសឲ្យភាពភ័យខ្លាចពីក្មេងបានបាត់ទៅឬទេ? អ្នកជឿទេ? ត្រឹមត្រូវ។ សួស្តីសម្លាញ់ សូមឱ្យខ្ញុំចាប់ដៃរបស់អ្នកបន្តិច។

212 ព្រះអង្គជាទីស្រឡាញ់ សូមដកយករឿងអាក្រក់នេះចេញពីក្មេងប្រុសតូចនេះ ហើយសូមឲ្យគាត់បានរស់នៅដូចមនុស្សធម្មតា។ នៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

213 ព្រះប្រទានពរអ្នកប្អូនប្រុស។ អ្នកជឿ មែនឬមិនមែន? អ្នកនឹងមិនអីទេ។ កុំសង្ស័យអ្វីទាំងអស់។

214 វ័យក្មេងខ្លាំងពូកែ មានបញ្ហាបេះដូង។ អ្នកជឿថាព្រះអាចព្យាបាលអ្នកទេ? [អ្នកជំងឺបាននិយាយថា "បាទលោក។"។—Ed] ទៅហើយនិយាយថា "សូមអរគុណព្រះអម្ចាស់ចំពោះការព្យាបាលខ្ញុំ"។

215 អ្នកជឿថាព្រះជាម្ចាស់នឹងព្យាបាលបញ្ហាក្រពះអ្នកនិងធ្វើឲ្យអ្នកប្រសើរឬទេ? ចូរទៅដោយអរសប្បាយហើយនិយាយថា "សូមអរគុណព្រះអម្ចាស់" ។

216 ទ្រង់នៅតែជាព្រះ ទ្រង់មែនឬមិនមែន? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed] រឿងតែមួយដែលអ្នកត្រូវធ្វើគឺគ្រាន់តែជឿ។ នោះជាការត្រឹមត្រូវឬទេ? តើអ្នកជឿកូនមនុស្សនៅក្នុងថ្ងៃចុងក្រោយឬទេ?

217 មានអ្វីមួយបានកើតឡើងនៅទីនេះប៉ុន្មាននាទីមុននេះ ហើយខ្ញុំមិនអាច... ព្យាយាមស្វែងរកថាវានៅកន្លែងណា។ នរណាម្នាក់មានសេចក្ដីជំនឿហើយបានធ្វើអ្វីមួយ។ ឬ ប្រហែលជាខ្ញុំនឹងទទួលពួកគេនៅថ្ងៃអាទិត្យក្រោយ ឬនៅពេលដែលខ្ញុំអាចធ្វើបាន។ តើអ្នក—អ្នក...មាននៅទីនោះជាថ្មីម្ដងទៀត។ អ្នកលើកដៃរបស់អ្នកឡើង។ តើអ្នកជឿទេថាព្រះអាចប្រោសឲ្យអ្នកជាសះស្បើយ ពីបញ្ហាបេះដូង ក៏ប្រោសកូនស្រីរបស់អ្នកនៅទីនោះជាមួយ...អ្នកជឿទេ? លោកស្រីនេហ្វ(Neff) អ្នកជឿថាព្រះ...លោក ឡេវនេហ្វ(Leo Neff)។ ខ្ញុំមិនស្គាល់អ្នកនោះទេ ប៉ុន្តែនោះគឺជាអ្នក។ អ្នកមានបញ្ហាបេះដូងនិងកូនស្រីតូចអ្នកមានបញ្ហាតំរងនោម។ អ្នកជឿ

ថានាងនឹងបានប្រសើរឡើងឬទេ? ក្តីជំនឿរបស់អ្នកធ្វើឱ្យអ្នកបានជា។ ជឿដោយអស់ពីចិត្តរបស់អ្នក។

218 អ្នកដែលនៅខាងក្រោយអាងទឹក ដែលឈរនៅទីនោះ ដែលមានបញ្ហាក្រពះ ព្រះយេស៊ូវគ្រីស្ទបានប្រោសអ្នកហើយ។

219 អ្នកជឿទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed] ទ្រង់នៅតែដដែល កាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត។ ចូរដាក់ដៃរបស់យើងនៅលើ គ្នាទៅវិញទៅមក ឥឡូវនេះ។ អូ គិតពីវេលាដែលជាកន្លែងដែលយើងកំពុងរស់នៅគិតពីជំនាន់នេះ។ គិតពីយើងដែលកំពុងនៅក្នុងវត្តមាននៃព្រះយេស៊ូវគ្រីស្ទ ជាព្រះបុត្រារបស់ព្រះ ជាម្ចាស់។ ទ្រង់សន្យាថាទ្រង់នឹងធ្វើការនេះនៅក្នុងថ្ងៃចុងក្រោយ។ ខ្ញុំបានដាក់ ដៃលើកន្សែងទាំងនេះ។

220 ព្រះអង្គជាទីស្រឡាញ់ ខ្ញុំអធិស្ឋានថាទ្រង់នឹងប្រទានពរកន្សែងទាំងនេះ ទាំងព្យាបាលរាងកាយមនុស្សក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

221 ឥឡូវនេះ ដាក់ដៃលើគ្នាទៅវិញទៅមក អ្នករាល់គ្នាគឺជាអវៈយវៈរបស់ព្រះ គ្រីស្ទ។ ព្រះវិញ្ញាណបរិសុទ្ធដដែល ដែលបានសន្យាថានឹងបង្ហាញពីសេចក្តី កំបាំងនៃចិត្ត និងធ្វើរឿងទាំងនេះទ្រង់គង់ក្នុងអ្នក។ អ្នកគឺជាផ្នែកមួយនៃទ្រង់ហើយទ្រង់គឺ ជាផ្នែកមួយនៃអ្នក។ ឥឡូវនេះទ្រង់មានបន្ទូលថា "ទីសម្គាល់នេះនឹងនៅតាមពួកគេដែលជឿ។" នោះជាអ្នក។ "ប្រសិនបើពួកគេដាក់នៅលើដៃអ្នកណាដែលឈឺពួកគេនឹងបានជាសះស្បើយ"។ ឥឡូវនេះកុំអធិស្ឋានសម្រាប់ខ្លួនអ្នកចូរអធិស្ឋានសម្រាប់ម្នាក់ដែលអ្នកបានដាក់ដៃរបស់អ្នកលើព្រោះពួកគេកំពុងអធិស្ឋានសម្រាប់អ្នក។ ឥឡូវចូរយើងអធិស្ឋានរួមគ្នា ហើយសូមកុំឲ្យមានមនុស្សទន់ខ្សោយណានៅក្នុងអាគារនេះឡើយ។ ហេតុអ្វីបានយើងរង់ ចាំយូរម្លេះបងប្អូនប្រុស ស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ គឺនៅទីនេះព្រះវិញ្ញាណបរិសុទ្ធ ព្រះទ្រង់គង់នៅទីនេះដែលជារឿងដែលយើងនឹងនិយាយ។

222 ព្រះយេស៊ូវជាទីស្រឡាញ់ យើងកំពុងទទួលស្គាល់វត្តមានរបស់ទ្រង់។ ទ្រង់បានប្រោសទារកតូចដែលស្លាប់ហើយឲ្យមានជីវិតឡើងវិញនៅថ្ងៃបន្ទាប់ ដោយការអធិស្ឋាននៃសេចក្តីជំនឿ។ ព្រះអង្គជាទីស្រឡាញ់ មានមនុស្សជាច្រើននៅទីនេះដែលយើងមិនអាចចូលទៅបាន ពេលវេលចេះតែកន្លងទៅ ប៉ុន្តែពួកគេបានដាក់ដៃលើគ្នាទៅវិញទៅ។ ពួកគេជាអ្នកជឿ។ យើងកំពុងអង្គុយនៅក្នុង

វត្តមានរបស់ព្រះអង្គម្ចាស់យេស៊ូវគ្រីស្ទ ដែលបានរស់ពីស្លាប់ នៅតែដដែលកាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូត។

223 សាតាំងឯងត្រូវកម្ចាត់ហើយ! ព្រះយេស៊ូវគ្រីស្ទបានផ្តួលឯង! ទ្រង់បានរស់ពីស្លាប់ហើយឈរនៅក្នុងចំណោមយើងនៅយប់នេះ បញ្ជាក់ការពិតនៃសារនេះនៅថ្ងៃចុងក្រោយ។ ចេញពីមនុស្សនេះ! ចេញពីពួកវានៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ! ព្រះយេស៊ូវមានបន្ទូលថា"នៅក្នុងនាមរបស់ខ្ញុំពួកគេនឹងដេញអារក្ស" ហើយអ្នកត្រូវបានគេដេញចេញ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ចូរចាកចេញពីក្រុមជំនុំនេះ!

224 អស់អ្នកណាដែលបានទទួលការព្យាបាលសូមក្រោកឈរឡើង អស់អ្នកណាដែលបានទទួលការព្យាបាលសូមក្រោកឈរឡើង។ លើកដៃរបស់អ្នក ឥឡូវនេះ ហើយសរសើរតម្កើងដល់ទ្រង់!

"ឥឡូវនេះខ្ញុំបានទទួលការព្យាបាលពីព្រះ" និយាយទៅកាន់ព្រះ។ ឥឡូវនេះខ្ញុំបានទទួលការព្យាបាលពីព្រះ។ [ក្រុមជំនុំនិយាយថា "ឥឡូវនេះខ្ញុំបានទទួលការព្យាបាលពីព្រះ។"—Ed។] ទ្រង់នៅតែដដែល កាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូតព្រះគ្រីស្ទ។ ["ទ្រង់គឺនៅតែដដែល កាលពីម្សិលមិញ ថ្ងៃនេះនិងជារៀងរហូតព្រះគ្រីស្ទ"។] ខ្ញុំឥឡូវបានជឿទ្រង់ហើយ។ ["ខ្ញុំឥឡូវបានជឿទ្រង់ហើយ។"] ជួយចិត្តដែលមិនជឿព្រះអង្គអើយ។ ["ជួយចិត្ត ដែលមិនជឿព្រះអង្គអើយ។"] អាម៉ែន។ ["អាម៉ែន។"]

ខ្ញុំនឹងសរសើរទ្រង់ ខ្ញុំនឹងសរសើរទ្រង់
សរសើរកូនចៀមដែលបានសុគតជំនួយមនុស្សមានបាប
ថ្វាយសិរីល្អដល់ទ្រង់ អ្នករាល់គ្នាអើយ
ដ្បិតឈាមទ្រង់បានលាងស្នាមប្រឡាក់នៃអំពើបាបយើង។

225 តើអ្នកមិនស្រឡាញ់ទ្រង់ទេឬ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"។—Ed] តោះចូរសរសើរតម្កើងទ្រង់អញ្ចឹង។ មនុស្សគ្រប់គ្នា ដោយលើកដៃឡើងថ្វាយការសរសើរដល់ទ្រង់ ខណៈពេលដែលបងប្អូនមកទីនេះដើម្បីបញ្ចប់។

**អាហារផ្នែកវិញ្ញាណតាមរដូវកាលដ៏ ស័ក្តិសម** KHM65-0718E

(Spiritual Food In Due Season)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាច ថ្ងៃអាទិត្យ ថ្ងៃទី 18 កក្កដា 1965 នៅរោងឧបោសថ Branham Jeffersonville, Indiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG